ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ

# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី “ឌុច”

## សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩**

**សវនាការលើកទី២៣**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

លោក ម៉ាត្ទូ គ្រីស្ពារ *(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ ប៊េត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទូអាត ហ្វដ *(Mr. Sturart FORD)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអាវ

**មេធាវីការពារជនជាប់ចោទ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

កញ្ញា ទី ស្រ៊ីនណា

លោក យ៉ុង ផានិត

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃី ស្ទួតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain WERNER)*

លោកស្រីអេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ខ្លឹមសារ

## សាក្សី

**សាក្សីជំនាញ៖** ក្រេក អេតឆេសាន់

សួរបន្តដោយ លោក អាឡាំង វ៉ែនណឺ ផ្ដើមពី ............................................................ទំព័រ ១

សួរដោយ លោក ការ សាវុត្ថ ផ្ដើមពី.....................................................................ទំព័រ ៣២

សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្ដើមពី.....................................................................ទំព័រ ៣៦

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊េត | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ក្រេក អេតធេសាន់,សាក្សី | អង់គ្លេស |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:០៩:៤៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលលើអ្នកជំនាញបណ្ឌិត ក្រេក អេតឆេសាន់ ជាបន្ត ។ មុននឹងចាប់ផ្តើមក្រឡាបញ្ជើឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគីដែលត្រូវបាន ដែលត្រូវចូលរួមនៅក្នុងដំណើរសវនាការនាពេលនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលបានចូលរួមនៅក្នុងដំណើរនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ ចំណែកឯអ្នកជំនាញក៏មានវត្តមានក្នុងបន្ទប់សវនាការផងដែរ ។

**ប្រធានអង្គជំនុំ៖**

កាលពីម្សិលមិញដំណើរការនៃការពិភាក្សាដេញដោលនេះ គឺដល់វេទិកានៃភាគីដើមបណ្តឹងរដ្ឋប្បវេណី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ។ ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺភាគីខាងមេធាវីភាគីខ្មែរគឺបានធ្វើរួចហើយ ប៉ុន្តែ នៅមេធាវីខាងអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋ-ប្បវេណីក្រុមមួយដែលមានការប៉ុនប៉ងក្នុងការតាំងសំណួរពាក់ព័ន្ធទៅនឹងអ្នកជំនាញបណ្ឌិត ក្រេក អេតឆេសាន់ ពាក់ព័ន្ធនឹងការអនុវត្តបក្សកុម្មុយនីស្តកម្ពុជានេះ ហើយនិងរបាយការណ៍របស់អ្នកជំនាញដែលបានធ្វើកន្លងមក ។

អ៊ីចឹងសូមអញ្ជើញមេធាវីក្រុមមួយ អាឡាំង វែនណឺ បើមានសំណួរ គឺអង្គជំនុំជម្រះប្រគល់វេទិកានេះជូនទៅលោកមេធាវីដើម្បីមានសំណួរដែលពាក់ព័ន្ធជាមួយនឹងអ្នកជំនាញរូបនេះ ។ សូមអញ្ជើញ ។

**សួរដោយលោក អាឡាំង វែនណឺ៖**

សូមអរគុណលោកប្រធាន ។ អរុណសួស្តីលោកបណ្ឌិត អេតឆេសាន់ ។ មុនពេលដែល ខ្ញុំចាប់ផ្តើមខ្ញុំសូមជម្រាបថា តាងនាមឲ្យក្រុមបរបស់ខ្ញុំ ខ្ញុំសូមអរគុណចំពោះការអត់ធ្មត់របស់លោក និងការអញ្ជើញរបស់លោក មកចូលរួមនៅក្នុងទីនេះ។

អ៊ីចឹង គឺខ្ញុំសូមអរគុណដែលលោកខំប្រឹងប្រែងយ៉ាងអស់ពីកម្លាំងចិត្តកាយនេះ ។ ខ្ញុំសូមចាប់ផ្តើមសំណួរទាក់ទងទៅនឹងទារុណកម្ម ។

**សៈ** ជនជាប់ចោទកាលពីសប្តាហ៍មុន គឺនៅថ្ងៃច័ន្ទ ថ្ងៃ១៨ ខែឧសភា ខ្ញុំនឹងធ្វើការអានដំណាក់ស្រង់ចេញពីប្រតិចារឹក ។ ជនជាប់ចោទ ហាក់ដូចជាបានលើកឡើង ហើយវាទាក់ទងទៅនឹងសំណួររបស់ចៅក្រម ឡាវ៉ែន៍ គឺសញ្ញាណនៃការកម្ទេច គឺវាមានហួសពីការសម្លាប់ទៅទៀត គឺប្រតិចារឹកជាភាសាអង់គ្លេស ថ្ងៃទី១៨ ខែឧសភា ទំព័រទី១៤ ។ ជនជាប់ចោទបានលើកឡើងថា ខ្ញុំសូមបន្ថែមនៅពេលដែលយើងនិយាយអំពីការកម្ទេច មានន័យថា ការចាប់ខ្លួន ហើយអ្នកដែលត្រូវបានចាប់ខ្លួន គឺត្រូវបានសួរចម្លើយដោយប្រើទារុណកម្ម ហើយធ្វើឡើងដោយមិនឲ្យគ្រួសាររបស់គេដឹង ។ ដូច្នេះ សំណួររបស់ខ្ញុំនោះគឺថា តើលោកយល់ស្របដែរ ឬទេពាក្យថា "កម្ទេច" ដែលប្រើប្រាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺមិនមានន័យត្រឹមតែការសម្លាប់ទេ គឺមានន័យជ្រាលជ្រៅជាងហ្នឹងទៅទៀត ។

**ឆៈ** សូមអរគុណលោកមេធាវី ។ គឺខ្ញុំដឹងភាសាវិជ្ជាទាក់ទងទៅនឹងភាសាខ្មែរ ប៉ុន្តែ តាមការយល់របស់ខ្ញុំនោះ ពាក្យខ្មែរដែលយើងបកប្រែថា ពាក្យ "ស្មាស" នេះគឺពាក្យថា "កម្ទេច" បានន័យថាកម្ទេច ។ គឺវាមានន័យជ្រាលជ្រៅជាងការសម្លាប់ទៅទៀត ។ ជាញយៗ យើងឃើញពាក្យនេះត្រូវបានបកប្រែថា មិនត្រឹមតែពាក្យថាកម្ទេចទេ វាត្រូវបានគេបកប្រែថា កម្ទេចឲ្យម៉ត់ ហើយនិងធ្វើឲ្យវាទៅជាកម្ទេចតូចៗ ។ វាមានន័យថា ដំណើរការកម្ទេចនេះ គឺវាមានរយៈពេលយូរហើយវាពាក់ព័ន្ធទៅនឹងការសម្លាប់ដោយប្រើរ៉ៃ និងត្បូងចបទៅនឹងលលាដ៍ក្បាល ដែលថា នេះជាសារដែលទាក់ទងទៅនឹងការសម្លាប់នោះ ។ គឺពាក្យនេះមិនពាក់ព័ន្ធត្រឹមតែការសម្លាប់តែប៉ុណ្ណោះនោះទេ គឺវាទាក់ទងទៅនឹងការកម្ទេចសម្លាប់ដោយផ្នែកចិត្តសាស្ត្រផងដែរ ។ នៅក្នុងរបបនេះ គឺការប្រព្រឹត្តិលើអ្នកទោសនៅស-២១ គឺវាជាលក្ខណៈធ្វើឲ្យមនុស្សអាប់អោន និងវាបានបង្កទៅលើបុគ្គលនីមួយៗ ។ ដូច្នេះ ខ្ញុំគួរតែនិយាយដោយសង្ខេបថាវាពិតជាដូច្នោះមែន ពាក្យថា "កម្ទេចនេះ"គឺវាមានន័យជ្រាលជ្រៅជាងពាក្យថា សម្លាប់ទៅទៀត ។

**សៈ** សូមអរគុណ ។ គឺខ្ញុំសូមលើកឡើងនូវសំណួរទីពីរ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ទៅលើចំណុចនេះឲ្យបានច្បាស់ ។ យើងព្យាយាមធ្វើការស្វែងយល់ ថាតើលោកបានរៀបរាប់យ៉ាងច្រើនហើយទាក់ទងទៅនឹងគោលនយោបាយនិងឯកសារទាក់ទងទៅនឹងការសម្លាប់ ។ ហើយយើងព្យាយាមធ្វើការស្វែងយល់ថាតើវាមានការលើកឡើងអំពីគោលនយោបាយនៃការធ្វើទារុណកម្មដែរឬទេ? នេះជាសំណួរទីមួយរបស់ខ្ញុំ ។ នៅក្នុងការស្រាវជ្រាវរបស់លោក តើលោកបានជួបប្រទះសេចក្តីសម្រេចផ្សេងៗ ដែលចេញដោយគណៈអចិន្ត្រៃយ៍ទាក់ទងទៅនឹងការធ្វើទារុណកម្មដែរឬទេ? ឬក៏លោកយល់ឃើញថា ក្រោយពេល

គេប្រើពាក្យថាកម្ទេចនេះ គឺវាមានន័យទៅដល់ការលើកឡើងការធ្វើទារុណកម្មរួចហើយនោះ? តើលោកយល់ទៅនឹងសំណួររបស់ខ្ញុំច្បាស់ដែរឬទេ?

[០៩:១៧:០០]

**ផ៖** គឺខ្ញុំយល់ច្បាស់សំណួរនេះគឺបានបញ្ជាក់និងសួរយ៉ាងច្បាស់ ។ គឺខ្ញុំមិនដែលឃើញ ការចេញបញ្ជា ឬក៏ចេញសេចក្តីសម្រេចណាមួយពីគណៈអចិន្ត្រៃយ៍នោះទេ ដែលសេចក្តីសម្រេចនិងសេចក្តីបញ្ជានោះគឺបានបង្គាប់ឲ្យធ្វើការសួរ ធ្វើទារុណកម្ម ។ ប៉ុន្តែ យ៉ាងណាក៏ដោយ គឺវាបង្ហាញយ៉ាងច្បាស់ចេញពីការបោះពុម្ពផ្សាយរបស់បក្ស ហើយនិងការប្រកាសផ្សេងៗរបស់ជួរដឹកនាំថ្នាក់លើ គឺថាពួកគេ គឺពួកគេចង់ឲ្យធ្វើការប្រព្រឹត្តទៅលើបុគ្គលទាំងឡាយណាដែលគេយល់ឃើញថា និងរកឃើញថា ជាសត្រូវ ឬជាខ្មាំង ។

**ស៖** ខ្ញុំសូមបន្តទៅនឹងសំណួរនេះ ។ ជនជាប់ចោទនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ គឺទំព័រទី៦ បានលើកឡើងថា វាការធ្វើទារុណកម្មមានបួនយ៉ាង ។ ហើយគឺគាត់លើកឡើងថា វាជាការអនុញ្ញាត ហើយគឺខ្ញុំសូមបញ្ជាក់ទៅលើចំណុចនេះ ។ លោកដែលជួបប្រទះឃើញឯកសារដែលនាំឲ្យលោកជឿថា គឺថាវិធីនៃការធ្វើទារុណកម្មត្រូវបានអនុញ្ញាតបើសិនជាអនុញ្ញាតមែន តើអ្នកណាគេជាអ្នកអនុញ្ញាត?

**ផ៖** ខ្ញុំមិនដែលបានឃើញឯកសារទាំងឡាយណា ដែលចាត់ចេញមកពីខាងជួរដឹកនាំនៅក្នុងគណៈអចិន្ត្រៃយ៍ដែលអនុញ្ញាតឲ្យធ្វើការ ធ្វើទារុណកម្មនោះទេ ។ ប៉ុន្តែ យ៉ាងណាក៏ដោយយើងឃើញមានឯកសារជាច្រើនដែលយើងនិយាយថា វាជាសៀវភៅកំណត់សម្គាល់របស់កម្មាភិបាល ដែលសៀវ-ភៅទាំងអស់នោះសរសេរឡើងដោយបុគ្គលិកស-២១ ហើយសៀវភៅនោះ គឺបានកត់ត្រាអំពីខ្លឹមសារនៃការអប់រំនៅក្នុងស-២១ ។ ហើយសៀវភៅនោះហើយនិងការប្រជុំនោះ គឺបានរៀបរាប់និងពិភាក្សាអំពីវិធីសាស្ត្រនៃការធ្វើទារុណកម្ម។

**ស៖** ផ្អែកទៅលើការស្រាវជ្រាវរបស់លោក តើលោកយល់ ឃើញយ៉ាងម៉េចដែរថា តើនរណាគេជាអ្នកធ្វើការផ្តល់ជូន និងរៀបចំវិធីសាស្ត្រនៃការធ្វើទារុណកម្មនោះ?

**ផ៖** នេះជាសំណួរមួយគួរឲ្យចាប់អារម្មណ៍លោកមេធាវី ។ ហើយនេះជាសំណួរមួយដែលយើងមានការងឿយឆ្ងល់ដ៏ច្រើន ហើយនិងយូរកន្លងមកហើយ ។ សម្រាប់ខ្ញុំ ខ្ញុំហាក់ដូចជាយល់ថា បច្ចេកទេសធ្វើទារុណកម្មភាគច្រើនត្រូវបានអនុវត្តឡើងតាមការអនុវត្តជាក់ស្តែង ឬតាមបទពិសោធន៍ ដែល

បានរៀនសូត្រមកពីបក្សកុម្មុយនីស្តវៀតណាម ។ ហើយបន្ទាប់មកត្រូវបានផ្ទេរទៅឲ្យបុគ្គលិក សន្តិសុខនានា និងមន្ត្រីខ្មែរក្រហមជាន់ខ្ពស់ ដែលនេះគឺជាការនិយាយតាមមាត់តគ្នា ហើយបើសិនជាយើងជឿទៅលើសក្ខីកម្មផ្សេងៗរបស់បុគ្គលិកនៅស-២១ និងជនជាប់ទោសដែលនៅរស់រានមានជីវិត ពីមន្ទីរស-២១ នោះ គឺយើងប៊ានថាបច្ចេកទេសធ្វើទារុណកម្មច្រើនទម្រង់ ច្រើនបែបបទ ត្រូវបានគេអនុវត្តនៅទីនោះ ។ ហើយដែលបច្ចេកទេសធ្វើទារុណកម្មមួយចំនួនអាចជាលទ្ធផលនៃការកែច្នៃប្រឌិតរបស់បុគ្គលិកនៅស-២១ ផ្ទាល់ ។

**ស៖** តើលោកចង់និយាយអំពីបុគ្គលិកមួយណាដែរ?

**ឆ៖** នៅក្នុងករណីនេះ ខ្ញុំនិយាយអំពីអ្នកសួរចម្លើយនៅស-២១ ។

**ស៖** ហើយទៅតាមការយល់ដឹងរបស់លោកវិញ តើនរណាគេជាអ្នកបង្រៀនបច្ចេកទេសធ្វើទារុណកម្មដល់អ្នកសួរចម្លើយអស់ទាំងនោះ?

**ឆ៖** ខ្ញុំជឿថា ឌុច គឺជាគ្រូបង្គោលនៅក្នុងការបង្រៀនបច្ចេកទេសធ្វើទារុណកម្មនៅស-២១ ។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ តើលោកមានប្រភពអីដើម្បីធ្វើការសន្និដ្ឋានបែបនេះ?

**ឆ៖** ខ្ញុំជឿដូច្នេះ ដោយទៅលើសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទផ្ទាល់ នៅលើសេចក្តីថ្លែងការណ៍របស់គាត់ និងនៅលើសេចក្តីថ្លែងការណ៍របស់បុគ្គលិកមន្ទីរស-២១ និងឯកសារដែលនៅសល់ដែលយើងរកបានមកពីមន្ទីរស-២១ នោះ ។

**ស៖** សូមអរគុណ ។ ខ្ញុំដូចជាមិនច្បាស់សោះថា នៅពេលដែលយើងនិយាយអំពីការធ្វើទារុណ-កម្មប្រសិនបើមានការប្រើអំពើ ឬក៏ការធ្វើទារុណកម្មនៅតាមស្រុក តំបន់ ឬក៏ភូមិភាគនៅទូទាំងប្រទេសកម្ពុជានោះ នៅកថាខណ្ឌ៦៤ នៅក្នុងរបាយការណ៍របស់លោក លោកបាននិយាយថា បុគ្គលិកនៅតាមតំបន់ក៏មានអំណាចក្នុងការធ្វើទារុណកម្មអ្នកទោសផងដែរ ។ អ្វីដែលលោកទើបតែបាននិយាយប្រាប់ខ្ញុំមុននេះទាក់ទងទៅនឹងស-២១ នោះ តើមន្ទីរសន្តិសុខនានានៅខាងក្រៅភ្នំពេញអនុវត្តដូចគ្នាដែរ ឬក៏យ៉ាងណា?

**ឆ៖** សម្រាប់ខ្ញុំ ខ្ញុំយល់ច្បាស់ថា ដូច្នេះ ។ គឺការធ្វើទារុណកម្មត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅតាមមន្ទីរសន្តិសុខនានានៅទូទាំងផ្ទៃប្រទេស នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជានៅកន្លែងភាគច្រើន ដូចជា បានប្រើប្រាស់បច្ចេកទេសដែលមានទំហំតិចជាងបច្ចេកទេសដែលប្រើនៅស-២១ ។

**ស៖** អាន៎ុងហើយ គឺជាសំណួរបន្ទាប់របស់ខ្ញុំ ។

[០៩:២៥:00]

យោងទៅលើការស្រាវជ្រាវរបស់លោក តើមានភាពខុសគ្នាទេរវាងការអនុវត្តការធ្វើទារុណកម្ម នៅតាមមន្ទីរសន្តិសុខនានា នៅទូទាំងប្រទេស និងការអនុវត្តការធ្វើទារុណកម្មនៅស-២១ នោះ?

**ឆ៖** នេះគឺជាសំណួរមួយដ៏លំបាកលោកមេធាវី ។ ទាក់ទងទៅហ្នឹង ការឈឺចាប់ ឬក៏ក្ដីរន្ធត់ ដែលបានធ្វើឡើងទៅលើជនរងគ្រោះដែលត្រូវទទួលទារុណកម្មនោះ គឺប្រហែលជាមិនមានភាពខុសគ្នា នោះទេ ។ មានន័យថា រវាងការធ្វើទារុណកម្មនៅស-២១ និងការអនុវត្តការធ្វើទារុណកម្មនៅតាមមន្ទីរ សន្តិសុខនានាដទៃទៀត ។ ក៏ប៉ុន្តែ ទាក់ទងទៅនឹងប្រភេទផ្សេងៗគ្នានៃបច្ចេកទេសនៃការធ្វើទារុណកម្ម គឺថាអាចមានភាពផ្សេងគ្នា ។

**ស៖** តើលោកអាចពន្យល់ឲ្យបានពិស្ដារជាងនេះបន្តិចទៀតទេ?

**ឆ៖** បាទ, ពិតជាបានលោកមេធាវី ។ នៅមន្ទីរសន្តិសុខភូមិភាគ និងមន្ទីរសន្តិសុខដែលមាននៅ ថ្នាក់ក្រោមកដទៃទៀត ប្រភេទផ្សេងៗនៃបច្ចេកទេសធ្វើទារុណកម្ម ដែលជាទូទៅទោះបីជាមិនមាន លក្ខណៈទូលំទូលាយក៏ដោយ ដូចជាកម្រិតត្រឹមការវាយ ការវាយនឹងខ្សែតី ការច្រកថង់ប្លាស្ទិកឲ្យថប់ ដង្ហើម និងការឆក់ខ្សែភ្លើង ។ ផ្ទុយពីនេះ នៅស-២១ វិញ ស-២១ហាក់ដូចជាប្រើប្រភេទផ្សេងៗនៃ បច្ចេកទេសធ្វើទារុណកម្មបន្ថែមទៀត ដូចជា ការអុច ដុត ការចាក់ក្រចកដៃ ម្រាមដៃ ម្រាមជើង ការ ដកក្រចកដៃ ក្រចកជើង និងការគាបស្បែក ហើយចាក់ទឹកអំបិលទៅលើស្នាមរបួសនោះ ការឲ្យសត្វ ដែលមានពិសខាំ និងទម្រង់ផ្សេងៗទៀតនៃការធ្វើទារុណកម្មដោយប្រើទឹក ការចងដៃទៅក្រោយខ្នង ហើយលើកដៃរបស់ជនរងគ្រោះនោះឡើង ដើម្បីឲ្យដៃនុំងឯងមានការផ្ដោះនូវចន្លោះស្មា ហើយនិងមាន ទម្រង់ផ្សេងៗទៀតនៃការធ្វើឲ្យមានការឈឺចាប់បែបនេះ ។

**ស៖** សូមអរគុណ ។ ចម្លើយរបស់លោក គឺជាការឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំទាក់ទងទៅ នឹងការធ្វើទារុណកម្ម ។ ឥឡូវនេះ ខ្ញុំមានសំណួរចំនួនទាក់ទងទៅចម្លើយសារភាព ខ្ញុំបានយល់ដឹងហើយ អំពីសេចក្ដីសម្រេចដែលបានធ្វើពីមុនមក ដូច្នេះខ្ញុំនឹងមិនសួរអំពីអត្ថបទនៃចម្លើយសារភាពមួយចំនួននោះ ទេ ។ ប៉ុន្តែ ខ្ញុំព្យាយាមយល់ដឹង--

**លោក អាឡិចសាន់ឌឺ ប៊េត៖**

ខ្ញុំសូមទោសដែលខ្ញុំឡើងកាត់ ។ លោក វ៉ែនណឺ បាននិយាយសេចក្ដីសម្រេចរបស់អង្គសវនាការ

ទាក់ទងទៅនឹងភស្តុតាងនេះ ទៅតាមការយល់ដឹងរបស់សហព្រះរាជអាជ្ញា គឺថាមិនទាន់មានសេចក្ដីសម្រេចពីអង្គសវនាការនៅឡើយទេទៅលើភស្តុតាងនេះ ។ ដូច្នេះ ខ្ញុំចង់ដឹងថា តើលោក លោកស្រីចៅក្រមហ្នឹង បានធ្វើសេចក្ដីសម្រេចទាក់ទងនឹងភស្តុតាងនេះហើយឬនៅ?

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៩:២៧]

**ប្រធានអង្គជំនុំ៖**

ឆ្លើយតបទៅនឹងការកត់សម្គាល់នូវការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អំពីអម្បិញមិញនេះ អង្គជម្រះសូមរំឭកអំពីដែលអង្គជម្រះបានសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាកាលពីសប្ដាហ៍កន្លងទៅដូចខាងក្រោមនេះ៖

អង្គជំនុំជម្រះសូមរំឭកដល់ភាគីទាំងអស់ថា មាត្រា១៥ នៃអនុសញ្ញាស្ដីពីការហាមឃាត់ ការធ្វើទារុណកម្មបានចែងថា "ភាគីរដ្ឋត្រូវធានាថា ឯកសាររបាយការណ៍ទាំងឡាយដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសំអាងជាធាតុនៃភស្តុតាងក្នុងនីតិវិធីណាមួយឡើយ ដែលបានធ្វើឡើងដោយសារការធ្វើទារុណកម្ម លើកលែងតែឯកសាររបាយការណ៍នោះត្រូវបានធ្វើឡើងសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពីទារុណកម្ម" ។ នេះគឺជាការរំឭកដល់ភាគីពាក់ព័ន្ធនឹងការប្រើប្រាស់នូវឯកសារទាំងឡាយដែលជាលទ្ធផលនៃការធ្វើទារុណកម្ម វាធៀបទៅនឹងអនុសញ្ញាអន្តរជាតិស្ដីពីការហាមឃាត់ការធ្វើទារុណកម្ម នៅក្នុងប្រើប្រាស់ឯកសារ ឬភស្តុតាងនេះ នៅក្នុងកិច្ចនីតិវិធី ។ នៅក្នុងបទប្បញ្ញត្តិជាច្រើននៃកម្ពុជាបច្ចុប្បន្ន ក៏បានទទួលយកនូវអនុសញ្ញានេះ ពីព្រោះប្រទេសកម្ពុជាជាភាគីហត្ថលេខីនៃអនុសញ្ញាអន្តរជាតិស្ដីពីការហាមឃាត់ធ្វើទារុណកម្មនេះផងដែរ ។ ពីម្សិលមិញ ក៏មានការជជែកពិភាក្សាគ្នាអំពីបញ្ហានេះ រវាងចៅក្រមនៅក្នុងក្រុមនៃអង្គជំនុំជម្រះសាលាដំបូងដែរ ដោយកត់សម្គាល់លើបញ្ហានៃការសួរដេញដោលមានបញ្ហាដែលត្រូវការកត់សម្គាល់នោះ ។ ប៉ុន្តែ ដោយសារហេតុមានបញ្ហាជាច្រើន នៅក្នុងនោះមានបញ្ហាមួយចំនួនទៀតពាក់ព័ន្ធជាមួយនឹងរឿងក្ដីទីពីរផង ។ អ៊ីចឹងអង្គជំនុំជម្រះមិនទាន់បាននឹងឈានដល់ថា ចេញសេចក្ដីសម្រេចទេ សូមឲ្យមានការកត់សម្គាល់ដល់គូភាគីដូច្នេះ ។ ហើយដើម្បីឲ្យចង់បានច្បាស់ពីបញ្ហានេះនូវអ្វីដែលជាលទ្ធផលនៃអង្គជំនុំជម្រះបានជជែកពិភាក្សាគ្នាពីម្សិលមិញនិងព្រឹកមិញនេះ ពាក់ព័ន្ធជាមួយនឹងការអនុវត្តអនុសញ្ញាអន្តរជាតិស្ដីពីទារុណកម្មនេះ គឺអង្គជំនុំជម្រះ គឺយើងខ្ញុំសូមប្រគល់នាទីជូនទៅលោកស្រីចៅក្រម ដើម្បីជម្រាបជូនដល់

អង្គសវនាការអំពីបញ្ហានេះ ដែលមានលក្ខណៈជាការកត់សម្គាល់ជាបណ្ដោះអាសន្ន មិនទាន់ជាសេចក្ដីសម្រេចជាផ្លូវការនៅឡើយទេ ។

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ដូចដែលលោកប្រធានបានជម្រាបហើយ អង្គសវនាការបានពិចារណាលើបញ្ហានេះ ហើយនៅពេលនេះ គឺចង់ធ្វើការបំភ្លឺឲ្យបានច្បាស់លើអ្វីដែលយើងបានចង្អុលបង្ហាញកាលពីប៉ុន្មានថ្ងៃមុន ។ អង្គសវនាការចង់បញ្ជាក់អំពីសារសំខាន់នៃអង្គហេតុដែលថា សវនាការនេះ គឺត្រូវគោរពមាត្រា១៥ នៃអនុសញ្ញាស្ដីពីការធ្វើទារុណកម្ម ដែលលោកប្រធានទើបតែអានអម្បាញ់មិញនេះ ។ បទប្បញ្ញត្តិនេះ គឺបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ហើយក៏បានឆ្លុះបញ្ចាំងនៃវិធាន២១.៣ នៃវិធានផ្ទៃក្នុងដែលបានចែងថា “មិនមានទម្រង់នៃការបង្ខិតបង្ខំលើរូបរាងកាយ ឬក៏ការគំរាមកំហែងណាមួយ មិនថាធ្វើឡើងដោយផ្ទាល់ចំពោះអ្នកត្រូវបានគេសម្ភាស ឬក៏អ្នកដែលផ្សេងៗទៀត មិនត្រូវបានយកមកប្រើប្រាស់ឡើយ ។ ហើយបើសិនជាការបង្ខំ ឬក៏ការគំរាមកំហែងនោះត្រូវបានប្រើប្រាស់ ចម្លើយដែលបានកត់ត្រានោះ គឺមិនអាចទទួលយកបានជាភស្តុតាងនៅចំពោះអង្គសវនាការនោះទេ” ។ ក្នុងការអនុវត្ត ចំណុចនេះមានន័យថា ចម្លើយសារភាពដែលបានធ្វើឡើង ហើយបានធ្វើឡើងក្រោមការធ្វើទារុណកម្មនោះ គឺជាអង្គហេតុដែលទទួលយកបាន ។ ប៉ុន្តែខ្លឹមសារនៃការសារភាព ដែលធ្វើឡើងដោយទារុណកម្មនោះ គឺមិនអាចយកមកធ្វើការទទួលយកបានថាវាជាចម្លើយមួយដែលពិតប្រាកដនោះទេ ។ ប្រសិនបើភាគីណាមួយចង់លើកឡើងអំពីភាពពិតប្រាកដ ឬក៏ខ្លឹមសារនៃចម្លើយសារភាពទាំងអស់នោះ វាជាការចាំបាច់ក្នុងការបង្ហាញជាមុនឲ្យឃើញថា ប្រសិនបើចម្លើយសារភាពត្រូវបានធ្វើឡើងដោយមានទារុណកម្ម ឬក៏ដោយមានការគំរាមកំហែង នៃអំពើទារុណកម្ម ដោយសារមូលហេតុនេះ ភាគីគួរតែពិចារណា ថាតើការពិនិត្យទៅលើខ្លឹមសារនៃចម្លើយសារភាពទាំងអស់នោះ គឺវាគ្រប់គ្រាន់ ហើយមានសារសំខាន់ពេញលេញក្នុងការសួរទៅលើលក្ខខណ្ឌ ឬក៏ស្ថានភាពមួយចំនួនដែលចម្លើយសារភាពនោះត្រូវបានធ្វើឡើង ។ ខ្ញុំលើកឡើងបញ្ជាក់នូវអ្វីដែលលោកប្រធានបានជម្រាប ។ ចំណុចនេះ វាអាចជួយទៅដល់ភាគីទៅលើការបំភ្លឺមួយចំនួន ។ ចំពោះការចែងនៅក្នុងមាត្រា១៥នៃអនុសញ្ញាស្ដីពីការធ្វើទារុណកម្ម ។ សូមអរគុណលោកប្រធាន ។

[០៩:៤៦:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអរគុណលោកប្រធាន សូមអរគុណលោកស្រីចៅក្រម ដែលបានបំភ្លឺ ។ យើងខ្ញុំមានសេចក្ដីសង្កេតមួយ ដើម្បីឲ្យយើងបានស្វែងយល់ឲ្យបានច្បាស់លាស់នូវអ្វីដែលលោកស្រីចៅក្រមទើបតែបានជម្រាបនេះ ។ ទោះបីជាគ្មានសេចក្ដីសម្រេចទៅលើគោលការណ៍ទូទៅក៏ដោយ ប្រសិនបើខ្ញុំយល់ទៅលើយោបល់របស់លោកស្រីចៅក្រមត្រឹមត្រូវនោះ គឺនៅពេលដែលភាគីគាត់ព្យាយាមផ្អែកទៅលើខ្លឹមសារនៃចម្លើយសារភាពតែប៉ុណ្ណោះ ដែលថា បញ្ហានេះត្រូវបានលើកឡើងដោយពេញលេញ ។

ប្រសិនបើខ្ញុំយល់ច្បាស់ដូច្នេះ គឺយើងនឹងមិនលើកឡើងបញ្ហានោះទេ ។ ប៉ុន្តែ សហព្រះរាជអាជ្ញាគឺសូមធ្វើការរំឮកអង្គសវនាការថា បញ្ហានេះគឺជាបញ្ហាដែលបានលើកឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅក្នុងរឿងក្ដីទីពីរ ហើយវាជាបញ្ហាមួយពិបាក ហើយនិងជាបញ្ហាមួយប្រសើរ ។ ហើយប្រសិនបើមានការពិភាក្សាទូទៅធ្វើអំពីគោលការណ៍ទូទៅនៅក្នុងអង្គសវនការនេះ គឺសហព្រះរាជអាជ្ញាគឺសុំទាក់សេចក្ដីសន្និដ្ឋានពេញលេញទៅលើបញ្ហានៃភាពរសើបនៃចំណុចនេះ ។ ហើយប្រសិនបើមានការយល់ព្រមពីអង្គសវនាការ គឺសហព្រះរាជអាជ្ញា សូមលើកឡើងថា នៅពេលនេះគឺយើងអត់ទាន់មានគោលការណ៍ទូទៅណាមួយបញ្ជាក់ទៅលើចំណុចនេះនោះទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ខាតរ៉ាយថ៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ គឺចំពោះបញ្ហានេះ បញ្ហាដែលមាននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតចំពោះសំណុំរឿងលេខពីរ គឺយើងមិនមានឃើញសេចក្ដីសម្រេចណាមួយសម្រេចទៅលើបញ្ហានេះទេ ប៉ុន្តែវាបង្ហាញយ៉ាងច្បាស់ថា យើងនៅក្នុងដំណាក់កាលនេះ វាមានភាពចាំបាច់ក្នុងការបំភ្លឺទៅលើបញ្ហានេះ ដើម្បីជាប្រយោជន៍ទៅដល់ភាគី ដើម្បីនៅក្នុងរឿងក្ដីនីមួយៗនោះ គឺយើងអាចដោះស្រាយទៅលើបញ្ហានេះបានប្រសិនបើវាកើតឡើង ។ ដូច្នេះ ភាគីអាចពិចារណាចំណុចនេះ ថាវាមានសារសំខាន់យ៉ាងម៉េច នៅពេលដែលយើងយោងទៅលើខ្លឹមសារនៃចម្លើយសារភាព ដោយសារតែអង្គ

សវនាការយល់ឃើញថា វាជាករណីដែលត្រូវធ្វើឡើងទៅតាមរឿងក្តីនីមួយៗ ហើយការពិនិត្យទៅលើស្ថានភាពផ្សេងៗនៃចម្លើយសារភាពដែលបានធ្វើឡើង ។

អង្គសវនាការកត់សម្គាល់លើសេចក្តីសន្និដ្ឋានរបស់លោក គឺយើងត្រូវការសេចក្តីដ្ឋានទាំងស្រុងនៅដំណាក់កាលក្រោយ ហើយយើងទុករក្សាសិទ្ធិនេះចំពោះភាគី ។ ខ្ញុំគិតថា អ្វីដែលខ្ញុំបានលើកឡើងនឹងផ្តល់ជាការបំភ្លឺដល់សហព្រះរាជអាជ្ញា ។

[០៩:៥០:០៧]

**លោក អាឡិចសាន់ឌឺ ប៊េត៖**

គឺវាបានបំភ្លឺយ៉ាងច្រើនចំពោះខ្ញុំ ទៅលើចំណុចនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី អាឡាំង វ៉ែនណឺ បន្តសំណួរពាក់ព័ន្ធជាមួយនឹងអ្នកជំនាញ ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន សូមអភ័យទោសដែលខ្ញុំប្រើប្រាស់ភាសាខ្ញុំលឿនពេក ។ លោកអេតឆេសាន់ គឺលោកបានលើកឡើងអំពីការធ្វើទារុណកម្ម គឺខ្ញុំសូមលើកឡើងដូចគ្នាទៅលើចម្លើយសារភាព ហើយមានន័យថា ប្រសិនបើវាមានគោលនយោបាយដាក់លាក់ទៅលើចម្លើយសារភាពនោះថាតើគោលនយោបាយលើចម្លើយសារភាពនោះវាមានន័យយ៉ាងម៉េច? ខ្ញុំសូមផ្តល់ទៅលើចំណុចមួយចំនួនទាក់ទងទៅនឹងអ្វីដែលបានលើកឡើង។ មុនពេលដែលលោកបានផ្តល់សក្ខីកម្មកាលពីថ្ងៃច័ន្ទ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ អង្គហេតុដែលបានយល់ព្រមព្រៀងគ្នា ត្រូវបានអាន ហើយជនជាប់ចោទផ្តល់ឱកាសឲ្យផ្តល់យោបល់ទៅលើអង្គហេតុដែលបានព្រមព្រៀងគ្នាទាំងអស់នោះ ។ គាត់បានលើកឡើងថា នៅក្នុងអង្គហេតុដែលបានព្រមព្រៀងគ្នា កថាខណ្ឌ៩៩ គឺសម្រាប់ឲ្យលោក អេតឆេសាន់ធ្វើការស្វែងយល់នៅក្នុងទំព័រទី៥៩ ដែលនៅក្នុងសវនាការថ្ងៃទី១៨ ។ អង្គហេតុនោះ គឺដូចលើកឡើងដូចខាងក្រោម៖

[០៩:៥២:០១]

ឌុច បានផ្តល់ការបង្គាប់ទៅលើការប្រមូល ឬក៏ការប្រមូលចម្លើយសារភាពទាក់ទងទៅនឹងភ្នាក់ងារ *ស៊ីអាយអេ* និង *កាហ្សេបេ* ។ ហើយនៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌ៤៤ជនជាប់ចោទយល់ព្រម ហើយសហព្រះរាជអាជ្ញាបានធ្វើការសង្ខេបទៅលើដីកាដំណោះស្រាយ កថាខណ្ឌ៤៤។

កថាខណ្ឌ៤៤ នៃដីកាដំណោះស្រាយបានលើកឡើងថា ឌុច បានលើកឡើងនៅក្នុងករណីជាច្រើន គឺគាត់បានផ្តល់យោបល់និងការណែនាំទាក់ទងទៅនឹងការទាញចម្លើយសារភាព និងខ្លឹមសារនៃចម្លើយសារភាពជាក់លាក់ ហើយជាពិសេសជនជាប់ចោទបានលើកឡើងថា វាមានការលើកឡើងពីដំបូងអំពី *ស៊ីអាយអេ* ហើយនិង *កាហ្សេបេ* នៅក្នុងខ្លឹមសារនៃចម្លើយសារភាព ។ សំណួររបស់ខ្ញុំគឺតាមអ្វីដែលលោកដឹងតាមការស្រាវជ្រាវរបស់លោក ។

**ស៖** លោកអាចនិយាយបានទេថា គឺមានគោលនយោបាយត្រូវបានសរសេរឡើងអំពីរបៀបនៃការទាញចម្លើយសារភាព? ឬក៏វាមានការណែនាំដោយផ្ទាល់មាត់ទាក់ទងទៅនឹងការទាញយកចម្លើយសារភាពដែរឬទេ?

[០៩:៥៣:៣០]

**ផ៖** បាទ, មេធាវី គឺសំណួរនេះសួរយ៉ាងច្បាស់ ។ ខ្ញុំគួរតែនិយាយថា គឺមានការណែនាំទាំងលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់ ទាក់ទងទៅនឹងការទាញយកចម្លើយសារភាព ។ សេចក្តីណែនាំជាលាយលក្ខណ៍អក្សរជាច្រើនដែលយើងបានដឹង គឺវាជាសេចក្តីណែនាំផ្ទៃក្នុងនៅក្នុងស-២១ ជាជាងវាមិនមែនជាសេចក្តីសម្រេច ឬណែនាំមកពីថ្នាក់លើនោះទេ ហើយវាក៏បានបង្ហាញយ៉ាងច្បាស់ផងដែរថា ការអនុវត្តចំពោះការធ្វើទារុណកម្មនៅស-២១ ហើយតាំងពីដំបូងមក គឺនៅមន្ទីរម-១៣ គឺវាពាក់ព័ន្ធ និងវិវឌ្ឍន៍ពីពេលមួយទៅពេលមួយស្របទៅនឹងវិធីសាស្ត្រនៃការទាញចម្លើយសារភាពជាក់លាក់មួយចំនួន ។

[០៩:៥៥:០០]

**ស៖** នៅពេលដែលលោកនិយាយថា សេចក្តីណែនាំដោយជាលាយលក្ខណ៍អក្សរនៅក្នុងស-២១ វាន័យថា តាមការយល់របស់ខ្ញុំនោះ គឺជនជាប់ចោទគាត់បានសម្រេចទៅលើការបង្កើតសេចក្តីណែនាំសម្រាប់ប្រើប្រាស់ផ្ទៃក្នុងនោះឬយ៉ាងម៉េច? នេះជាការយល់ឃើញរបស់ខ្ញុំត្រឹមត្រូវដែរឬទេ?

**ផ៖** គឺត្រឹមត្រូវ ។

**ស៖** តើចំពោះសេចក្តីណែនាំដោយផ្ទាល់មាត់នោះយ៉ាងម៉េចដែរ? តើគេបានលើកឡើងអំពីសេចក្តីណែនាំផ្ទាល់មាត់នោះ អំពីរបៀបទាញយកចម្លើយយ៉ាងម៉េចដែរ?

**ផ៖** ជនជាប់ចោទ នៅពេលមួយចំនួនបាននិយាយនៅក្នុងការសួរចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលគាត់ទទួលបានការណែនាំដោយផ្ទាល់មាត់ ស្តីអំពីវិធីនៃការធ្វើទារុណកម្ម និងការធ្វើទារុណកម្ម វិធីនៃការទាញចម្លើយសារភាព ហើយនិងអំពីខ្លឹមសារនៃចម្លើយសារភាពដែល

គេចង់បាន ។ យើងក៏មានឃើញភស្តុតាងនៅក្នុងសំណុំរឿង ដែលជនជាប់ចោទគឺបានបញ្ជូនសេចក្ដីណែនាំដោយផ្ទាល់មាត់នោះទៅអ្នកសួរចម្លើយរបស់ខ្លួន ដែលសេចក្ដីណែនាំនោះទាក់ទងទៅនឹងទម្រង់នៃការធ្វើការសួរចម្លើយ និងការទាញយកខ្លឹមសារនៃចម្លើយសារភាពដែលគេចង់បាន ។

**ស៖** សូមអរគុណ ។ អ្វីដែលខ្ញុំសួរអំពីចម្លើយសារភាពនិងការធ្វើទារុណកម្មនោះ គឺដូចគ្នាដែរ គឺថា ចម្លើយសារភាព គឺវាមានលក្ខណៈពិសេសនៅស-២១ ឬក៏វាធ្វើឡើងដូចគ្នាដែរនៅក្នុងផ្ទៃក្នុងតាមមូលដ្ឋាន? គឺទាក់ទងទៅនឹងចម្លើយសារភាព គឺត្រូវបានគេធ្វើឡើងនិងទាញចេញនៅតាមភូមិភាគតំបន់ ឬក៏តាមស្រុកអីផ្សេងៗដែរ ឬក៏វាធ្វើឡើងនៅតែស-២១?

**ឆ៖** បាទ, លោកមេធាវី! ចម្លើយសារភាពគឺគេប្រមូលនៅតាមមន្ទីរសន្តិសុខផ្សេងៗ ដែលមាននៅតាមថ្នាក់ជួរផ្សេងៗ នៅតាមភូមិភាគ នៅតាមតំបន់ និងនៅតាមស្រុក ។ នៅក្នុងករណីមួយចំនួនដែលយើងបានដឹង ចម្លើយសារភាពនោះប្រមូលបាននៅតាមមន្ទីរសន្តិសុខថ្នាក់ទាបៗ ហើយវាមានការរៀបរាប់ពិស្ដារទៅលើចម្លើយសារភាពទាំងអស់នោះ ។

យើងឃើញមានកំណត់ហេតុកត់ត្រាទុកដែលនៅសល់ចំពោះសកម្មភាពទាំងអស់នេះ ហើយយើងផ្អែកទៅលើសក្ខីកម្មរបស់អ្នកប្រព្រឹត្តមួយចំនួន ឬក៏សក្ខីកម្មរបស់អ្នកដែលរស់រានមានជីវិត ដែលយើងអាចស្វែងយល់អំពីប្រតិបត្តិការនៅក្នុងភូមិភាគ តំបន់ និងស្រុក និងតាមមន្ទីរសន្តិសុខផ្សេងៗ ។

[០៩:៥៨:៥៨]

ប៉ុន្តែ ផ្អែកទៅលើភស្តុតាងទាំងអស់នោះ គឺវាបង្ហាញចំពោះខ្ញុំយ៉ាងច្បាស់ថា ចម្លើយសារភាពនិងការសួរចម្លើយដែលបានបង្កើតឡើងនៅស-២១ គឺវាមានលក្ខណៈពិស្ដារ និងរៀបរាប់យ៉ាងហ្មត់ចត់ ហើយវាធ្វើឡើងយ៉ាងល្អជាជាងមន្ទីរសន្តិសុខផ្សេងៗទៀត ។

**ស៖** តើលោកអាចពន្យល់បន្ថែមទេ ហេតុអ្វីបានជាចម្លើយសារភាពនៅស-២១ វាមានលក្ខណៈពិស្ដារ និងរៀបចំបានហ្មត់ចត់ជាងនៅទីកន្លែងផ្សេងៗ?

**ឆ៖** បាន ខ្ញុំអាចរៀបរាប់បាន ។ មូលហេតុមួយដែលថា ចម្លើយសារភាពវាមានលក្ខណៈរៀបរាប់ពិស្ដារនៅស-២១នោះ គឺវាទាក់ទងទៅនឹងលក្ខណៈនៃបុគ្គលិកដែលគាត់ជាអ្នកសួរចម្លើយ។ បុគ្គលិកមួយចំនួនជាច្រើនទាំងអស់នោះគឺជាយុទ្ធជនបដិវត្តន៍ ដែលគាត់បានបម្រើបដិវត្តន៍អស់ច្រើនទសវត្សរ៍មកហើយ ហើយអ្នកទាំងអស់នោះគាត់បានទទួលបានឋានៈខ្ពស់នៅក្នុងជួរបដិវត្តន៍ ហើយគាត់ត្រូវបានគេតែងតាំងរួមជាមួយអ្នកដទៃទៀត ហើយត្រូវបានតែងតាំងក្នុងឋានៈខ្ពស់នៅក្នុងអង្គការបដិវត្តន៍ ឬក៏

អ្នកទាំងអស់នោះ គឺគាត់ត្រូវបានគេជ្រើសរើសៗដោយផ្ទាល់អ្នកដែលចង់ចូលបដិវត្តន៍ ។ ហើយជាធម្មតានោះ បុគ្គលទាំងអស់នោះ គឺគាត់មានចំណុចមួយចំនួន ដែលគាត់អាចធ្វើការពិភាក្សា និងលើកឡើងនៅក្នុងចម្លើយសារភាព ហើយវាអាចជាចំណាប់អារម្មណ៍ទៅដល់បុគ្គលទាំងឡាយដែលចង់បានចម្លើយសារភាព ។ យើងឃើញមានចម្លើយសារភាពមួយចំនួននៅស-២១ ដែលបានប្រមូលឡើងនៅក្នុងអំឡុងពេលរយៈពេលជាច្រើន ហើយបានធ្វើឡើងក្នុងរយៈពេលយូរ ។ ហើយចម្លើយសារភាពមួយចំនួនវាលើសពីមួយពាន់ទំព័រទៅទៀត ។ ហើយគឺមិនមានអ្វីប្រៀបធៀបបានទៅនឹងចម្លើយសារភាពដែលធ្វើឡើងនៅក្នុងមន្ទីរផ្សេងៗនោះទេ ។

**ស៖** សូមអរគុណ ។ តើលោកមានបានដឹងអំពី--

**លោក ហ្វ្រង់ស្វ័រ រូ៖**

យើងបានទទួល នៅក្នុងការបកប្រែជាភាសាបារាំងមានបញ្ហាមួយចំនួន នៅពេលដែលលោកនិយាយថា ហេតុផលមួយដែលភ្ជាប់ទៅនឹងប្រភពមនុស្សអស់ទាំងហ្នឹង ដែលជាអ្នកសួរចម្លើយនោះ តើយើងនិយាយអំពីអ្នកសួរចម្លើយ ឬក៏អ្នកទោស?

[០៩:០២:៣៤]

បន្ទាប់មកទៀត លោកបាននិយាយអំពីអ្នកទោសដែលជាអតីតអ្នកធ្វើបដិវត្តន៍ដ៏យូរលង់ណាស់មកហើយ ។ ដូច្នេះ ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ទៅលើចំណុចនេះ ។ ដូច្នេះ បើសិនជាមានការខុសទាស់នោះ គឺយើងសូមធ្វើការកែប្រែទៅលើការបកប្រែជាភាសាបារាំងនោះ ពីព្រោះអ្នកខ្លះគឺជាអតីតអ្នកធ្វើបដិវត្តន៍ជាច្រើនទសវត្សរ៍មកហើយនោះ ។ សូមអរគុណ ។

**សួរដោយលោក អាឡាំង វែនណឺ៖**

ដោយសារខ្ញុំស្តាប់ជាភាសាអង់គ្លេស ដូច្នេះខ្ញុំមិនប្រាកដដែរ ។ មានអ្នកខ្លះថាឲ្យខ្ញុំគួរតែសួរជាភាសាបារាំងទៅ តែខ្ញុំមិនបានសួរទេ ។ សូមអរគុណ ។ ឥឡូវនេះខ្ញុំនិយាយបកមកត្រឡប់មកសំណួររបស់ខ្ញុំវិញ ។

**ស៖** នៅពេលដែលលោកធ្វើការស្រាវជ្រាវ តើលោកមានបានដឹងអំពីការធ្វើចំណារនៅ ស-២១ នោះយ៉ាងម៉េចដែរ? ឥឡូវនេះខ្ញុំនិយាយអំពីនៅថ្នាក់មូលដ្ឋាន តើលោកមានបានដឹងអំពីចំណារទៅលើចម្លើយសារភាពនៅថ្នាក់មូលដ្ឋានដែរឬទេ?

**ឆ៖** បាទ, ខ្ញុំបានដឹង ។

**សះ** តើលោកអាចនិយាយបន្ថែមបានទេ ទាក់ទងទៅនឹងចំណារលើចម្លើយសារភាពនោះ?

**ឆះ** លោកមេធាវី ខ្ញុំអាចនិយាយថា ចំណារទៅលើចម្លើយសារភាពនោះគឺមាន ការអនុវត្តបែបនេះក៏កើតមានឡើងដែរ នៅថ្នាក់កម្រិតទាបនៅតាមមន្ទីរសន្តិសុខនានា ។ ហើយការធ្វើចំណារគឺថាវាមិនមែនមិនមានពិស្ដារដូចដែលជាចំណារដែលយើងបានដឹងនៅក្នុងបរិបទនៃស-២១នោះទេ ។ ក៏ប៉ុន្តែខ្ញុំគិតថា ខ្ញុំមិនអាចនិយាយឲ្យបានលើសនេះទេ ពីព្រោះឯកសារដែលយើងនិយាយនោះ គឺជាអត្ថបទឯកសារទាក់ទងទៅនឹងការស៊ើបអង្កេតដែលកំពុងតែបន្ត ។

**សះ** សូមអរគុណ ។ ឥឡូវនេះយើងនិយាយអំពីចម្លើយសារភាពនៅស-២១ ម្សិលមិញលោកបាននិយាយថា គឺថាយើងអត់មានប្រតិចារឹកទេ ដូច្នេះ ខ្ញុំមិនអាចដកស្រង់សម្ដីពិតប្រាកដរបស់លោកបានទេ ហើយនៅពេលដែលខ្ញុំមានប្រតិចារឹកនោះ គឺថាខ្ញុំអាចនឹងធ្វើការលើកឡើងឲ្យបានច្បាស់លាស់នូវសម្ដីលោកនិយាយ ។

[១០:០៥:៣២]

បើសិនជាខ្ញុំយល់ខុសសូមប្រាប់ខ្ញុំផង ។ កាលពីម្សិលមិញ និងម្សិលម៉្ងៃ លោកបាននិយាយអំពីដែលបានកើតឡើងនៅស-២១។ លោកបាននិយាយថា ជនជាប់ចោទបានសិក្សាទៅលើចម្លើយសារភាព ហើយនៅពេលជាច្រើនលោកបាននិយាយអំពីបញ្ជីខ្មាំង ហើយម្សិលមិញលោកក៏បានប្រើពាក្យរកមើលខ្មាំង ។ ហើយខ្ញុំដូចជាមានការភ័ន្តច្រឡំបន្តិច នៅពេលដែលលោកនិយាយអំពីបញ្ជីខ្មាំងដែលគេស្នើឡើងនោះ តើលោកនិយាយអំពីចំណារនៅលើចម្លើយសារភាព ឬក៏និយាយអំពីចំណុចផ្សេងពីនេះ?

**ឆះ** នេះគឺជាចំណុចផ្សេងៗច្រើនគ្នា លោកមេធាវី ។ នៅក្នុងដំណើរការនៃការដកស្រង់ទាញយកចម្លើយសារភាព ជនរងគ្រោះនៅស-២១ ជាប្រចាំត្រូវបានគេឲ្យធ្វើបញ្ជីឈ្មោះនៃបុគ្គល ដែលគិតថាបានរួមគំនិតជាមួយពួកគេនៅក្នុងការលើកឡើងអំពីសកម្មភាពក្បត់របស់ពួកគេនោះ ។ នេះគឺជាប្រភេទមួយនៃបញ្ជីឈ្មោះ ដែលជនដែលត្រូវបានគេសួរចម្លើយនោះ បានធ្វើឡើង ។ នៅបណ្ណសារនៅស-២១ យើងក៏រកឃើញផងដែរនូវបញ្ជី គឺបញ្ជីខ្មាំងដែលគេស្នើឡើង ដែលត្រូវបានបង្កើតឡើងដោយអ្នកសួរចម្លើយ ឬមួយដោយបុគ្គលិកនៅស-២១ ដទៃទៀត ។ តាមរយៈដំណើរការនៃការវិភាគទៅលើចម្លើយសារភាព ដែលបានធ្វើរួចមកហើយនោះ ។ ដូច្នេះ នេះគឺជាប្រភេទមួយទៀត នៃបញ្ជីឈ្មោះដែលបានធ្វើឡើងដោយបុគ្គលិក មិនមែនដោយជនរងគ្រោះនោះទេ ។

**ស៖** តើលោកយល់យ៉ាងដូចម្ដេចដែរទៅលើចំណុចដែលថា នរណាម្នាក់ដែលបានបញ្ជាបញ្ជីឈ្មោះ ដែលគេចាត់ទុកថា បញ្ជីខ្មាំងដែលត្រូវបានសរសេរដោយអ្នកសួរចម្លើយ ហើយនិងដោយអ្នកដែលជាបុគ្គលិកនោះ? តើលោកមានបានដឹងអ្វីទេ? នរណាគេជាអ្នកបញ្ជាឲ្យធ្វើបញ្ជីឈ្មោះបែបនេះ?

**ឆ៖** លោកមេធាវី ខ្ញុំមិនអាចនឹកឃើញភ្លាមៗទេ ថាខ្ញុំបានឃើញបញ្ជាបែបនេះទេ គឺបញ្ជាដើម្បីឲ្យធ្វើបញ្ជីបែបនេះ ក្រៅពីបញ្ជាៗផ្ទាល់ទៅលើជនរងគ្រោះ ឬក៏អ្នកទោសជាក់លាក់ណាមួយនោះ។ ការយល់ដឹងរបស់ខ្ញុំគឺថា នេះគឺជាការអនុវត្តដែលបានកើតមានឡើង ហើយដែលត្រូវបានកែសម្រួលដោយជនជាប់ចោទខ្លួនឯងផ្ទាល់ ។ ហើយនិងថ្នាក់លើរបស់ជនជាប់ចោទនោះយល់ដឹងថា ការអនុវត្តបែបនេះគឺមានអត្ថប្រយោជន៍ណាស់ ។ ដូច្នេះ នេះគឺជាហេតុផលមួយ ។ ហើយបន្ទាប់មកទៀតនោះ ដោយសារហេតុផលហ្នឹងហើយ ទើបគេបានតែងតាំងគាត់ជាប្រធានស-២១ ។

[១០:០៩:៥៦]

**ស៖** ដើម្បីឲ្យបានយល់ច្បាស់ លោកយល់ថា ការអនុវត្តក្នុងការធ្វើបញ្ជីបែបនេះ ត្រូវបានកែសម្រួលឡើងដោយជនជាប់ចោទ ។ តើលោកមានហេតុផល ឬក៏ប្រភពអ្វីដែរនៅក្នុងការធ្វើការសន្និដ្ឋានបែបនេះ?

**ឆ៖** ការសន្និដ្ឋានបែបនេះ គឺជាការសន្និដ្ឋានដោយធ្វើ ដោយការវិភាគផ្អែកទៅលើអ្វីៗទាំងអស់ដែលខ្ញុំបានដឹងអំពីដំណើរការរបស់ទាំងនេះ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។

**ស៖** សូមអរគុណ។ បើអ៊ីចឹងខ្ញុំនឹងបញ្ចប់សំណួរចុងក្រោយទាក់ទងនឹងបញ្ជីឈ្មោះនេះ ។ ដើម្បីឲ្យយល់ដឹងអំពីបញ្ជីទាំងពីរប្រភេទដែលលោកបាននិយាយនេះ តើលោកនិយាយអំពីបញ្ជីនេះ តើបញ្ជីទាំងអស់ហ្នឹងវាមានចំនួនប៉ុន្មានទៅមួយរយ ឬក៏ពីររយ ឬក៏មួយពាន់បញ្ជីសម្រាប់ប្រភេទនីមួយៗនេះ?

**ឆ៖** ខ្ញុំមិនដែលរាប់បញ្ជីអស់ទាំងហ្នឹងទេ លោកមេធាវី ។ បើតាមខ្ញុំស្មានទៅប្រហែលអាចជារាប់ពាន់បញ្ជី ។

**ស៖** មានន័យថាសម្រាប់ប្រភេទនីមួយៗឬ?

**ឆ៖** បាទ, ត្រឹមត្រូវហើយ ។

**ស៖** ខ្ញុំមានសំណួរមួយពីរទៀត ទាក់ទងទៅនឹងចំណារ ដែលទៅតាមការយល់ដឹងឲ្យបានត្រឹមត្រូវរបស់ខ្ញុំនោះ គឺវាផ្សេងពីបញ្ជីមែនទេ?

**ឆ៖** បាទ, ត្រឹមត្រូវហើយមេធាវី ។

**ស៖** ដំបូងខ្ញុំចង់សួរលោកនូវសំណួរនេះ នៅពេលដែល ណាត ជាប្រធានមន្ទីរស-២១ តើលោកមានបានដឹងថា ណាត ហ្នឹងបានធ្វើចំណារទៅលើចម្លើយសារភាព ទៅតាមវិធីដូចដែលជនជាប់ចោទបានធ្វើចំណារទៅលើចម្លើយសារភាព នៅពេលដែលគាត់បានឡើងជាប្រធានស-២១ នោះ?

**ឆ៖** លោកមេធាវី, ខ្ញុំមិនអាចនឹងឃើញថា បានឃើញចំណារលើចម្លើយសារភាពដែលចំណារនោះជាចំណាររបស់ ណាត ផ្ទាល់នោះ ។ ប្រហែលជាអាចមាន ក៏ប៉ុន្តែខ្ញុំមិនជឿថាមានចំនួនច្រើនទេ ។

**ស៖** ទាក់ទងទៅនឹងចំណារដដែល ខ្ញុំចង់យល់ដឹងថា តើការធ្វើចំណារ ឬក៏របៀបនៃការធ្វើចំណារនោះចាប់ផ្តើមឡើងយ៉ាងដូចម្តេច? តើមានបញ្ហា ឬក៏បញ្ហាជាលាយលក្ខណ៍អក្សរយ៉ាងដូចម្តេចដែរ ដើម្បីឲ្យធ្វើចំណារលើចម្លើយសារភាពអស់ទាំងនោះ?

**ឆ៖** ទេ លោកមេធាវី ។

**ស៖** ទៅតាមចំណេះដឹងរបស់លោក និងក្នុងការស្រាវជ្រាវរបស់លោក ថាតើប្រព័ន្ធនៃការការចំណារចាប់ផ្តើមឡើងដោយដូចម្តេច ហើយហេតុអ្វីបានមានការធ្វើចំណារបែបនេះ?

[១០:១៣:៣០]

**ឆ៖** ការសន្និដ្ឋានរបស់ខ្ញុំទៅលើចំណុចនេះ គឺថា នេះជាលទ្ធផលដែលជនជាប់ចោទខ្លួនឯងផ្ទាល់បានធ្វើទៅលើការងាររបស់ខ្លួន ។ ក្នុងនាមជាអាជីពរបស់គាត់ ជនជាប់ចោទ គឺជាគ្រូបង្រៀន ។ ដូច្នេះហើយគឺថា គាត់ធ្លាប់ក្នុងការចុះនិទ្ទេស ឬក៏ចុះចំណារទៅលើកិច្ចសាលារបស់កូនសិស្សគាត់ ។ ការសន្និដ្ឋានរបស់ខ្ញុំហ្នឹងគឺថា គាត់បានបន្តការអនុវត្តបែបនេះនៅក្នុងអាជីពថ្មីរបស់គាត់ ក្នុងមានជាអ្នកសួរចម្លើយ ។

**ស៖** ហើយពីមុននៅពេលដែលខ្ញុំសួរសំណួរទាក់ទងទៅនឹងសំណួរនៅចំណារ នៅតាមមូលដ្ឋាននោះ តើលោកអាចនិយាយឲ្យបានខ្លីទេ ថាតើអ្វីទៅជាវិធីទូទៅដែលជនជាប់ចោទបានធ្វើចំណារទៅលើចម្លើយសារភាពនោះ? តើលោកអាចរៀបរាប់បានទេ?

**ឆ៖** មានប្រភេទផ្សេងៗគ្នានៃការធ្វើចំណារ ។ ចំណារមួយចំនួន ដូចជាមាន ជាឯកសារដែលពណ៌នាអ៊ីចឹង ។ មានន័យថា រៀបរាប់ថាតើផ្ញើទៅអ្នកណាគេ ដែលចម្លើយសារភាពហ្នឹងត្រូវបានធ្វើហើយនិងនៅពេលណា? ចំណារខ្លះទៀត ដូចជាការជំនួយស្មារតី ដែលធ្វើឡើងដោយជនជាប់ចោទ ។ ជាឧទាហរណ៍អាចជាថា បានអានរួចហើយ ឬក៏មិនទាន់ចប់នៅឡើយទេ ឬក៏ប្រហាក់ប្រហែលគ្នាបែបនេះ ។ ហើយចំណារខ្លះទៀត គឺជាសេចក្តីបង្គាប់ទៅអ្នកសួរចម្លើយដែលមានប្រភេទផ្សេងៗគ្នា ។

សេចក្តីណែនាំនោះអាចជា ដែលថា ជនជាប់ចោទសម្រេចធ្វើការសន្និដ្ឋានថា ការសួរចម្លើយហ្នឹងចប់ហើយ ឬបង្គាប់ឲ្យអ្នកសួរចម្លើយ ឲ្យស្វែងរកព័ត៌មានជាក់លាក់មួយចំនួន ឬមួយក៏អាចបង្គាប់ឲ្យអ្នកសួរចម្លើយធ្វើការអនុវត្តទារុណកម្ម ។

ហើយប្រភេទផ្សេងទៀតនៃចំណារ គឺមានលក្ខណៈជាការវិភាគ ដែលនេះមានន័យថា ចម្លើយសារភាពជាច្រើន មានប្រភេទជាសេចក្តីរាយការណ៍ មានន័យថា សង្ខេបទៅលើចម្លើយសារភាពហើយ និងធ្វើការវិភាគទៅលើចម្លើយសារភាព ។ ប្រភេទខ្លះទៀតនៃចំណារនោះ គឺបានពិភាក្សាអំពីទិដ្ឋភាពទូលំទូលាយអំពីការស៊ើបអង្កេត ដែលត្រូវបានធ្វើឡើងដោយស-២១ ហើយរួមទាំងបញ្ហានានាដែលហួសពីខ្លឹមសារនៃចម្លើយសារភាពជាក់លាក់ណាមួយនោះ ។ ហើយក៏នៅមានប្រភេទចំណារផ្សេងៗទៀតដែរ ដែលដូចជាកំណត់សម្គាល់ពីខាងថ្នាក់លើ ដូចជា សុន សេន ជាដើម ឬក៏ នួន ជា ។

ដូច្នេះ គឺជាពិបាកណាស់ នៅក្នុងការបញ្ជាក់លក្ខណៈទូទៅ ទៅលើប្រភេទនៃចំណារនោះ ។

**ស៖** សូមអរគុណ ។ ខ្ញុំបានយល់ដឹងច្បាស់ហើយ ។ ឥឡូវនេះ ខ្ញុំមានសំណួរទាក់ទងទៅនឹងអន្តរាគមន៍ទៅលើចម្លើយសារភាពទាំងនោះ គឺមិនមែនអន្តរាគមន៍របស់អ្នកដែលសរសេរចម្លើយសារភាពទេ ប៉ុន្តែដោយអ្នកផ្សេងទៀត ។ ជនជាប់ចោទ បាននិយាយនៅចំពោះមុខចៅក្រមថា កាលពីថ្ងៃទី២៩ គឺឯកសារD30 ដែលថា សុន សេន បាននិយាយតាមទូរស័ព្ទជារៀងរាល់ថ្ងៃជាមួយគាត់អំពីចម្លើយសារភាព ហើយគាត់បានធ្វើការកែប្រែ កែសម្រួលទៅតាមបង្គាប់នោះ ។ អ្វីដែលលោកបាននិយាយកាលពីម្សិលមិញ គឺលោកយល់ថា គាត់ហ្នឹងជាមនុស្សមមាញឹកណាស់ ហើយបើតាមការស្រាវជ្រាវ និងទៅតាមការយល់ដឹងរបស់លោក តើលោកយល់ថា ជាការត្រឹមត្រូវទេដែល សុន សេន បានធ្វើអន្តរាគមន៍ ឬក៏ធ្វើការកែប្រែទៅលើខ្លឹមសារនៃចម្លើយសារភាពទាំងនោះ?

**ឆ៖** លោកមេធាវី ខ្ញុំជឿថា ការសន្និដ្ឋានរបស់ជនជាប់ចោទបែបនេះ គឺអាចជាលទ្ធភាពពិតប្រាកដមែន នៅក្នុងករណីនៃការសួរចម្លើយសមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជានោះ ។ សម្រាប់ទាហានសាមញ្ញធម្មតា ឬក៏កម្មាភិបាលធម្មតា ដែលត្រូវបានគេបញ្ជូនទៅស-២១នោះ មានន័យថា ប្រហែលជាមិនកើតមានទេករណីបែបនេះ ។

**ស៖** នៅក្នុងសវនាការកាលពីសប្តាហ៍មុន មុនពេលដែលលោកមកផ្តល់សក្ខីកម្មកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ នោះគឺមាននៅក្នុងប្រតិចារឹក ជាសេចក្តីព្រៀងជាភាសាអង់គ្លេស ទំព័រ៥២ ដល់ទំព័រ៥៤ ជនចាប់ចោទបាននិយាយខ្លួនឯងផ្ទាល់ថា អ្នកដែលធ្វើអន្តរាគមន៍ទៅលើចម្លើយសារភាព មាន

ន័យថាធ្វើការកែប្រែ គឺយកប៊ិច មកកែប្រែចម្លើយសារភាពនោះ គឺនេះជាសម្ដីដែលគាត់បាននិយាយ ។ អ្នកដទៃទៀតដែលត្រូវបានពាក់ព័ន្ធនោះ គឺគណៈអចិន្ត្រៃយ៍មិនធ្វើសកម្មភាពអ្វីទេ ។ ឧទាហរណ៍ តាម៉ុក ឈ្មោះរបស់គាត់ហ្នឹងមាននៅក្នុងចម្លើយសារភាព ប៉ុន្តែ គាត់មិនត្រូវបានគេចាប់ទេ ។ បន្ទាប់ពីបានឮឈ្មោះ តាម៉ុក នោះ គណៈអចិន្ត្រៃយ៍បានរំឭកខ្ញុំកុំឲ្យធ្វើសកម្មភាពអ្វី ហើយចំណែក*ប្រាជី* លោក ធុយ ក៏មានឈ្មោះនៅក្នុងចម្លើយសារភាពជាច្រើនដែរ ប៉ុន្តែគណៈអចិន្ត្រៃយ៍មិនធ្វើសកម្មភាពអ្វីទេ ។ នេះគ្រាន់តែជាឧទាហរណ៍ ហើយខ្ញុំនៅចាំថាចម្លើយសារភាពត្រូវបានគេកែសម្រួល ដូច្នេះ ខ្ញុំគ្រាន់តែផ្ដល់ចម្លើយប្រាប់លោកជាឧទាហរណ៍ ប្រាប់លោកបន្តិចអំពីចំណុចនេះ ។ នៅពេលដែលគាត់ទៅចាប់ជនម្នាក់នោះ មានន័យថា ចម្លើយសារភាពត្រូវធ្វើឡើងគឺសម្រាប់គោលបំណងនៃការចាប់នោះ ។

តើលោកឯកភាពទៅនឹងអ្វីដែលជនជាប់ចោទបាននិយាយនេះទេ? មានន័យថាជាទូទៅ គឺថាមានអ្នកគេកែទៅលើខ្លឹមសារអត្ថន័យនៃចម្លើយសារភាពនោះ ដោយផ្អែកទៅលើការស្រាវជ្រាវរបស់លោក។

**ឆ៖** បាទ, លោកមេធាវី គឺមានភស្តុតាងបង្ហាញលើសពីចម្លើយរបស់ជនជាប់ចោទថា ការអនុវត្តបែបនោះ គឺវាកើតឡើង គឺត្រូវគេអនុវត្តនៅក្នុងករណីមួយចំនួន ។

**សៈ** តាមអ្វីដែលលោកដឹង ថាតើអ្នកណាជាអ្នកកែ ឬក៏សរសេរទៅលើចម្លើយទាំងអស់នោះ?

**ឆ៖** គឺចំណុចនេះវាពិបាកក្នុងការបង្ហាញ ប៉ុន្តែ វាហាក់ដូចជាបង្ហាញឲ្យយើងឃើញថា មេដឹកនាំជាន់ខ្ពស់នៃ នៅក្នុងជួរបដិវត្តន៍គឺ សុន សេន, នួន ជា ហើយប្រហែលជាអាច ប៉ុល ពត អាចជាអ្នកទទួលខុសត្រូវក្នុងការអន្តរាគមន៍បែបនោះ ។

**សៈ** តាមអ្វីដែលលោកបានដឹង គឺជនជាប់ចោទ គាត់បានសរសេរចម្លើយសារភាពនៅតាមការយល់ដឹងរបស់លោក តើមានដែរឬទេ?

**ឆ៖** គឺខ្ញុំអត់អាចលើកឧទាហរណ៍ ទាក់ទងទៅនឹងចំណុចនោះទេ ។

**សៈ** ជនជាប់ចោទនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២១ មករា ឆ្នាំ២០០៨ ទំព័រទី១ នៃភាសាអង់គ្លេស ឯកសារនោះគឺលេខ D38 គឺជនជាប់ចោទនិយាយអំពីលិខិតពី សុន សេន ដែលប្រាប់អ្នកសួរចម្លើយឲ្យប្រយ័ត្ន ដែលប្រយ័ត្នចំពោះចម្លើយសារភាព ដែលចោទប្រកាន់មនុស្សច្រើនពេក ថាតើលោកបានដឹង ធ្លាប់ដឹងអំពីលិខិតបែបនោះដែរឬទេ?

**ឆ៖** បាទ លោកមេធាវី ។

**សះ** គឺខ្ញុំអត់ចង់សួរទៅលើខ្លឹមសារទេ ។ តាមអ្វីដែលលោកដឹង ថាគឺនេះជាការសេចក្តីណែនាំមួយដែលលោកបានដឹងថា វាជាសេចក្តីណែនាំមកពីខាងលើបញ្ជូនមកបុគ្គលិកស-២១ ដែលបង្គាប់ថាតើត្រូវធ្វើយ៉ាងម៉េច ឬមិនត្រូវធ្វើយ៉ាងម៉េចទៅលើករណីទាំងអស់នោះ ឬក៏លោកដឹងថា វាមានសេចក្តីបង្គាប់បែបនេះផ្សេងៗទៀត?

**ឆះ** បាទ, លោកមេធាវី គឺខ្ញុំដឹងអំពីការធ្វើអន្តរាគមន៍បែបនោះផ្សេងៗទៀតទៅលើករណីនេះ ។

**សះ** តើលោកអាចធ្វើការរៀបរាប់ដែរឬទេ?

**ឆះ** យ៉ាងហោចណាស់នៅពេលមួយនោះ សុន សេន ខ្លួនឯងផ្ទាល់បានចុះមកមើលស-២១ ដែលនៅក្នុងពេលនោះ គាត់មកធ្វើការបង្ហាត់បង្រៀនបុគ្គលិកស-២១ ។ ទោះបីជាយើងមិនមានកំណត់សម្គាល់ច្បាស់លាស់ ថាតើមានការលើកឡើងអ្វីអំពីការអប់រំ និងការបណ្តុះបណ្តាលនោះគឺយើងអាចគិតថា ប្រធានបទ គឺវាអាចពាក់ព័ន្ធទៅនឹងកិច្ចការទាំងអស់នេះ នៅពេលដែលមានការបណ្តុះបណ្តាលបែបនោះ ។

[១០:២៥:២៧]

**សះ** លោកបាននិយាយនៅទីនេះ នៅថ្ងៃអង្គារ នៅពេលដែលជនជាប់ចោទធ្វើការសិក្សាទៅលើចម្លើយសារភាព ហើយស្នើសុំការសម្រិតសម្រាំងនោះ គឺនឹងបញ្ជូន បន្ទាប់មកនឹងបញ្ជូនទៅថ្នាក់លើ ។ តើលោកនិយាយអំពីបញ្ជីដែលលោកបានលើកឡើងពីមុននោះ ឬក៏លោកនិយយយោងទៅលើចំណុចណាផ្សេងពីហ្នឹង?

**ឆះ** គឺវាត្រឹមត្រូវ លោកមេធាវី ។ គឺទាក់ទងទៅនឹងបញ្ជីដែលត្រូវបានគេកំណត់ថា ជាខ្មាំង ។

**សះ** នៅពេលដែលលោកនិយាយថា គាត់បញ្ជូននេះទៅថ្នាក់លើរហូតដល់ខែកញ្ញា ឆ្នាំ១៩៧៧ តើវាត្រឹមត្រូវក្នុងការនិយាយដែរឬទេថា សុន សេន គឺគាត់ពាក់ព័ន្ធជាអ្នកពាក់ព័ន្ធ ដែលថាជាថ្នាក់លើនោះនៅពេលដែលបញ្ជីនោះ បានបញ្ជូនឡើងទៅហ្នឹង?

**ឆះ** គឺត្រឹមត្រូវ គឺចំណុចការងារដែលបញ្ជូនបញ្ជីនេះ គឺបញ្ជូនពាក់ព័ន្ធទៅនឹង សុន សេន ។

**សះ** នៅពេលដែល សុន សេន ចាកចេញពីភ្នំពេញ តើលោកអាចនិយាយយ៉ាងម៉េច អំពីការជាប់ពាក់ព័ន្ធរបស់គាត់ទាក់ទងទៅនឹងបញ្ជី ឬក៏ពាក់ព័ន្ធនឹងអ្វីដែលបញ្ជូនចេញពីស-២១ ដូចជាទាក់ទងចម្លើយសារភាពជាដើមនោះ ។ តើលោកដឹងថា លោក សុន សេន នៅពាក់ព័ន្ធទៅនឹងការធ្វើសេចក្តី

សម្រេចផ្សេងទៀតដែរឬទេ បន្ទាប់ពីគាត់ចាកចេញពីភ្នំពេញនោះ?

**ឆ៖** ដូចដែលសហព្រះរាជអាជ្ញា គាត់បានធ្វើការកត់សម្គាល់ឃើញកាលពីម្សិលមិញ ទាក់ទងទៅនឹងកំណត់សម្គាល់មួយចំនួន ដែលផ្ញើចេញមកពីលេខា៥០២ ស៊ូ ម៉េត ជូនជនជាប់ចោទ ។ លិខិតកំណត់សម្គាល់ទាំងអស់នោះ មួយចំនួនគឺបានបង្ហាញថា ត្រូវបានឆ្លងតាមរយៈ សុន សេន ។ ទោះបីជាបន្ទាប់ពីនៅក្នុងពាក់កណ្តាលខែសីហា ឆ្នាំ១៩៧៧ ក៏ដោយ ។ ដូច្នេះ គឺវាហាក់ដូចជាបង្ហាញឲ្យយើងឃើញថា សុន សេន គឺនៅតែជាប់ពាក់ព័ន្ធនៅក្នុងករណីមួយចំនួន បន្ទាប់ពីគាត់បានចាកចេញទៅសមរភូមិមុខ ។

[១០:២៨:១៨]

**ស៖** សូមអរគុណ ។ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ថ្ងៃទី២៨ កុម្ភៈ ឆ្នាំ២០០៨ នៅក្នុងទំព័រ៨ នៃភាសាអង់គ្លេសដែលមានលេខ D22 ជនជាប់ចោទ បាននិយាយថា នៅពេលដែលមានការចាប់ខ្លួនទ្រង់ទ្រាយធំនៅក្នុងអង្គភាព បន្ទាប់ពីមានសេចក្តីសម្រេចជនជាប់ចោទស្នួរ ហ៊ី, សុំ ហ៊ី ឲ្យទៅអង្គភាពនោះ ។ តើលោកបានដឹងអំពីឯកសារដែលមានរៀបរាប់ អំពីការណែនាំដូច្នោះដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ។

**ស៖** ដូច្នេះ គឺលោកមិនអាចនិយាយថា វាមានសេចក្តីណែនាំហ្នឹងច្រើនជាងមួយ ។ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ ទៅលើករណីហ្នឹង?

**ឆ៖** គឺលោកលើកឡើងត្រឹមត្រូវហើយ ។

**ស៖** ខ្ញុំមានសំណួរមួយទៀត បន្ទាប់មកខ្ញុំនឹងបញ្ចប់ប្រធានបទនៃចម្លើយសារភាព ។ លោកបានពន្យល់យ៉ាងច្បាស់លាស់អំពីវិសាលភាពនៃការកម្ទេច និងសម្រិតសម្រាំង ជាពិសេសនៅក្នុងជួរយោធាកងទ័ពបដិវត្តន៍កម្ពុជា ។ ខ្ញុំសូមដកស្រង់កាលពីថ្ងៃអង្គារ លោកបានលើកឡើងថា មានការកម្ទេចទ្រង់ទ្រាយធំនៅក្នុងជួរយោធា កងទ័ពបដិវត្តន៍កម្ពុជា ។ ហើយលោកបាននិយាយថា មានសមាជិកយោធា៣៥៩នាក់ ត្រូវបានសម្លាប់ដែលមកពីអគ្គសេនាធិការ ។ ហើយគឺខ្ញុំអាចបង្ហាញទៅលើចំណុចនេះ គឺមានតារាងដែលលោកបានបង្ហាញ ។ នៅក្នុងទំព័រទី៥ គឺ៤៥ភាគរយ នៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជាត្រូវបានគេកម្ទេច ។ ហើយគឺមាន២៧ភាគរយត្រូវបានគេកម្ទេច ហើយតាមកងពលផ្សេងៗ គឺមាន៥ភាគរយ ។ ដូច្នេះ គឺលោកបានបង្ហាញយ៉ាងច្បាស់ ហើយលោកបានពន្យល់យ៉ាងហ្មត់ចត់អំពីការវាយប្រហារក្នុងទ្រង់ទ្រាយធំនៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា ។

សំណួររបស់ខ្ញុំនោះ គឺថាតើលោកឃើញអំពីទំនាក់ទំនងរវាង សុន សេន ដែលនៅពេលនោះគាត់ជានាយសេនាធិការ ថាតើគាត់មានពាក់ព័ន្ធទៅនឹងចម្លើយសារភាព និងការកម្ទេចទាំងអស់នោះដែរឬទេ នៅពេលដែលលោកបានលើកឡើងទៅលើចំណុចនេះ? តើលោកយល់សំណួររបស់ខ្ញុំដែរឬទេ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំដូចជាអត់យល់ទេ ។

**ស៖** លោកបាននិយាយថា មានការវាយប្រហារទ្រង់ទ្រាយធំនៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា តើលោកគិតដែរឬទេថា សុន សេន នៅពេលនោះ ដែលជានាយសេនាធិការ ហើយដែលគាត់ជាថ្នាក់លើរបស់ជនជាប់ចោទនោះ ក្នុងរយៈពេលប៉ុន្មានឆ្នាំ ថាតើលោកអាចគិតថាវាជាបញ្ហាដែលថានាំឱ្យមានការវាយប្រហារទ្រង់ទ្រាយធំបែបនោះ ឬក៏លោកមិនគិតដូច្នោះទេ?

[១០:៣២:០៧]

**ឆ៖** សូមអរគុណ ។ ខ្ញុំជឿថា ខ្ញុំយល់ហើយសំណួរនេះ ។ ចម្លើយនោះគឺថា អត់ទេ ។ ខ្ញុំជឿថា មូលហេតុនៃការកម្ទេចទ្រង់ទ្រាយធំនោះ នៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា គឺវាមិនជាប់ពាក់ព័ន្ធដោយផ្ទាល់ ដែលថា សុន សេន គឺជានាយសេនាធិការ និងជាមេផ្ទាល់របស់ជនជាប់ចោទនោះទេ ។

**ស៖** តើហេតុអ្វីបានជាមិនដូច្នោះ?

**ឆ៖** ដោយយើងមិនបានមើលខ្លឹមសារជាក់លាក់ ទៅលើចម្លើយសារភាពមួយចំនួន ឬទាំងអស់នោះ ខ្ញុំជឿថា ខ្លឹមសារនៃចម្លើយសារភាពដែលប្រមូលបាននៅស-២១ គឺបានជំរុញថា វាមានការឃុបឃិតគ្នានៅក្នុងជួរដឹកនាំយោធា ។

**ស៖** ខ្ញុំយល់ហើយ ។ លោកបាននិយាយម្សិលមិញថា និយាយម្សិលមិញអំពីការសម្រិតសម្រាំងនៅក្នុងក្រសួងសេដ្ឋកិច្ច វាអាចកើតឡើងដោយការភ័យខ្លាចរបស់គណៈអចិន្ត្រៃយ៍ ហើយអ្នកផ្សេងអាចនិយាយថាវាកើតឡើង (សូមអភ័យទោស) គឺខ្ញុំអត់មានប្រតិចារឹកទេ ប៉ុន្តែ គឺខ្ញុំសូមលើកឡើងនូវសម្តីនេះ ។ គេអាចនិយាយថា គឺវាជាដំណើរការក្នុងការកំណត់ខ្មាំង ហើយលោកនិយាយថា វាជាករណីនេះទាំងពីរ ហើយប្រព័ន្ធនៃការកំណត់ទៅលើខ្មាំងនេះ គឺវាអាចពង្រឹង និងធ្វើឱ្យការភ័យខ្លាចនោះកាន់តែមានលក្ខណៈភ័យខ្លាចជាងមុន តើលោកយល់ទៅនឹងអ្វីដែលខ្ញុំចង់សួរដែរឬទេ?

**ឆ៖** បាទ, មេធាវី ។ វាឧទាហរណ៍ល្អមួយ ទាក់ទងទៅនឹងការវិភាគមួយនោះ គឺវាទាក់ទងទៅនឹងការឱ្យព័ត៌មានមកវិញដោយលក្ខណៈវិជ្ជមាន ។ អ៊ីចឹងបានន័យថា វាអាចផ្តល់ឱ្យយើងយល់ឃើញទៅលើប្រព័ន្ធហ្នឹង ហើយវាបង្កើតជាថាមពលមួយទៅលើករណីនេះ ។

**ស៖** សូមអរគុណ ។ ខ្ញុំមានសំណួរមួយទៀតទាក់ទងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា តើលោកបានដឹងអំពីគោលនយោបាយជាក់លាក់នៃការបង្អត់អាហារអ្នកទោសដែរឬទេ?

**ឆ៖** បាទ គឺមាន ។

[១០:៣៥:២១]

**ស៖** តើលោកអាចនិយាយយ៉ាងម៉េចខ្លះ អំពីគោលនយោបាយនៃការបង្អត់អាហារនោះ?

**ឆ៖** ផ្អែកតាមការស្រាវជ្រាវរបស់ខ្ញុំទៅលើបញ្ហាចោទមួយនេះ គឺខ្ញុំគួរតែនិយាយថា ការបង្អត់អាហារអ្នកទោស និងនៅតាមមន្ទីរសន្តិសុខផ្សេងៗ គឺវាមានលក្ខណៈរីករាលដាល និងទ្រង់ទ្រាយធំ ។ ហើយវាអនុវត្តជាទូទៅតែម្តង នៅក្នុងគោលនយោបាយក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយនៅក្នុងករណីមួយចំនួន គឺវាបង្ហាញឲ្យឃើញថា វិធីនេះ គឺជាវិធីមួយដែលគេប្រើប្រាស់ជាលក្ខណៈនៃការសម្រិតសម្រាំង ។

**ស៖** តើលោកនិយាយយ៉ាងម៉េច អំពីគោលនយោបាយនេះនៅស-២១?

**ឆ៖** ផ្អែកទៅលើចម្លើយសក្ខីកម្មមួយចំនួនដែលខ្ញុំបានពិនិត្យឃើញនោះ ខ្ញុំនឹងនិយាយថា អាហារដែលផ្តល់ទៅដល់អ្នកទោសនៅស-២១ គឺជារបបមួយដែលមិនមានអាហារគ្រប់គ្រាន់ ។ ហើយបន្ទាប់មកអាហារទាំងអស់នោះ វាបណ្តាលឲ្យមនុស្សស្លាប់ ។

**ស៖** នេះគឺជាការអនុវត្តចំពោះគោលនយោបាយហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** គឺវាទំនងដូចជាអ៊ីចឹងហើយ ។

**ស៖** សូមអរគុណ ។ ខ្ញុំមានសំណួរមួយ ដោយសារតែខ្ញុំយល់អត់ច្បាស់ អំពីទំនាក់ទំនងរវាងលេខាភូមិភាគ និងលេខាតំបន់ ហើយនិងទំនាក់ទំនងរវាងអ្នកតំណាងខាងអគ្គសេនាធិការ ។ លោកបាននិយាយថ្ងៃច័ន្ទ នៅទំព័រទី៨៥ និង៨៦ លោកនិយាយថា ភូមិភាគនីមួយៗគឺវាមានការគ្រប់គ្រងដោយអគ្គសេនាធិការ ហើយដូចគ្នានេះដែរ គណៈតំបន់គឺគ្រប់គ្រងជួរយោធានៅតាមតំបន់ ដែលគឺទទួលការគ្រប់គ្រងដោយអគ្គសេនាធិការផងដែរ ។ វាហាក់ដូចជាមិនឲ្យខ្ញុំយល់មិនច្បាស់សោះ ទាក់ទងទៅនឹងភូមិភាគ និងតាមតំបន់ ។ តើបុគ្គលណាមានអំណាចជាងក្នុងភូមិភាគនិងតំបន់ ថាតើបុគ្គលណាគាត់ទទួលខុសត្រូវទៅនឹងកងទ័ពនៅក្នុងភូមិភាគ និងតាមតំបន់?

**ឆ៖** បាទ, លោកមេធាវី! ខ្ញុំគិតថា ខ្ញុំយល់សំណួររបស់លោក ។ អានេះ គឺជាសំណួរមួយគួរឲ្យចាប់អារម្មណ៍ ។ បញ្ហានៃទំនាក់ទំនងយោធានិងស៊ីវិល និងការគ្រប់គ្រងរបស់ស៊ីវិល ផ្អែកស៊ីវិលទៅលើ

យោធានោះ គឺជាបញ្ហាទូទៅ ។ នៅគ្រប់រដ្ឋាភិបាលទូទាំងពិភពលោក ហើយជាការពិតណាស់ ជាញឹកញាប់គឺកើតមានបញ្ហាបែបនេះ នៅក្នុងប្រព័ន្ធនយោបាយដែលពឹងអាស្រ័យទៅលើកម្រិតនៃការធ្វើការបង្ខំនោះ ។

ជាទូទៅគោលគារណ៍គ្រឹះនៃបក្សកុម្មុយនីស្តកម្ពុជា ដែលមានចែងនៅក្នុងឯកសារគ្រឹះជាច្រើននោះ ដូចជានៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា និងសេចក្ដីសម្រេចនានារបស់អចិន្ត្រៃយ៍... ។ល។ បានចែងយ៉ាងច្បាស់ថា គឺបក្សដែលជាអ្នកត្រួតត្រាទៅលើកងកម្លាំងប្រដាប់អាវុធ ហើយនៅក្នុងករណីជាច្រើនចំណុចនេះ ហាក់បីដូចជាវិធីដែលគេបានអនុវត្តនៅក្នុងកម្រិតភូមិភាគ និងនៅក្នុងកម្រិតតំបន់ ។

[១០:៤០:០០]

ក៏ប៉ុន្តែ អំណាចរបស់មេបញ្ជាការយោធា គឺខ្លាំង ហើយនេះគឺជាអ្វីដែលមេដឹកនាំនយោបាយទាំងអស់ត្រូវពិចារណាឲ្យបានច្បាស់លាស់ និងដោយប្រុងប្រយ័ត្ន ។

**ស៖** សូមអរគុណ ។ កាលពីថ្ងៃច័ន្ទ ហើយនៅក្នុងប្រតិចារឹកកាលពីថ្ងៃទី១៨ នៅទំព័រ៧១ លោកនិយាយថា នៅក្នុងអំឡុងពេលនៃរបបនោះ ខ្ញុំជឿថា គឺ សុន សេន បានក្លាយទៅជាសមាជិកពេញសិទ្ធិ ហើយពេលនោះ គង់ សុផល គឺជាសមាជិកត្រៀមរហូតដល់ពេលគាត់ត្រូវបានគេចាប់ខ្លួនបញ្ជូនមកស-២១ ។ តើលោកអាចប្រាប់បានទេ នៅពេលណាដែល សុន សេន បានក្លាយទៅជាសមាជិកពេញសិទ្ធិរបស់គណៈអចិន្ត្រៃយ៍នោះ?

**ឆ៖** ខ្ញុំជឿថា សុន សេន បានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍មិនអាចមុនខែវិច្ឆិកា ឆ្នាំ៧៨ ឬក៏អាចមុននេះទៅទៀត ។

**ស៖** ជនជាប់ចោទនៅចំពោះមុខចៅក្រមស៊ើប ហើយទៅតាមឯកសារយោងដែលខ្ញុំមាននេះគឺកាលពីថ្ងៃទី៥ គឺនៅឯកសារ D16 គាត់និយាយថា កាលពីថ្ងៃ៣០ ខែមេសា នៅក្នុងប្រតិចារឹកនៅទំព័រទី៣៥ ដល់ ៣៧ ជនជាប់ចោទនិយាយថា សុន សេន គឺមានឋានៈលេខ៧ នៅក្នុងរបបនោះ ។ តើលោកឯកភាពទៅនឹងការសន្និដ្ឋានរបស់ជនជាប់ចោទនេះទេ?

**ឆ៖** នៅក្នុងអំឡុងពេលនៃរបបនោះ ឋានៈរបស់សមាជិកជាន់ខ្ពស់ គឺមានការប្រែប្រួលជាប្រចាំបើពួកគេតស៊ូក្នុងការក្ដាប់យកអំណាចរៀងខ្លួន ។ ហើយនៅពេលដែលមានការសម្រិតសម្រាំងកើតឡើងនៅថ្នាក់លើនៃបដិវត្តន៍ផងដែរនោះ ។ ដូច្នេះ ការចាត់លំដាប់ថ្នាក់នេះគឺមានការផ្លាស់ប្ដូរទៅតាមពេលវេលា ក៏ប៉ុន្តែ អ្វីដែលគាត់អាចលើកឡើងនឹងអាចជាចំណុចត្រឹមត្រូវនៅចំណុចណាមួយដែលថា សុន

សេន ហ្នឹងអាចជាមនុស្សទីប្រាំពីរ នៅក្នុងជួរបក្សនោះ ។

**ស៖** ក៏ប៉ុន្តែ ខ្ញុំចង់ដឹងអំពីអំណាចពិតប្រាកដ ។ លោកបានពន្យល់ប្រាប់លោកស្រីថៅក្រុម ខាតរាយថ៌ បានច្បាស់ណាស់ថា គាត់មានអំណាចខ្លាំងពីព្រោះនៅពេលហ្នឹង គាត់គឺជាផ្នែកមួយនៃរដ្ឋាភិបាល និងជាផ្នែកមួយរបស់យោធាដែលជាអគ្គសេនាធិការ និងជាសមាជិករបស់គណៈអចិន្ត្រៃយ៍ ។ តើជាការត្រឹមត្រូវទេបើសិននិយាយថា ទោះបីជាមិនមែននៅក្នុងរចនាសម្ព័ន្ធជាផ្លូវការក៏ដោយ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង តើជាការត្រឹមត្រូវទេ? មានន័យថាគាត់មានអំណាចជាងសមាជិកផ្សេងៗ ដទៃទៀតនៅក្នុងគណៈអចិន្ត្រៃយ៍ ដូចជា ហ៊ូ នឹម, សោ ភឹម ឬក៏ វ៉ន វេត នោះ តើលោកឯកភាពនឹងការសន្និដ្ឋានបែបនេះទេ?

[១០:៤៣:៣៥]

**ឆ៖** នេះគឺជាសំណួរមួយដ៏លំបាកបំផុតលោកមេធាវី ។ អំណាច គឺជាវត្ថុដែលយើងមិនអាចមើលឃើញ ហើយវាពិបាកណាស់ក្នុងការធ្វើការវាស់វែងវា ។ អំណាចអាចនឹងកើតមាននៅពេលដែលមានការធ្វើការប្រជុំណាមួយ ឬក៏សមត្ថភាពក្នុងការជះឥទ្ធិពលទៅសេចក្តី ការធ្វើសេចក្តីសម្រេចនៅក្នុងក្រុមណាមួយ ។ ហើយជាការពិតណាស់ ទាក់ទងទៅនឹងសមត្ថភាពរបស់គាត់ ក្នុងការបញ្ជាកងកម្លាំងយោធា សុន សេន គឺមានអំណាចជាង វ៉ន វេត ឬមួយក៏ អៀង សារី ។ ក៏ប៉ុន្តែ តើគាត់មានឥទ្ធិពលយ៉ាងណានោះ នៅក្នុងការធ្វើនយោបាយ នៅក្នុងការធ្វើសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍? នោះអាចជាបញ្ហាមួយផ្សេងពីនេះ ។

**ស៖** សូមអរគុណ ។ តើលោកអាចបញ្ជាក់បានទេ លោកបានឆ្លើយតបទៅនឹងលោកស្រី ខាតរាយថ៌ នៅក្នុងរបាយការណ៍របស់លោកទាក់ទងអំពីលេខអក្សរ “គ” “ឃ” “ង” ជាដើម ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា សម្រាប់ឈ្មោះទីមួយនោះ គឺថាគាត់ត្រូវបានគេសម្លាប់ ថាតើគាត់ត្រូវបានគេសម្លាប់យ៉ាងដូចម្តេចនោះ? តើគាត់ គេសម្លាប់គាត់នៅទួលស្លែងឬ?

**ឆ៖** បាទ, ត្រឹមត្រូវហើយលោកមេធាវី ។

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធានខ្ញុំដឹងថា ដល់ពេលសម្រាកហើយ តែខ្ញុំមានសំណួរមួយចំនួនទៀត តើចង់ឲ្យខ្ញុំសម្រាកសិន ឬក៏យើងត្រូវសម្រាកសិន?

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន បើសិនលោកប្រធានអនុញ្ញាតនៅពេលនេះ តើខ្ញុំអាចនិយាយបានទេ តើខាងមេធាវីការពារក្តីអាចមានឱកាសបានទេ? ខ្ញុំដូចជាមានការបារម្ភបន្តិចពីព្រោះលោក វ៉ែនណឺ កាលពីម្សិលមិញបានប្រកាសថា គាត់ប្រហែលជាមានសំណួរស៊ីពេលប្រហែលជាម្ភៃនាទីទេ ។ តែទោះបីជាយើងចំណាយពេលដប់ប្រាំនាទី ដោះស្រាយទៅនឹងការធ្វើសេចក្តីអង្កេតរបស់ខាងសហព្រះរាជអាជ្ញាក៏ដោយនោះ ឥឡូវនេះលោក វ៉ែនណឺ បាននិយាយជាងមួយម៉ោងរួចមកហើយ ។ ហើយខ្ញុំយល់ថា លោកអាឡិច ប៊ែត គាត់នឹងចាកចេញនៅរសៀលនេះ ។ ហើយខ្ញុំចង់ធ្វើការសាកសួរទៅលោក អេតធេសាន់មុនលោកអាឡិចប៊ែត គាត់ចាកចេញ ហើយក៏មុនពេលដែលខ្ញុំចាកចេញទៅដែរ ។

ដូច្នេះ តើយើងអាចធ្វើការកំណត់បានទេ ថាតើយើងធ្វើការបែងចែកពេលវេលាគ្នាយ៉ាងដូចម្តេច? សម្រាប់ភាគីពាក់ព័ន្ធនីមួយៗ ទាក់ទងទៅនឹងពេលវេលាសម្រាប់ឲ្យខាងមេធាវីការពារក្តីផងដែរ ។

តើលោកប្រធានអាចឲ្យលោក វ៉ែនណឺ ហ្នឹងធ្វើសំណួរឲ្យបានច្បាស់លាស់ ហើយនិងជាក់លាក់បន្តិចដើម្បីឲ្យយើងនឹងកំណត់ ពេលវេលាបានប្រសើរជាងនេះ ។

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំនឹងធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ជាងនេះ លោកប្រធាន ។ សូមអរគុណ ។

ចៅក្រម ឡាវ៉ែន៍ បាននិយាយដែលថា កាលពីម្សិលមិញនោះ ខ្ញុំមិនមានបំណងស៊ីពេលដូច្នេះទេ ខ្ញុំគ្រាន់តែចង់ធ្វើការពន្យល់ថា ខ្ញុំនឹងអាចស៊ីពេលលើសម្ភៃនាទី ឬក៏កន្លះម៉ោង ប្រសិនបើសិនជាខ្ញុំកំណត់ពេលវេលាដូច្នេះនៅពេលនោះ ប្រហែលជាខ្ញុំខុសហើយ បើសិនជាខ្ញុំខុសមែន ខ្ញុំសុំទោស ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដោយ ឌីវីឌី ថតសម្លេងក៏អស់ផង ក៏ដល់ពេលត្រូវសម្រាកផង អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយប្រាំនាទី អញ្ជើញចូលវិញ ដើម្បីបន្តដំណើរការពិភាក្សាដេញដោលបន្តទៀត ។ មន្ត្រីតុលាការសម្របសម្រួលដល់អ្នកជំនាញ ដើម្បីបានកន្លែងសម្រាកសមរម្យ ។

*[សវនាការសម្រាកពីម៉ោង ១០:៤៨នាទី ដល់ម៉ោង១១:៣០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជម្រះប្រកាសបន្តដំណើរនីតិវិធីសវនាការ ។ ហើយជាកិច្ចបន្តនេះគឺប្រគល់វេទិកាទៅឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ។ មេធាវីអន្តរជាតិ បន្តការសួរសំណួរ

ដល់អ្នកជំនាញរូបនេះបន្តទៀត ប៉ុន្តែ ដោយអង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការលើកឡើងនូវមិតិយោបល់របស់មេធាវីការពារក្តី គឺជាការសមរម្យមួយដែលមេធាវីអន្តរជាតិតំណាងឲ្យរដ្ឋប្បវេណីក្រុមមួយបានអះអាងពីម្សិញមិញ គឺក៏ដូចជាថ្ងៃមុនដែល គឺថាខ្លួននឹងមិនសួរសំណួរអីច្រើនទេ ។ ប៉ុន្តែ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ពេញមួយព្រឹកនេះ គឺមានតែគាត់ទេដែលគាត់ទទួលយកទាំងស្រុងនូវវេទិកាដដែកដេញដោលនេះ ។ អ៊ីចឹង អង្គជំនុំជម្រះ ទីមួយ សូមរំឭកដល់មេធាវី អាឡាំង វ៉ែនណឺ ថា សូមលោកសួរឲ្យចំ ហើយនិងអនុញ្ញាតឲ្យកម្រិតត្រឹមតែ យ៉ាងយូរគឺដប់មីនុតប៉ុណ្ណោះ ក្នុងការបន្តការសួរនេះ ឬក៏តិចជាងនេះ ។ ហើយសួរឲ្យបានច្បាស់លាស់ឲ្យខ្លី ឲ្យចំបញ្ហាតែម្តង ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

**ស៖** សូមអរគុណលោកប្រធាន គឺខ្ញុំយល់ច្បាស់នូវអ្វីដែលលោកចៅក្រមបានបញ្ជាក់ ។ លោកអេតធេសាន់ ខ្ញុំចង់សួរសំណួរទីមួយរបស់ខ្ញុំនោះគឺថា ជនជាប់ចោទនៅចំពោះសហចៅក្រមស៊ើបអង្កេតនៅថ្ងៃ៥ ខែ៩ ឆ្នាំ២០០៧ ទំព័រលេខ៦ ឯកសារ D16 គាត់បានលើកឡើងថា ថាតើលោកដឹងអំពីកិច្ចការនោះយ៉ាងម៉េច? ដោយសារតែនៅថ្ងៃនោះ ខែសីហា លោកធ្វើការជាមួយនឹង សុន សេន ។ ហើយ សុន សេន និយាយជាមួយខ្ញុំអំពីអ្នកនៅថ្នាក់លើនៅក្នុងគណៈអចិន្ត្រៃយ៍ ។ ដោយយើងចាំនូវអ្វីដែលយើងចាំនោះ គឺនៅថ្ងៃអង្គារ ក្នុងប្រតិចារឹករបស់យើងទំព័រ៥២ គឺវានិយាយអំពីគោលនយោបាយសម្ងាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ថាតើវាត្រឹមត្រូវក្នុងនិយាយដែរឬទេ ដែលថា ជនជាប់ចោទគាត់ទទួលបានព័ត៌មានដែលគាត់ទទួលបាន? ថាតើគាត់ទទួលបានព័ត៌មានទាក់ទងទៅនឹងបញ្ហាសម្ងាត់ដែរឬទេ?

**ឆ៖** គឺខ្ញុំគួរ ខ្ញុំគិតថា ខ្ញុំប្រហែលមិនអាចធ្វើការរៀបចំឃ្លាដូចដែលលោកបានលើកឡើងនោះទេ ប៉ុន្តែខ្ញុំសូមនិយាយថា ជនជាប់ចោទ គឺគាត់ទទួលបានៗដោយផ្ទាល់ នឹងការទាក់ទងទៅលើថ្នាក់លើជាន់ខ្ពស់ ហើយគាត់ ជនជាប់ចោទនោះ គាត់ក៏ៗទទួលបានព័ត៌មានដែលមានលក្ខណៈសម្ងាត់បំផុតច្រើនផងដែរ ។

[១១:៣៤:១៣]

**ស៖** សូមអរគុណ ។ យើងនិយាយអំពីបុគ្គលដែលទទួលខុសត្រូវផ្នែកមន្ទីរសន្តិសុខនៅក្រៅភ្នំពេញ ដូចជានៅតាមជនបទផ្សេងៗ តើវាត្រឹមត្រូវដែរឬទេដែលយើងនិយាយថា ភាគច្រើននៃប្រធានមន្ទីរសន្តិសុខ ដែលចាប់ផ្តើមឡើងនៅក្នុងឆ្នាំ១៩៧៥ ហើយមកត្រឹមខែមករា ឆ្នាំ១៩៧៩ អ្នកដែលស្ទើរតែទាំងអស់នោះ គឺមិនត្រូវបានកម្ទេចនោះទេ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** គឺឃើញថា មានចំនួនភាគច្រើន ។

**ស៖** តើវាអនុវត្តដូចគ្នាទៅនឹងបុគ្គលិក និងអ្នកយាមដែលគាត់ធ្វើការនៅតាមជនបទនោះ ដូចគ្នាដែរឬទេ? នៅតាមមន្ទីរសន្តិសុខនោះ ។

**ឆ៖** គឺវាស្រ័យទៅតាមករណីនីមួយៗ ។ នៅកន្លែងមួយចំនួន នៅពេលដែលមានការសម្រិតសម្រាំងជួរដឹកនាំ ឬក៏មានការសម្រិតសម្រាំងបុគ្គលិកនោះ ។ ហើយនៅក្នុងករណីទៀត យើងឃើញមានការសម្រិតសម្រាំងម្តងហើយម្តងទៀត នៅចំពោះជួរដឹកនាំនិងបុគ្គលិក ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ។ ដោយយើងចងចាំនូវអ្វីដែលលោកបានលើកឡើងអំពីតែ អំពីអ្នកភាគច្រើន អ្នកដែលខុសត្រូវមន្ទីរសន្តិសុខភាគច្រើន គឺត្រូវបានគេកម្ទេច ។ ហើយយើងចាំ នូវអ្វីដែលលោកបានលើកឡើងកាលពីថ្ងៃមុន គឺបុគ្គលិកនៅស-២១ មួយចំនួននោះត្រូវបានគេសម្រិតសម្រាំង ។ ហើយយើងចាំនូវអ្វីដែលលោកបាននិយាយអំពីការសម្រិតសម្រាំងនៅក្នុងក្របខ័ណ្ឌកម្ពុជាប្រជាធិបតេយ្យ ។ ថាតើហេតុអ្វីជនជាប់ចោទគាត់មិនទទួលបាននូវការសម្រិតសម្រាំងបែបនោះ ដូចគេដូចឯង?

**ឆ៖** ចំពោះការយល់ឃើញរបស់ខ្ញុំ ជនជាប់ចោទដែលមិនត្រូវបានគេសម្រិតសម្រាំង ដោយសារតែមេរបស់គាត់ គិតថាមានលក្ខណៈស្មោះត្រង់ ហើយមានប្រសិទ្ធភាព ។

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំអត់មានសំណួរសួរបន្ថែមទៀតទេ ខ្ញុំសូមអរគុណចំពោះពេលវេលាដែលលោកបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ ។

[១១:៣៦:៥៤]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជម្រះសូមប្រគល់វេទិកានេះទៅមេធាវីការពារក្តី ដើម្បីមានលទ្ធភាពក្នុងការតាំងសំណួរពាក់ព័ន្ធទៅនឹងបណ្ឌិត ក្រេក អេតធេសាន់ ដែលជាអ្នកជំនាញរូបនេះ ។ បើមានសូមអញ្ជើញលោកមេធាវី ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណលោកប្រធាន ។ សូមលោកបណ្ឌិតមេត្តាបញ្ជាក់នៅក្នុងរបាយការណ៍ ចុះថ្ងៃទី១៨ ខែ៧ ២០០៧ របស់លោកបណ្ឌិត ត្រង់វាក្យខណ្ឌទី២៤ ដែលលោកបានបញ្ជាក់ថា តែពីរបន្ទាត់

កន្លះទេ ខ្ញុំសូមអានតែម្តង "គណៈអចិន្ត្រៃយ៍ ដើរតួម្តងទៀតក្នុងនាមគណៈមជ្ឈិម មានអំណាចអនុញ្ញាតឲ្យអង្គការថ្នាក់ក្រោម ដែលជាឧបករណ៍របស់បក្សអនុវត្តការប្រហារជីវិត ដោយគ្មានការវិនិច្ឆ័យ ដូចបានឃើញក្នុងសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ។" អ៊ីចឹង ឃ្លាហ្នឹង តើមានន័យយ៉ាងម៉េច? ចង់និយាយថា ត្រង់ហ្នឹង ឬដែលលោកបណ្ឌិតបានឆ្លើយពីថ្ងៃមុន គឺពីថ្ងៃទី១៨ ខែ៥ ២០០៩ វេលាម៉ោងដប់ប្រាំមួយដប់ប្រាំនាទី និងហាសិបប្អូនវិនាទី ។ លោកបណ្ឌិតបានឆ្លើយថា យល់ស្របជាមួយនឹងជនជាប់ចោទ ពីព្រោះពេលនោះជនជាប់ចោទបានឆ្លើយថា ជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋ-កម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជនមានតែបួនក្រុមទេ ។ បួនក្រុមនេះហើយ ដែលវាសម្រេចឲ្យអ្នកណារស់ ឲ្យអ្នកណាងាប់ គឺនៅលើវា ពីព្រោះគណៈអចិន្ត្រៃយ៍បានប្រគល់សិទ្ធិឲ្យវាជាអ្នកសម្រេចក្នុងការកម្ទេចមនុស្ស ហើយលោកក៏បានឆ្លើយថា យល់ស្របជាមួយជនជាប់ចោទ ។

អ៊ីចឹង តើឃ្លាដែលខ្ញុំអានអម្បាញ់មិញនៅក្នុងរបាយការណ៍របស់លោកនេះឬ ដែលបញ្ជាក់ពីគំនិតដែលលោកយល់ស្រប? សូមលោកបញ្ជាក់ ។

**ឆ៖** សូមអរគុណលោកមេធាវី ។ ឲ្យខ្ញុំសូមទោសប្រសិនបើខ្ញុំយល់មិនច្បាស់អំពីសំណួររបស់លោកនោះទេ ខ្ញុំដូចជាយល់មិនច្បាស់ទេ ។

**ស៖** ខ្ញុំសូមជម្រាបម្តងទៀត ។ វាក្យខណ្ឌដែលខ្ញុំអានអម្បាញ់មិញ លោកបណ្ឌិតស្តាប់បានហើយៗជនជាប់ចោទ បានឆ្លើយមុនដែលលោកចៅក្រមបានសួរលោក លោកបានឆ្លើយថា លោកបានយល់ស្របជាមួយនឹងជនជាប់ចោទ ។ អ៊ីចឹង ដែលខ្ញុំសួរថា តើឃ្លាដែលខ្ញុំអានន៎ែ តើគំនិតហ្នឹង ក្នុងឃ្លាហ្នឹងដែលលោកយល់ស្របជាមួយជនជាប់ចោទ?

[១១:៤០:៤១]

**ឆ៖** សូមអរគុណលោកមេធាវី ។ តើខ្ញុំអាចសុំឲ្យលោកបញ្ជាក់ឲ្យបានច្បាស់លាស់បន្តិចទេនៅចំណុចណាដែលលោកចៅក្រមបានសួរខ្ញុំ ហើយនឹងអ្វីដែលខ្ញុំបានឯកភាពជាមួយនឹងជនជាប់ចោទនោះ ។

**ស៖** សូមជម្រាបលោកថា នៅវេលាម៉ោង ដប់ប្រាំមួយដប់ប្រាំនាទី និងហាសិបប្អូនវិនាទីលោកចៅក្រមបានសួរលោក ហើយលោកក៏បានឆ្លើយថា គឺខ្ញុំយល់ស្របនឹងចម្លើយនេះ ។ នឹងចម្លើយហ្នឹងចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយថា ជនដែលទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្ម គឺជនបួនក្រុមដែលខ្ញុំបានជម្រាបមិញហ្នឹង ហើយលោកក៏បានឆ្លើយថា យល់ស្របតាមជនជាប់ចោទ ។

អ៊ីចឹងសូមលោកបញ្ជាក់មកទៀត តើឃ្លាដែលនៅក្នុងហ្នឹង តើឃ្លាហ្នឹង ឬដែលលោកអះអាងថា

ដែលលោកយល់ស្របជាមួយនឹងជនជាប់ចោទ? ពីព្រោះក្នុងឃ្លាន៎ែ លោកបានលើកសេចក្តីសម្រេចរបស់មជ្ឈិមបក្សចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ មកអះអាង ។ សូមលោកបញ្ជាក់ ។

**ឆ៖** សូមអរគុណលោកមេធាវី ។ ខ្ញុំអាចបញ្ជាក់ថា ខ្ញុំបានពឹងផ្អែកយ៉ាងច្រើននៅក្នុងសក្ខីកម្មរបស់ខ្ញុំ ទៅលើសេចក្តីសម្រេចចិត្តដែលបានចុះថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៧៦ នោះ គឺជាសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ ។ នៅក្នុងសំណួររបស់លោកៗបានសួរថា តើខ្ញុំបានឯកភាពឬ ដែលថាមនុស្សទាំងបួនប្រភេទនុ៎ង ដែលជនជាប់ចោទបានលើកឡើង គឺជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ខ្ញុំត្រូវតែឆ្លើយថា សម្រាប់ខ្ញុំផ្ទាល់ពាក្យថា "អ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ" គឺមានអត្ថន័យបច្ចេកទេសដែលមានភាពស្មុគស្មាញបំផុត ។ ដែលខ្ញុំជឿថា ខ្ញុំមិនអាចធ្វើការពន្យល់បានទេនៅក្នុងស្ថាភាពនេះ ។

**ស៖** សូមអរគុណលោកអត់អាចពន្យល់បានទេ ប៉ុន្តែនៅក្នុងថ្ងៃនោះលោកបានមានប្រសាសន៍ថា លោកយល់ស្របជាមួយនឹងជនជាប់ចោទ ។ អ៊ីចឹងគំនិតរបស់លោកៗនៅតែយល់ស្របជាមួយនឹងជនជាប់ចោទ ឬយ៉ាងម៉េច?

**ឆ៖** អរគុណលោកមេធាវី ។ ខ្ញុំបញ្ជាក់ឲ្យបានច្បាស់បំផុតថា តើពាក្យសម្តីរបស់ជនជាប់ចោទចំណុចណាដែលខ្ញុំឯកភាពជាមួយនោះ សូមលោកបញ្ជាក់ឲ្យបានច្បាស់បន្តិចបានទេ?

[១១:៤៥:២៧]

**ស៖** សូមអរគុណលោកបណ្ឌិត ។ ពាក្យសម្តីដែលជនជាប់ចោទបានអះអាងនោះ គឺជនជាប់ចោទបានសង្កត់ធ្ងន់ទៅលើលិខិតចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលគណៈអចិន្ត្រៃយ៍មជ្ឈិមបក្សនៃកុម្មុយនីស្ត បានប្រគល់សិទ្ធិមកឲ្យជនបួនក្រុមជាសម្រេចក្នុងការកម្ទេចប្រជាជនកម្ពុជាក្នុងជួរ និងក្រៅជួរ គឺជនជាប់ចោទផ្អែកទៅលើលិខិតនេះ ។ ហើយនៅក្នុងរបាយការណ៍របស់លោកក៏ផ្អែកទៅលើលិខិតនេះដែរ ។ អ៊ីចឹងហើយបានខ្ញុំសួរលោក ដែលលោកថា តើលោកបណ្ឌិត យល់ស្របជាមួយជនជាប់ចោទ តើលោកបណ្ឌិតសំអាងទៅលើឃ្លាក្នុងរបាយការណ៍របស់លោកកន្លែងហ្នឹង ឬយ៉ាងម៉េច?

**ឆ៖** សូមអរគុណលោកមេធាវី ឥឡូវនេះច្បាស់ហើយ ខ្ញុំពិតជាឯកភាព ។ គឺឯកភាពថា ផ្នែកដំបូងនៃឯកសារ មានន័យថា សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នេះ គឺបានរៀបរាប់ ដែលថាគណៈអចិន្ត្រៃយ៍ផ្តល់អំណាចទៅឲ្យស្ថាប័នមួយចំនួនក្នុងការកម្ទេចប្រជាជន ។ ខ្ញុំឯកភាពទៅលើចំណុចនេះ ។

**ស៖** សូមអរគុណលោកបណ្ឌិត ។ សំណួរទីពីរ តាមការស្រាវជ្រាវរបស់លោកបណ្ឌិត តើលោកបណ្ឌិតអាចរកឃើញទេ តើគុកមួយណាដែលធំជាងគេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆៈ** សូមអរគុណលោកមេធាវី ។ មានវិធីជាច្រើនក្នុងការវាស់វែងអំពីទំហំ ឬក៏ប្រវែង ។ បើសិនជាយើងធ្វើការវាស់វែងទំហំ អាស្រ័យទៅលើការវាស់វែងទៅលើចំនួនបុគ្គលិកដែលធ្វើការនៅតាមមន្ទីរសន្តិសុខនោះ គឺនឹងមិនមែនជាសំណួរទៀតទេ ។ ស-២១ គឺជាមន្ទីរសន្តិសុខ ដែលធំជាងគេបង្អស់ ក៏ប៉ុន្តែបើសិនជាយើងធ្វើការវាស់វែងទៅលើទំហំនៃមន្ទីរសន្តិសុខ ដោយរាប់ទៅលើចំនួនជនរងគ្រោះដែលបានស្លាប់ គឺនេះជាចំណុចពិបាកនៅក្នុងការប្រៀបធៀប ពីព្រោះមានតែមន្ទីរសន្តិសុខចំនួនតិចតួចប៉ុណ្ណោះដែលមានកំណត់ហេតុបញ្ជាក់ពិស្តារចំណុចនេះ ។ ដូចជាចំណុចពិស្តារដែលមានបញ្ជាក់នៅក្នុងមន្ទីរស-២១នោះ ។ នៅក្នុងករណីខ្លះទៀត យើងអាចធ្វើការប៉ាន់ស្មាន ដោយអាស្រ័យទៅលើចំនួនរណ្តៅកប់សពរួម និងចំនួនឆ្អឹងខ្មោចដែលមាននៅក្នុងរណ្តៅកប់សពរួមអស់ទាំងហ្នឹង ។

ដូច្នេះ ជាការពិបាកក្នុងការកំណត់និយមន័យថា តើមន្ទីរសន្តិសុខមួយណាដែលសម្លាប់មនុស្សច្រើនជាងគេនោះ?

**សៈ** សូមអរគុណលោកបណ្ឌិត ។ ដែលខ្ញុំចង់ដឹង ថាតើមន្ទីរសន្តិសុខមួយណាធំជាងគេនោះ? ព្រោះតាមការសួរដេញដោលកន្លងមក ហាក់ដូចជាចង់សង្កត់ថា ស-២១ ជាមន្ទីរសន្តិសុខ ដែលធំជាងគេទាំងអស់ទូទាំងប្រទេសកម្ពុជា ។ ចំណែកខ្ញុំ ជាមេធាវីឲ្យការពារ ខ្ញុំជម្រាបលោកបណ្ឌិតថា ខ្ញុំយល់ផ្ទុយពីគេ ។ ខ្ញុំយល់ថាមន្ទីរសន្តិសុខស-២១ បានជាមានបុគ្គលិក វាច្រើនរហូតទៅដល់រាប់ពាន់នាក់ ដោយសារមន្ទីរសន្តិសុខស-២១ វាបែងចែកទៅបីកន្លែង វាមាននៅស-២៤ វាមាននៅព្រៃស វាមាននៅជើងឯក វាមាននៅស-២១ ខ្លួនវានេះផង ។ ហើយជាពិសេស ដែលត្រូវការស៊ីបុគ្គលិកច្រើន ដោយសារនៅស-២៤ នៅព្រៃស គឺមានមនុស្សសឹងថា រាប់ដល់រាប់ពាន់នាក់ ដែលគេយកទៅអប់រំកែប្រែនៅកន្លែងនោះ ។ អ៊ីចឹង ការអប់រំកែប្រែនៅកន្លែងនោះ បើមនុស្សវារាប់រយនាក់ ដូច្នេះវាត្រូវការនាក់យាមអ្នកធ្វើការនៅហ្នឹងក៏វាច្រើនដែរ ។ ដូច្នេះវាមិនមែន ស-២១ ធំជាងគេក្នុងការកាប់សម្លាប់នោះទេ ។ ខ្ញុំយល់អ៊ីចឹង អានេះតាមយោបល់របស់ខ្ញុំ សូមជម្រាបលោកបណ្ឌិតអ៊ីចឹង ។ ហើយបើតាមខ្ញុំយល់ថា ដីកាដែលឃុំ ដែលសំដៅយកការដែលគុកធំជាងគេរបស់ខ្ញុំ គឺសំដៅទៅរកកន្លែងណា ដែលកាប់សម្លាប់ច្រើនជាងគេ ។ ខ្ញុំចង់សំដៅកន្លែងហ្នឹង ។ នេះសូមអរគុណលោកបណ្ឌិត ។

[១១:៥០:៣០]

សំណួរទីបី នៅក្នុងដ្យាក្រាមដែលនៅក្នុងរបាយការណ៍របស់លោកបណ្ឌិត ដ្យាក្រាមនេះ ខ្ញុំបានពិនិត្យទៅឃើញហាក់ដូចជា សមាជិករដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យហាក់ដូចជាច្រើន ដូច

មានច្រើន ។ ប៉ុន្តែ បើសិនជាខ្ញុំពិនិត្យទៅលើឯកសារចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ត្រង់ទំព័រ៦ ដែលមានលេខERN00003141 បន្ទាត់ទីពីរ ទីបី ទីបួន ទីប្រាំ ពីក្រោមឡើងលើទៅ ខ្ញុំពិនិត្យឃើញថា សមាជិករដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យហាក់ដូចជាមានគ្នាតែបួននាក់ទេ ។ អ៊ីចឹងបញ្ហានេះ សូមលោកបណ្ឌិតមេត្តាបញ្ជាក់មើល តើសមាជិករដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានប៉ុន្មាននាក់ ហើយឈ្មោះអីខ្លះ? បាទ សូមអរគុណ សូមលោកបណ្ឌិតមេត្តាបញ្ជាក់ ។

**ឆ៖** សូមអរគុណលោកមេធាវី ។ នេះគឺជាឯកសារដូចដែលលោកបានស្នើឡើងអ៊ីចឹង គឺបាននិយាយចំពោះថ្នាក់លើតែបួនរូប តែប៉ុណ្ណោះ គឺ ប៉ុល ពត ដែលរៀបរាប់ក្នុងឯកសារនេះថា ជារដ្ឋមន្ត្រីទីមួយ សមមិត្ត វ៉ាន់ ដែលនេះជាឈ្មោះហៅក្រៅរបស់ អៀង សារី ចាត់ទុកជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេស ។ បន្ទាប់មកគឺសមមិត្ត វន ដែលជាឈ្មោះរបស់ វ៉ន វេត ដែលជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសមមិត្តខៀវ ដែលជាឈ្មោះហៅក្រៅរបស់ សុន សេន ដែលរៀបរាប់ថា គាត់ជាឧបនាយករដ្ឋមន្ត្រីទទួលខាងការពារប្រទេស ។

**ស៖** សូមអរគុណលោកបណ្ឌិត ។ អ៊ីចឹង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សមាជិករដ្ឋាភិបាលមានតែបួននាក់ទេ ។ សូមអរគុណ ។

សំណួរទីបួន សូមលោកបណ្ឌិតមេត្តាបញ្ជាក់ពាក្យថា "អង្គការ" ពាក្យថាអង្គការនេះ តើគេសំដៅទៅលើអចិន្ត្រៃយ៍មជ្ឈិមបក្ស ឬក៏សំដៅទៅលើរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ អ៊ីចឹងអង្គការហ្នឹង សំដៅទៅលើអ្នកណា? សូមលោកបណ្ឌិតមេត្តាបញ្ជាក់ ។

**ឆ៖** សូមអរគុណលោកមេធាវី ។ នេះគឺជាសំណួរមួយដែលគួរឲ្យចាប់អារម្មណ៍បំផុត ។ បក្សកុម្មុយនីស្តកម្ពុជា បានអនុម័តនូវការប្រើពាក្យ "អង្គការ" ដែលជាពាក្យខ្មែរ ដែលពាក្យអង់គ្លេសហៅថា *អ័រហ្គេណាយហ្សេសិន* ហើយនៅក្នុងស្ថានភាពបែបនេះដែរ នៅក្នុងបក្សកុម្មុយនីស្តវៀតណាម ក៏មានប្រើពាក្យស្រដៀងគ្នានេះដែរ ។ នៅក្នុងដំណាក់កាលផ្សេងៗគ្នា សម្រាប់មនុស្សផ្សេងៗគ្នា នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ពាក្យនេះត្រូវបានគេយល់ថា ត្រូវបានគេយល់ផ្សេងៗគ្នា ។ អ្នកខ្លះយល់ថា ពាក្យនេះគឺយោងសំដៅទៅលើអង្គការទាំងមូលនៃបក្សកុម្មុយនីស្តកម្ពុជា ។ សម្រាប់អ្នកខ្លះទៀត ពាក្យនេះអាចត្រូវបានប្រើនិយាយអំពីបុគ្គលដែលជាសមាជិកណាមួយនៃបក្សកុម្មុយនីស្តកម្ពុជា ហើយក៏មានអ្នកខ្លះទៀតចាត់ទុកថា ពាក្យនេះគឺនិយាយអំពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ។ ហើយដោយប្រហែលជារួមបញ្ចូលទាំងគណៈអចិន្ត្រៃយ៍ និងស្ថាប័នផ្សេងៗទៀតដែលនៅជុំវិញគណៈអចិន្ត្រៃយ៍ផង

ដែរ ដូចជាមន្ទីរ៨៧០ផង ។ នៅក្នុងប្រើដទៃទៀតនោះ ពាក្យ “អង្គការ” ក៏ដូចជានិយាយសំដៅទៅលើ ប៉ុល ពត ឬក៏ជួនកាលទៀត គឺសំដៅទៅលើ ប៉ុល ពត និង នួន ជា ។ ដូច្នេះ យើងមើលទៅហាក់បីដូចជា ពាក្យនេះមានន័យផ្សេងៗគ្នា ។

[១១:៥៦:០៩]

**ស៖** សូមអរគុណលោកបណ្ឌិត ។ អ៊ីចឹងពាក្យថា អង្គការនេះ បើតាមខ្ញុំស្តាប់លោកបណ្ឌិតទៅ គឺយល់ថា សំដៅទៅលើអង្គការបក្ស មិនមែនជារដ្ឋាភិបាលទេ តើអ៊ីចឹងមែនទេលោកបណ្ឌិត? សូមអរគុណ ។

**ឆ៖** បាទ, លោកមេធាវី ។ នេះគឺជាការយល់របស់ខ្ញុំ ។

**ស៖** សូមអរគុណ ។ សុំសួរសំណួរទីប្រាំ ។ នៅស-២១ តើអ្នកណាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម? ខ្ញុំសួរនេះ ដោយសារនៅពីលើតាឌុច អ្នកបញ្ជាតាឌុច វាមានសុន សេន វាមាន នួន ជា ហើយបន្ទាប់មកក្រោមគេ គឺតាឌុច គឺជនជាប់ចោទ ។ អ៊ីចឹង ខ្ញុំសួរថា អ៊ីចឹងឧក្រិដ្ឋកម្មនៅស-២១ ហ្នឹង បើតាមលោកបណ្ឌិត តើសុន សេន ឬតាឌុច?

សូមលោកបណ្ឌិតមេត្តាបញ្ជាក់ ។ សូមអរគុណ ។

**ឆ៖** សូមអរគុណលោកមេធាវី ។ ពាក្យថា “មេដឹកនាំជាន់ខ្ពស់” និងពាក្យថា “អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត” គឺជានិយមន័យច្បាស់លាស់នៃយុត្តិធិការបុគ្គលរបស់តុលាការនេះ ។ ដូច្នេះ ដោយខ្ញុំមិនមែនជាមេធាវី ខ្ញុំត្រូវតែប្រយ័ត្នប្រយែងបំផុតនៅក្នុងការប្រើពាក្យពេចន៍ទាំងនេះ ។ លើសពីនេះទៅទៀតតាមការយល់ដឹងរបស់ខ្ញុំ នេះជាភារកិច្ចរបស់អង្គសវនាការនេះ ដើម្បីធ្វើការកំណត់ តើអ្នកណាគេជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅស-២១ ។ ក៏ប៉ុន្តែ ប្រាកដណាស់ គឺថាខ្ញុំនឹងឯកភាពជាមួយលោកថា នួន ជា, សុន សេន និងជនជាប់ចោទនេះ គឺពាក់ព័ន្ធទាំងអស់នៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនោះ ហើយពួកគេ គឺមានការទទួលខុសត្រូវរៀងៗខ្លួនចំពោះឧក្រិដ្ឋកម្មទាំងនោះ ។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចៗ មេធាវី ដោយមានបញ្ហា ។

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០១:០៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការតាំងសំណួររបស់មេធាវីការពារក្ដីចំពោះអ្នកជំនាញអម្បាញ់មិញនេះ ហាក់ដូចជា ទីមួយ គឺមានការសួរត្រង់ៗចំបញ្ហាតែម្ដង ដើម្បីតម្រូវឲ្យសាក្សីឆ្លើយជាក់លាក់តបនឹងសំណួររបស់ខ្លួន ដែលមិនមែនជាមុខងាររបស់អ្នកជំនាញ ឬសាក្សីទេ ។ ការសន្និដ្ឋានវាយតម្លៃនូវអង្គហេតុ ហេតុការណ៍ភស្តុតាងនានាដែលបានមកពីការសវនាការដេញដោលនៅក្នុងដំណើរការនីតិវិធីសវនាការ វាជាសមត្ថកិច្ច វាជាសមត្ថកិច្ច វាជាសិទ្ធិរបស់ភាគី ដែលនឹងអាចធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់នៃការពិភាក្សាដេញដោល ដោយផ្អែកលើព័ត៌មានផ្សេងៗ លើឯកសារ លើភស្តុតាងនានាដែលទទួលបានពីការដេញដោល ។ ឯការសម្រេចពិចារណាថ្លឹងថ្លែងសម្រេចចុងក្រោយនោះ វាជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះ ។

អ៊ីចឹងអង្គជំនុំជម្រះសូមរំឭកអំពីការតាំងសំណួរប្រភេទបែបចំៗបញ្ហាហើយតម្រូវឲ្យអ្នកជំនាញឆ្លើយតបយ៉ាងជាក់លាក់ដូចនេះ គឺអង្គជំនុំជម្រះឲ្យមេធាវីបញ្ចៀសនូវសំណួររបៀបនេះ ។ ហើយអង្គជំនុំជម្រះគឺនឹងធ្វើការកត់សម្គាល់លើបញ្ហានៃសំណួររបៀបនេះ ដើម្បីមិនអនុញ្ញាតឲ្យសួរសំណួររបៀបនេះទៀតទេ ហើយឬក៏មិនឲ្យសាក្សី ឬក៏អ្នកជំនាញពាក់ព័ន្ធ គឺមិនឲ្យឆ្លើយតបនឹងសំណួរបែបនេះទេ ។ ហើយលោកមេធាវីការពារក្ដីគួរតែត្រូវបានសួរពាក់ព័ន្ធទៅនឹងខ្លឹមសារនៃរបាយការណ៍ដែលគាត់ធ្វើមានលក្ខណៈជាទូទៅ ។ ហើយចំពោះលទ្ធផលយ៉ាងណានោះ គឺមានការកត់ត្រាទុក ហើយធ្វើការសរសេរសន្និដ្ឋានចុងក្រោយនៃកិច្ចដំណើរការនីតិវិធី វាយតម្លៃ ដើម្បីបានទទួលការដំណើរការសវនាការទៅបានល្អ ។

សូមអញ្ជើញមេធាវីការពារក្ដីអាចបន្តសំណួរសួរដល់ចំពោះអ្នកជំនាញរូបនេះបាន ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ដែលបានរំឭកថាមិនឲ្យសួរសំណួរត្រង់ៗ ។

**ស៖** សូមលោកបណ្ឌិតពន្យល់ តើប្រធានស-២១ វាខុសនឹងប្រធានមន្ទីរសន្តិសុខ ឬប្រធានគុកដទៃទៀតត្រង់ណាខ្លះ? ឬក៏វាដូចគ្នា? សូមអរគុណ ។

**ឆ៖** សូមអរគុណលោកមេធាវី ។ នៅក្នុងការយល់ឃើញរបស់ខ្ញុំ ប្រធានស-២១ គឺវាមានលក្ខណៈខុសពីប្រធានមន្ទីរសន្តិសុខផ្សេងៗ ចំពោះបញ្ហាមួយចំនួន ។

[១២:០៥:១០]

ទីមួយ គឺទីតាំងប្រតិបត្តិការរបស់ស-២១ គឺគ្រប់គ្រងនិងប្រតិបត្តិការទូទៅនៅលើផ្ទៃប្រទេស ។ មិនមានប្រធានមន្ទីរសន្តិសុខណាគាត់មានសមត្ថកិច្ចគ្រប់គ្រងលើ គ្មានការប្រតិបត្តិការលើប្រទេសទាំងមូលនោះទេ ។ ដូច្នេះហើយ នេះជាភាពខុសគ្នានៃប្រធាន ស-២១ និងប្រធានមន្ទីរសន្តិសុខផ្សេងៗ ។

ទីពីរ គឺការរាយការណ៍ដោយផ្ទាល់ទៅថ្នាក់លើរបស់ប្រធានស-២១ ។ ប្រធានស-២១ គឺគាត់ធ្វើការរាយការណ៍ផ្ទាល់ទៅជួរដឹកនាំជាន់ខ្ពស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ជារៀងរាល់ថ្ងៃ ហើយគាត់រាយការណ៍តាមលក្ខណៈផ្ទាល់ខ្លួនរបស់គាត់ ។ ហើយខ្ញុំមិនបានដឹងថា ប្រធានមន្ទីរសន្តិសុខផ្សេងៗទៀតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ មានទំនាក់ទំនងនិងមុខងាររាយការណ៍ផ្ទាល់ចំពោះបក្សកុម្មុយនីស្តកម្ពុជានោះទេ ។

ទីបី ប្រធានស-២១ ខុសពីប្រធានមន្ទីរសន្តិសុខដទៃៗទៀត គឺដោយសារទីតាំងប្រតិបត្តិការរបស់មន្ទីរនេះ គឺទីតាំងនេះ វាធំជាងទីតាំងផ្សេងហាសិបដង ហើយវាធំជាងពីររយដង ជាងមន្ទីរសន្តិសុខផ្សេងៗទៀត ។

ដោយសារមូលហេតុទាំងបីនេះហើយ គឺខ្ញុំសូមបញ្ជាក់ថា ប្រធាន ស-២១ គឺខុសពីប្រធានមន្ទីរសន្តិសុខផ្សេងៗទៀត ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកបណ្ឌិត សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរ ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ហ្វ្រង់ស្វ័រ រូ មានសំណួរច្រើនទេ ដែលមានការប៉ុនប៉ងក្នុងការសួរទៅអ្នកជំនាញរូបនេះ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ គឺខ្ញុំចង់សួរសំណួរទៅសាក្សីអ្នកជំនាញ ប៉ុន្តែនៅពេលនេះ ដែលជាពេលសម្រាកនោះទេ ។ ប៉ុន្តែ មុនពេលដែលយើងធ្វើការឈប់សម្រាកញ៉ាំអាហារថ្ងៃត្រង់ គឺខ្ញុំអាចសួរអ្នកជំនាញឲ្យធ្វើការអនុវត្តការងារមួយចំនួន ដែលខ្ញុំស្នើសុំគាត់ឲ្យបង្ហាញ និងធ្វើនៅចំពោះមុខអង្គសវនាការ ។ ដូច្នេះហើយ គឺខ្ញុំគួរតែស្នើសុំគាត់នៅពេលនេះ ដើម្បីឲ្យគាត់អាចធ្វើការងារនេះក្នុងពេលឈប់សម្រាក ។ ហើយយើងទៅលើបញ្ហានេះ នៅពេលដែលយើងត្រឡប់មកវិញ ។

[១២:០៨:៥១]

សំណួររបស់ខ្ញុំគឺទាក់ទងទៅនឹងបញ្ហាជាក់លាក់មួយចំនួន ហើយវាពាក់ព័ន្ធទៅនឹងតារាងអង្គការចាត់តាំង ដែលអស់លោក លោកស្រី អាចពិនិត្យមើលឃើញនៅក្នុងកថាខណ្ឌ១៣៣ នៃរបាយការណ៍របស់គាត់ ។ ហើយខ្ញុំចង់ឲ្យលោក អេតធេសាន់ ខ្ញុំចង់សួរគាត់ឲ្យធ្វើការពេញទៅលើតារាងអង្គការចាត់តាំងនេះ ដោយផ្អែកទៅលើកថាខណ្ឌ១១៥ របស់គាត់ នៅក្នុងរបាយការណ៍ ។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ កថាខណ្ឌ១១៥ នៃរបាយការណ៍របស់គាត់ លោកជំនាញគឺបានលើកឡើងថា យោងតាមរបាយ-ការណ៍មកពីអគ្គសេនាធិការកងទ័ពបដិវត្តន៍ នៅក្នុងខែមីនា ឆ្នាំ១៩៧៧ កងទ័ពបដិវត្តន៍មានចំនួនប្រហែល៦១០០០ នាក់ ហើយបានបែងចែកជាប្រាំបួនកងពល មានកងពល៧០៣, ៣១០... ។ល ។ ដូច្នេះយើងឃើញមានកងពលធំចំនួនប្រាំបួន កងវរសេនាធំឯករាជ្យចំនួនបី កងវរសេនាធំលេខ១៥១, ៤៨៨... ។ល ។ និងមន្ទីរមួយចំនួនទៀត គឺមន្ទីរស-២១ មន្ទីរ៦៣ និង ៦២ ។ ដូច្នេះ ខ្ញុំសូមសួរលោកជំនាញ ខ្ញុំសូមស្នើឲ្យលោកជំនាញឲ្យបញ្ចូលនៅក្នុងតារាងរបស់គាត់នូវកថាខណ្ឌនេះ ថាតើស-២១ គឺវាស្ថិតនៅក្នុងតារាងអង្គការចាត់តាំងនោះនៅត្រង់ណា? ដូច្នេះហើយគឺការងារនេះ ខ្ញុំសូមស្នើសុំឲ្យលោកអេតធេសាន់ ធ្វើនៅក្នុងពេលអាហារថ្ងៃត្រង់ ។

**ប្រធានអង្គជំនុំ៖**

លោកបណ្ឌិតស្តាប់បានទេ អំពីការប៉ុនប៉ងរបស់មេធាវីដែលនឹងអាចធ្វើសវនាការដេញដោលចំពោះលោកក្នុងនាមជាអ្នកជំនាញនៅក្រោយពេលអាហារថ្ងៃត្រង់នេះ? ដោយមេធាវី ហ្វ្រង់ស្វ័រ រ៉ូ បានលើកឡើងនូវបញ្ហាមួយចំនួនដែលជាការប៉ុនប៉ងក្នុងការពិភាក្សាដេញដោលចំពោះលោក និងឲ្យលោកបង្ហាញនៅក្រោយពេលពិសាអាហារថ្ងៃត្រង់ ។ ការធ្វើដូច្នេះគឺជាការល្អមួយ ដែលនឹងធ្វើឲ្យមានការត្រៀមលក្ខណៈជាមុន ហើយនិងពន្លឿននៃកិច្ចពិភាក្សាដេញដោលផងដែរ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ ហេតុអ្វីបានជាលោកលើកតែមន្ទីរស-២១តែប៉ុណ្ណោះ នៅក្នុងតារាងអង្គការចាត់តាំង ហើយមិនលើកមន្ទីរផ្សេងៗទៀត ដែលលោកបានលើកឡើងនៅក្នុងកថាខណ្ឌ១១៥?

**លោក ក្រេក អេតធេសាន់៖**

បាទ, លោកចៅក្រមសូមអរគុណ។ គឺខ្ញុំអាចអនុវត្តការងារនេះបាន និងអាចជម្រាបបាន ។

មន្ទីរស-២១ ជាអង្គភាពពិសេសមួយ ដូចដែលយើងបានពិភាក្សាកាលពីម្សិលមិញ ពេលខ្លះមន្ទីរ ស-២១ នេះ គឺយើងហៅថាជាសាខាពិសេស ។ ដូច្នេះ វាបានបង្ហាញអំពីលក្ខណៈពិសេសរបស់មន្ទីរមួយនេះ ។ វាមិនមែនជាអង្គភាពយោធាមួយដែលទៀងទាត់ ដែលសម្រាប់គ្រប់គ្រងភស្តុភានោះទេ ។ មន្ទីរនេះគឺជាសមាសធាតុមួយរបស់អគ្គសេនាធិការ ហើយមន្ទីរនេះ តួនាទីរបស់មន្ទីរនេះវាមានលក្ខណៈខុសពីមន្ទីរផ្សេងៗទៀត ដែលមាននៅក្នុងជួរអគ្គសេនាធិការ ។ ហើយមន្ទីរនេះ មិនមែនជាមន្ទីរប្រយុទ្ធក្នុងសមរ-ភូមិនោះទេ គឺវាជាមន្ទីរប្រតិបត្តិការមួយ ។

ដូច្នេះ ខ្ញុំៗ ដោយសារបញ្ហានេះគឺខ្ញុំគិតថា វាសមក្នុងការដាក់បញ្ចូលនៅក្នុងតារាងរចនាសម្ព័ន្ធរដ្ឋាភិបាល ជាជាងការដាក់បញ្ចូលនូវមន្ទីរផ្សេងៗទៀត ដែលជាមន្ទីរប្រតិបត្តិការប្រយុទ្ធប្រឆាំងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។ នេះហើយជាហេតុផលរបស់ខ្ញុំក្នុងការដាក់បញ្ចូលមន្ទីរនេះចូលទៅក្នុងតារាងរចនាសម្ព័ន្ធរដ្ឋាភិបាល ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ប៉ុន្តែ មេធាវីការពារក្តី សូមឲ្យអ្នកជំនាញ ដែលជាអ្នកជំនាញនៅទីនេះ គឺគាត់អនុវត្ត និងធ្វើការងារមួយចំនួន ។ ខ្ញុំចង់ឲ្យគាត់បង្ហាញនៅក្នុងតារាងនេះ ថាតើអង្គភាពទាំងអស់នោះគួរតែដាក់នៅកន្លែងណា? ហើយខ្ញុំគិតថាវាជាបញ្ហាមួយដែលល្អ ដើម្បីអនុញ្ញាត និងស្នើសុំគាត់ឲ្យធ្វើដូច្នេះ ។ ដូច្នេះខ្ញុំនៅរក្សាការស្នើសុំរបស់ខ្ញុំដដែល ។

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញគឺ បើខ្ញុំស្តាប់មិនច្រឡំទេ គឺលោកបណ្ឌិតបានឆ្លើយនឹងសំណួររបស់ខ្ញុំហើយ គាត់នឹង គាត់អាចធ្វើបាន ។ មិនអ៊ីចឹងទេលោកបណ្ឌិត? អ្វីដែលជាការស្នើឡើងរបស់មេធាវីការពារក្តីអំពីកថាខណ្ឌមួយចំនួន ដែលមានការប៉ុនប៉ងក្នុងការលើកឡើងដេញដោលនៅរសៀលនេះ ដោយមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ក្រេក អេតឆេសាន៖**

បាទ, ខ្ញុំបានឆ្លើយថាខ្ញុំអាចធ្វើបាន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលត្រូវពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះនឹងបន្តដំណើរការនីតិវិធីសវនាការចាប់ពីនៅម៉ោងមួយកន្លះរសៀល

នេះ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។ ហើយភាគីដូច្នោះដែរ និងលោកបណ្ឌិតផង គឺសូមអញ្ជើញមកម្តងទៀត គឺនៅរសៀលនេះ ដើម្បីធ្វើការបន្តនូវកិច្ចពិភាក្សាដេញដោលក្នុងនាមលោកជាអ្នកជំនាញបន្ត ។

*[សវនាការសម្រាកពីម៉ោង ១២:១៦នាទី ដល់ម៉ោង ១៣:៥០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ ហើយជាកិច្ចបន្តនេះសូមប្រគល់វេទិកាជូនទៅមេធាវី ហ្វ្រង់ស្វ័រ រ៉ូ ដែលជាមេធាវីការពារជនជាប់ចោទ អាចឡើងធ្វើសំណួរពាក់ព័ន្ធទៅនឹងសាក្សីអ្នកជំនាញ ក្រេក អេតឆេសាន់ ។ សូមអញ្ជើញលោកមេធាវី ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំព្យាយាមសួរសំណួរទាំងអស់ដែលខ្ញុំមាន ទៅលើលោកអ្នកជំនាញឲ្យចប់នៅចុងរសៀលថ្ងៃនេះតែម្តង ។ ខ្ញុំចង់ជម្រាបប្រាប់លោកអង្គចៅក្រមថា នៅថ្ងៃទី៨ ខែមិថុនា នោះ គឺខ្ញុំមិនមានវត្តមាននៅទីនេះទេ រហូតដល់ថ្ងៃទី១១ ទើបខ្ញុំត្រឡប់មកវិញ ។ ខ្ញុំសូមជូនដំណឹងនេះដល់អង្គសវនាការ ។ ដោយសារខ្ញុំមានភារកិច្ចដែលត្រូវបានបំពាក់ឲ្យខ្ញុំដោយអគ្គលេខាធិការអង្គការសហប្រជាជាតិនៅប្រទេស ឡេបាណន់ ។ ដូច្នេះ សហសេវិករបស់ខ្ញុំនឹងជំនួសខ្ញុំក្នុងអំឡុងពេល ៣ថ្ងៃ ដែលខ្ញុំអវត្តមាននៅខែក្រោយ ។

**ស៖** សួរស្តីលោក អេតឆេសាន់ សូមអរគុណចំពោះការអត់ធ្មត់របស់លោក ។ តើលោកត្រៀមខ្លួនជាស្រេចក្នុងការឆ្លើយសំណួររបស់ខ្ញុំហើយឬ?

**ឆ៖** បាទ, ខ្ញុំត្រៀមខ្លួនហើយៗលោកមេធាវី ។

**ស៖** លោក អេតឆេសាន់ ខ្ញុំគិតថា ពីពេលមុនគឺលោកធ្វើការ ឬក៏លោកផ្តល់ ឬក៏រួមវិភាគទានឲ្យអង្គការមួយជាឈ្មោះថា អង្គការឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាមែនទេ?

**ឆ៖** ពិតមែនហើយ ត្រឹមត្រូវហើយលោកមេធាវី ។

**ស៖** តើពេលនុ៎ង លោកគឺជាបុគ្គលិករបស់ *ឌីស៊ីខេម* ឬក៏លោកជាទីព្រឹក្សារបស់ *ឌីស៊ីខេម* នៅពេលនោះ?

**ឆ៖** នៅក្នុងឆ្នាំ៩៥ ខ្ញុំគឺជាផ្នែកមួយនៃក្រុមដែលបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ហើយបន្ទាប់មកខ្ញុំក្លាយទៅជានាយកនៃមជ្ឈមណ្ឌលនោះ នៅក្នុងរយៈពេលពីរឆ្នាំបន្ទាប់មក ។

**ស៖** ដូច្នេះ គឺលោកបានចាកចេញនៅឆ្នាំ៩៧ ឬ? មានន័យថា ពេលនុ៎ងលោកបានចេកចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជានៅឆ្នាំ៩៧ ឬ?

[១៣:៥៤:៣៧]

**ឆ៖** នៅចុងឆ្នាំ៩៦ ខ្ញុំបានឈប់ធ្វើជានាយកនៅមជ្ឈមណ្ឌលនោះ ពេលនោះខ្ញុំដើរតួរជាទីប្រឹក្សាមជ្ឈមណ្ឌលនោះម្តង ។

**ស៖** ហើយលោកជាទីប្រឹក្សាឲ្យមជ្ឈមណ្ឌល *ឌីស៊ីខេម* ហ្នឹងអស់រយៈពេលប៉ុន្មានឆ្នាំដែរ?

**ឆ៖** ខ្ញុំមិនអាចប្រាប់ឲ្យបានពិតប្រាដកនូវចំនួនពេលវេលានោះទេ ពីព្រោះខ្ញុំមិនបានចាំច្បាស់ ប៉ុន្តែ ខ្ញុំបានបំពេញតួនាទី គឺខ្ញុំបានធ្វើកិច្ចសន្យាចំនួនពីរ ដែលក្នុងកិច្ចសន្យាទាំងពីរហ្នឹង ខ្ញុំមានតួនាទីប្រឹក្សា គឺស៊ីពេលប្រហែលជា៣ឆ្នាំ សម្រាប់កិច្ចសន្យាទាំងពីរនោះ ។

**ស៖** តើលោកនៅធ្វើការជាមួយការិយាល័យសហព្រះរាជអាជ្ញានៅ អ.វ.ត.ក ហ្នឹងអត់រយៈពេលប៉ុន្មានឆ្នាំ?

**ឆ៖** គឺចាប់ផ្តើមពីខែកក្កដា ឆ្នាំ២០០៦ ។

**ស៖** ដូចដែលត្រូវបានលើកឡើងដោយលោកស្រីចៅក្រម ខាត់វ៉ាយថ៍ លោកបានសរសេរ និងជាអ្នកនិពន្ធសៀវភៅជាច្រើន ដោយយោងទៅលើការស្រាវជ្រាវរបស់លោក ។ ហើយលោកពេលនុ៎ងមានកិត្តិនាម គឺជាអ្នកជំនាញដែលមានបទពិសោធន៍យ៉ាងច្រើនទៅលើបញ្ហានេះ ។ តើត្រឹមត្រូវទេ?

**ឆ៖** លោកមេធាវី នេះជាការត្រឹមត្រូវហើយ ដោយសារខ្ញុំបានសរសេរសៀវភៅជាច្រើនស្តីអំពីខ្មែរក្រហម ។ ហើយខ្ញុំគឺទុកឲ្យមហាជនធ្វើការវាយតម្លៃទៅលើការងាររបស់ខ្ញុំនេះ ។

**ស៖** បាទ ខ្ញុំអាចធានាប្រាប់លោកថា គឺលោកមានកិត្តិនាមល្បីល្បាញណាស់ ។ ឥឡូវនេះនិយាយអំពីសំណួររបស់ខ្ញុំម្តង ។ នៅពេលដែលយើងចាប់ផ្តើមការពិភាក្សាគ្នា ឥឡូវនេះគឺជាសំណួរទីមួយរបស់ខ្ញុំ ហើយជាសំណួរដែលសំខាន់បំផុត។

អំពីចំណេះដឹងរបស់លោកក្នុងនាមជាអ្នកស្រាវជ្រាវ គឺថា បានន័យថា នៅពេលបច្ចុប្បន្ននេះ

ហើយលោកក៏ត្រូវតែចាំផងដែរថា ភារកិច្ចរបស់លោកបច្ចុប្បន្ននៅជាមួយការិយាល័យសហព្រះរាជអាជ្ញា ។ ដោយសារកត្តាទាំងពីរនេះ តើលោកស្ថិតនៅក្នុងស្ថានភាពមួយដែលអាចឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំបាន ក្នុងនាមខ្លួនជាជនឯករាជ្យ ហើយនិងមិនចំពាក់ចំពិនជាមួយនឹងភាគីណាមួយទេ ហើយដែលថា ចម្លើយរបស់លោកដែលនឹងផ្តល់ឲ្យខ្ញុំនឹងគឺវាអាចផ្ទុយទៅនឹងយុត្តិសាស្ត្ររបស់ខាងសហព្រះរាជអាជ្ញាផងដែរនោះ ។

**ឆ៖** ខ្ញុំពិតជាគិតដូច្នេះ ។

**ស៖** បាទ, ខ្ញុំជឿទៅលើលោក ។ សូមអរគុណ ។

តើលោកអាចប្រាប់ខ្ញុំបានទេ ប្រសិនបើយើងពិនិត្យមើលលិខិតទាំងប្រាំបួននោះឡើងវិញ ដែល ស៊្វ ម៉េត បានបញ្ជូនមក ឌុច ។ ហើយនៅក្នុងរបាយការណ៍របស់លោក លោកផ្អែក ឬក៏យោងទៅលើលិខិតតែបីទេ ។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីពាក្យសម្តីរបស់លោកស្រី ស្វតហ្សឺនស្គី ដែលគាត់បានលើកឡើងអំពីចំណុចនោះ ។ នៅពេលដែលលោកធ្វើសេចក្តីព្រាងទៅលើរបាយការណ៍របស់លោក តើពេលហ្នឹងលោកបានដឹងអំពីលិខិតទាំងប្រាំបួននេះ ឬក៏លោកបានដឹងអំពីលិខិតតែបីទេ? គឺខ្ញុំនិយាយនេះសំដៅទៅលើលិខិតទាំងប្រាំបួន ដែលយើងបានពិភាក្សាគ្នាកាលពីម្សិលមិញ ហើយមានតែលិខិតតែបីទេ ដែលលោកយោងនៅក្នុងរបាយការណ៍របស់លោក ។

**ឆ៖** បាទ, ខ្ញុំយល់សំណួររបស់លោកហើយ លោកមេធាវី ។ នៅពេលដែលខ្ញុំសរសេររបាយ-ការណ៍របស់ខ្ញុំ ខ្ញុំជឿថា ខ្ញុំបានដឹងអំពីសំបុត្រចំនួនប្រាំបីក្នុងចំណោមសំបុត្រទាំងប្រាំបួននេះ ។ ហើយសំបុត្រមួយ លិខិតមួយទៀតហ្នឹង គឺខ្ញុំបានដឹងក្រោយពីខ្ញុំបានបំពេញរបាយការណ៍របស់ខ្ញុំរួចហើយ ។

**ស៖** ដូច្នេះដោយបានដឹងពីសំបុត្រចំនួនទាំង៨នោះ គឺថាលោកជ្រើសរើសតែបីទេ, មែនទេ?

**ឆ៖** ត្រឹមត្រូវហើយ លោកមេធាវី ។

**ស៖** នៅក្នុងសមត្ថភាពរបស់លោកជាអ្នកជំនាញ លោកជឿថាសំបុត្របី ដែលលោកជ្រើសរើសហ្នឹង គឺវាគ្រាប់គ្រាន់ហើយក្នុងការបង្ហាញពីគោលគំនិតរបស់លោក មែនទេ?

**ឆ៖** ជាការត្រឹមត្រូវហើយលោកមេធាវី ។

**ស៖** សូមអរគុណ ។ តើមានរឿងហេតុអ្វីកើតឡើងទៅចំពោះលោក ស៊្វ ម៉េត នោះ? តើលោកបានដឹងទេ?

**ឆ៖** គាត់មិនស្លាប់ទេ ហើយគឺថាគាត់នៅរស់នៅមានសុខភាពធម្មតាទេ បើតាមខ្ញុំដឹងគាត់រស់នៅខេត្តបាត់ដំបងនៅពេលបច្ចុប្បន្ននេះ ។

**ស៖** ហើយលោកមិនដែលមានឱកាសក្នុងការសួរសំណួរគាត់ទេ ស្តីអំពីសំបុត្រអស់ទាំងហ្នឹង? តើមែនទេ?

**ឆ៖** ទេ, មិនមានទេ ។

**ស៖** ឥឡូវនេះ ដោយសារយើងនិយាយអំពីអ្នកដទៃ តើលោកអាចបញ្ជាក់ប្រាប់ខ្ញុំបានទេថា ទាក់ទងទៅនឹងរចនាសម្ព័ន្ធថ្នាក់លើ សុន សេន ដែលជាមេរបស់ ឌុច នោះ ។ តើលោកអាចបញ្ជាក់ប្រាប់ខ្ញុំថា គាត់ហ្នឹងនៅរស់រានមានជីវិតទេ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានរំលំនោះ?

[១៤:០២:០៩]

**ឆ៖** បាទ លោកមេធាវី គឺពេលនុ៎ងគាត់នៅមានជីវិតនៅឡើយទេ បន្ទាប់ពីខែមករា ឆ្នាំ៧៩ មកនោះ ។

**ស៖** តើលោកអាចបញ្ជាក់ប្រាប់បានទៀតទេថា គាត់បានរស់រានមានជីវិត ហើយចូលរួមនៅក្នុងបញ្ហានយោបាយនៅឆ្នាំបន្ទាប់ៗមកទៀតនោះ?

**ឆ៖** បាទ, លោកមេធាវី នេះជាការត្រឹមត្រូវ ។

**ស៖** តើខ្ញុំមានកំហុស ឬប្រសិនបើខ្ញុំនិយាយថា គាត់គឺជាផ្នែកនៃគណៈប្រតិភូ ដែលបានចុះកិច្ចសន្យា កិច្ចព្រមព្រៀងប៉ារីសនៅឆ្នាំ៩១ នោះ?

**ឆ៖** ខ្ញុំគិតថា នេះជាចំណុចត្រឹមត្រូវ ។

**ស៖** លោក អេតឆេសាន់ ជួនកាលនៅពេលដែលលោកនិយាយលោកបានលើកឡើងពីពាក្យថា "ការភ័យខ្លាច" ហើយជួនកាលក៏លោកប្រើពាក្យថា "ភាពរន្ធត់" ផងដែរ ។ តើលោកអាចកំណត់យ៉ាងម៉េចទៅថា របបមួយដែលជារបបគួរឲ្យភ័យខ្លាច ឬក៏គួរឲ្យរន្ធត់នោះ?

**ឆ៖** នេះគឺជាសំណួរមួយដែលគួរឲ្យចាប់អារម្មណ៍ លោកមេធាវី ។ ខ្ញុំអាចកំណត់ថា របបដែលគួរឲ្យភ័យខ្លាច ឬក៏គួរឲ្យរន្ធត់នោះ គឺជារដ្ឋាភិបាលមួយ ឬក៏អង្គការ ឬក៏ស្ថាប័នមួយ ដែលប្រើវិធីហិង្សាតាមទំនើងចិត្ត ដើម្បីបង្ខំអ្នកដែលធ្វើការតវ៉ានឹងខ្លួន ដែលជាសមាជិក ឬក៏មហាជននានាដែលពួកគេចង់ក្តោបក្តាប់នោះ ។

**សៈ** ខ្ញុំមិនគិតថា ខ្ញុំច្រឡំទេ ប៉ុន្តែខ្ញុំអាចចាត់ទុកថា អ្វីទៅជានិយមន័យនៃកម្ពុជាប្រជាធិបតេយ្យ ដែលវាស៊ីគ្នាទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យនោះ ។

[១៤:០៥:០៥]

**ឆះ** តើនេះជាសំណួរឬលោក?

**សៈ** បាទ, នេះគឺជាសំណួរ ។

**ឆះ** ទៅតាមទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំ ថ្នាក់ដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ ជាជាក់លាក់បំផុត គឺប្រើការធ្វើឲ្យភ័យរន្ធត់ ធ្វើឲ្យខ្លបខ្លាចហ្នឹងជាវិធីក្នុងការក្តោបក្តាប់ត្រួតត្រា ។

**សៈ** ឥឡូវនេះ គឺយើងនឹងនិយាយអំពីបញ្ហាជាក់លាក់នេះ ។ ក៏ប៉ុន្តែ មុននឹងយើងចាប់ផ្តើមទៅលើចំណុចនោះ ខ្ញុំចង់សួរសំណួរលោកមួយ ។ នៅក្នុងការស្រាវជ្រាវរបស់លោក លោកបានធ្វើការវិភាគនូវភាសាដែលបានប្រើដោយថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបើសិនជាលោកបានធ្វើការវិភាគភាសាទាំងនោះ ដែលថា ភាសានោះមានន័យយ៉ាងដូចម្តេចនៅក្នុងប្រព័ន្ធនៃការធ្វើឲ្យរន្ធត់នោះ គឺខ្ញុំចង់និយាយក្នុងលក្ខណៈន័យទូលំទូលាយ មិនមែនន័យជាក់លាក់ទេ ។ មានន័យថា តើទាក់ទៅនឹងបញ្ហាភាសានេះ តើលោកអាចមានផ្តល់នូវការអង្កេតជាទូទៅ ទាក់ទងទៅនឹងភាសាដែលប្រើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានដែរឬទេ ទាក់ទងទៅនឹងពាក្យថា ភ័យរន្ធត់ ឬក៏ធ្វើឲ្យគួរឲ្យខ្លាចនោះ?

**ឆះ** លោកមេធាវី ។ ខ្ញុំមិនបានធ្វើការសិក្សាលម្អិតទៅលើភាសា ទាក់ទងទៅនឹងចំណុចនេះទេ ក៏ប៉ុន្តែ ដោយសារខ្ញុំជានិស្សិតនៅក្នុងការសិក្សាពីរបបកម្ពុជាប្រជាធិបតេយ្យអស់រយៈពេលសាមសិបឆ្នាំជាងនោះ ខ្ញុំបានផ្តល់ការគិតមួយចំនួនទៅលើភាសាដែលបានប្រើនោះ ។

**សៈ** ខ្ញុំក៏មិនមានចំណេះដឹងអ្វីលើសពីលោកដែរ ទាក់ទងទៅនឹងភាសាខ្មែរនោះ ហើយខ្ញុំអាចធ្វើការពឹងផ្អែកតែទៅលើការបកប្រែតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ យើងតែងតែឃើញពាក្យដែលប្រើ ថ្នាក់ក្រោមត្រូវគិតអំពីចំណុចនោះ គឺថាពាក្យថ្នាក់ក្រោម ត្រូវគិត ត្រូវយកចិត្តទុកដាក់ ។ ហើយបើសិនជាខ្ញុំនិយាយឲ្យបានច្បាស់លាស់នោះ គឺក្នុងកថាខណ្ឌ១២១នៃរបាយការណ៍ដ៏ល្អរបស់លោក។បាននិយាយអំពី សុន សេន នៅថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៧៦ គឺនៅកថាខណ្ឌ១២១នោះ ។ លោកបាននិយាយថា សុន សេន បានដាស់តឿនមេបញ្ជាការរបស់ខ្លួន ដកស្រង់ថាឲ្យគិតអំពីការទប់ទល់នឹងខ្មាំង ទាំងក្នុង និងទាំងក្រៅ ។ ហើយបានបញ្ជាឲ្យបញ្ជាការទាំងនុំង យកចិត្តទុកដាក់ ដូចខ្ញុំដូចជាមានការភ្ញាក់ផ្អើល ពីព្រោះអីគឺនៅក្នុងឃ្លានេះមិននិយាយថា អ្នកត្រូវតែលុបបំបាត់។ ប៉ុន្តែ គាត់

បាននិយាយថា អ្នកត្រូវតែបំបាត់ទាំងស្រុង នៅសមត្ថភាពអាក្រក់នោះ ប៉ុន្តែ គឺគាត់ដាក់ថា អ្នកត្រូវយកចិត្តទុកដាក់ ...។ល ។ ដូច្នេះ ទាក់ទងទៅនឹងការប្រើវាក្យស័ព្ទអស់ទាំងហ្នឹង នៅក្នុងឯកសារផ្សេងៗទៀតនោះ ខ្ញុំគ្រាន់តែចង់ដឹងថា តើចំណុចនេះមានឥទ្ធិពលទៅលើលោកទេ? ឬក៏ដូចថានៅពេលឥទ្ធិពលហ្នឹងមានមកលើខ្ញុំនោះ?

[១៤:០៩:២៣]

**ឆ៖** មេធាវី, ខ្ញុំគិតថា ខ្ញុំមិនឯកភាពទៅនឹងការវិភាគរបស់លោកទេ ប្រសិនបើលោកអានប្រយោគទាំងមូលបន្តពីកន្លែងដែលលោកចាប់ផ្ដើមអម្បាញ់មិញ គឺមានការនិយាយបន្ថែមទៀតថា យកចិត្តទុកដាក់កម្ទេចពួកសមាសភាពមិនល្អឲ្យបានទាំងស្រុងចេញពីបក្ស នេះគឺជាឃ្លាពេញនៃអ្វីដែលលោកបានលើកឡើងអម្បាញ់មិញនេះ ។

**ស៖** អ្វីដែលខ្ញុំចង់លើកឡើងនោះគឺថា មិនមានការធ្វើការបញ្ជាផ្ទាល់ទេ ។ ក៏ប៉ុន្តែ មានន័យថាប្រជាជននោះ ត្រូវបានគេបង្គាប់ឲ្យធ្វើការគិតទៅលើគោលនយោបាយរបស់បក្ស ។ តើអ្វីដែលខ្ញុំយល់នេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ការយល់របស់ខ្ញុំនោះ គឺលោកមេធាវី នៅក្នុងវគ្គអប់រំនេះ ដែលមានមេបញ្ជាការកងពលសុន សេន គឺគាត់ធ្វើការងារដែលយើងដឹងថា គឺជាការឃោសនាលើមាគ៌ាបក្ស បានន័យថា ធ្វើយ៉ាងណាអ្នកថ្នាក់ក្រោមរបស់គាត់យល់យ៉ាងច្បាស់ អំពីគោលនយោបាយរបស់បក្ស ហើយនិងតួនាទីរបស់ពួកគេនៅក្នុងការអនុវត្តគោលនយោបាយទាំងអស់នោះ ។

**ស៖** នេះក៏ជាអ្វីដែលខ្ញុំយល់ផងដែរ ការងារតួនាទីរបស់គាត់នៅក្នុងការអនុវត្តគោលនយោបាយតើនេះជាអ្វីដែលលោកយល់ លោកចង់និយាយនោះ ឬក៏យ៉ាងម៉េច គឺតួនាទីរបស់ពួកគេក្នុងការអនុវត្តគោលការណ៍នយោបាយដោយផ្ទាល់ខ្លួនរបស់ពួកគេ?

**ឆ៖** គឺអញ្ចឹងមែន ។

**ស៖** នេះខ្ញុំនិយាយអំពីភាសាដែលបានប្រើប្រាស់ ហើយនិងបញ្ហាចោទដែលពាក់ព័ន្ធទៅនឹងបញ្ហាមួយទៀត ដែលលោកបានលើកឡើង គឺទាក់ទងទៅនឹងបញ្ហាការសម្លាប់ លោកបានបង្ហាញកាលពីព្រឹកម្សិលមិញ ឆ្លើយតបទៅនឹងសំណួររបស់លោកចៅក្រម ឡាវែន៍ ។ ចៅក្រមបានសួរទៅកាន់ជនជាប់ចោទ ហេតុអ្វីបានជាឈ្មោះថ្នាក់លើមិនមានការសរសេរបញ្ជាក់? ជនជាប់ចោទបានបញ្ជាក់ថា ដោយ-សារតែគឺជាទម្លាប់នៃការអនុវត្តការងារ ។

យោងតាមការស្រាវជ្រាវរបស់លោក នៅក្នុងរបបនោះ ថាតើមានគោលនយោបាយនៃការលាក់បាំងការសម្លាប់ដែរឬទេ? ដែលបានពន្យល់ថា ទោះបីជាឯកសារនោះសម្លាត់យ៉ាងណាក៏ដោយ គឺឈ្មោះរបស់ ប៉ុល ពត ឬក៏ ឈ្មោះរបស់ នួន ជា ឬក៏ ឈ្មោះរបស់ សុន សេន មិនត្រូវបង្ហាញ និងលាតត្រដាងនោះទេ ។ ហើយធ្វើយ៉ាងណាជៀសវាងការលាតត្រដាងឈ្មោះ ទាំងអស់នោះ ។ តើដូច្នោះដែរឬទេ?

[១៤:១២:៤៣]

**ឆ៖** គឺពិតដូច្នោះមែន ។ ការប្តេជ្ញារក្សាការសម្ងាត់នៅក្នុងកុម្មុយនីស្តកម្ពុជា គឺមានលក្ខណៈតឹងតែងណាស់ ។ ហើយការពន្យល់របស់ជនជាប់ចោទទៅលើបញ្ហានេះ គឺមានលក្ខណៈសមហេតុផល ហើយយើងអាចទទួលយកបាន ។

**សៈ** ដោយយើងមិនចង់និយាយឡើងវិញទាក់ទងទៅនឹងចំណុចជាច្រើន ដែលយើងបាននិយាយរួចហើយនោះ ។ ខ្ញុំចង់ត្រឡប់ទៅវិញសួរលោក អំពីរបាយការណ៍របស់លោក ហើយតាមអ្វីដែលយើងមើលនៅក្នុងរបាយការណ៍នេះ យើងដកនូវចំណុចមួយចំនួន ។ នៅក្នុងនេះ គឺមានចំណុចមួយដែលលោកបានលើកឡើងអំពីវិធីសាស្ត្រ ដែលបក្សកុម្មុយនីស្តកម្ពុជាបានរៀបចំជាឋានានុក្រម ស្តីអំពីអំណាច ។ ហើយលោកបានលើកឡើងយ៉ាងជាក់លាក់ នៅក្នុងមាត្រា១១នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា គឺមាត្រា២៣នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងកថាខណ្ឌ១១នៃរបាការណ៍របស់លោក ។ ខ្ញុំចង់អាននូវផ្នែកនេះ ដែលលោកបានលើកឡើង យោងតាមលក្ខន្តិកៈតួនាទីរបស់គណៈមជ្ឈិម លោកបានពន្យល់អំពីគណៈអចិន្ត្រៃយ៍ ដែលមានតួនាទីនិងទទួលខុសត្រូវទៅលើការងារនេះ គឺយោងតាមលក្ខន្តិកៈតួនាទីរបស់គណៈមជ្ឈិម រួមមានការអនុវត្តមាគ៌ាបក្សទូទាំងប្រទេស ការផ្តល់ការណែនាំដល់គ្រប់ភូមិភាគ តំបន់ និងអង្គការនៅតាមក្រុង និងអង្គការបក្សទាំងឡាយដែលទទួលខុសត្រូវលើអង្គភាពផ្សេងៗនៅទូទាំងប្រទេស ។ ហើយលោកបានលើកឡើងនៅក្នុងកថាខណ្ឌនេះ និងគ្រប់គ្រង និងដាក់ពង្រាយកម្មាភិបាល និងសមាជិកបក្សក្នុងបក្សទាំងមូល ក្តាប់បាន ចំណុចនេះគឺសំខាន់ណាស់ ខ្ញុំសុំបញ្ជាក់ ក្តាប់បានច្បាស់លាស់ជាប់ជានិច្ចនូវជីវប្រវត្តិ ជំហរចាត់តាំងមនោគមវិជ្ជា នយោបាយរបស់ពួកគេ និងអប់រំបញ្ចុះបញ្ចូលជាប់ជានិច្ចដល់ពួកគេ ពាក់ព័ន្ធនឹងនយោបាយមនោគមវិជ្ជា និងអង្គការចាត់តាំង ។

នេះគឺជាកម្មវិធីដែលគេត្រូវអនុវត្តន៍ ឬក៏យ៉ាងម៉េចលោក អេតធេសាន់? គឺជាកម្មវិធីដែលគួរឲ្យតក់ស្លុតទៅលើបញ្ហានេះ ឬក៏យ៉ាងម៉េច?

**ឆ៖** ការផ្តោតទៅលើការក្តាប់បានច្បាស់លាស់ជាប់ជានិច្ចនូវជីវប្រវត្តិ គឺវាទាក់ទងទៅនឹងដំណើរការ សម្រិតសម្រាំងកម្មាភិបាលដោយផ្អែកទៅលើជីវប្រវត្តិទាំងអស់នេះ ។ ដូច្នេះ ខ្ញុំនិយាយថា ពិតជាដូច្នោះមែន ។

[១៤:១៧:១០]

**ស៖** លោកក៏បានលើកឡើងបញ្ជាក់នៅក្នុងសវនាការថ្ងៃទី២១ ខែឧសភា ថា បន្ទាប់ពីការអនុវត្តនោះ មជ្ឈិមបក្ស គឺជាអង្គការដែលដឹងថាមានអ្វីកើតឡើងនៅទូទាំងប្រទេស ។ ថាតើលោកយល់ស្របទៅលើចំណុចនេះដែរឬទេ?

**ឆ៖** ពិតជាដូច្នោះមែន គឺនេះគឺជាការយល់ឃើញរបស់ខ្ញុំលើបញ្ហានេះ ។

**ស៖** ដូច្នេះ អ្វីទាំងអស់ដែលបានបង្កើតឡើង អ្វីដែលបានលាក់បាំងសម្ងាត់ទាំងអស់នោះ ទោះបីជានៅក្នុងខ្សែបណ្តោយក៏ដោយ គឺគណៈមជ្ឈិម គឺជាអង្គការតែមួយគត់ដែលដឹងអំពីការងារទាំងអស់នោះ ។ តើយ៉ាងនេះដែរឬទេ?

**ឆ៖** ជាទូទៅ គឺពិតជាដូច្នោះមែន ។ ទោះបីជាមានលក្ខណៈលើកលែងចំពោះក្រឹត្យក្រមរបស់គេក៏ដោយ ។

**ស៖** ដូច្នេះសូមឲ្យលោកនិយាយពន្យល់បន្ថែម តើការលើកលែងចំពោះក្រឹត្យក្រមរបស់គេនោះ គឺយ៉ាងម៉េច ចំពោះករណីនេះ?

**ឆ៖** គឺថា ជនជាប់ចោទ គឺមិនមែនជាសមាជិកមួយនៃគណៈមជ្ឈិម ។ ប៉ុន្តែ យ៉ាងណាក៏ដោយ គឺជនជាប់ចោទអាចធ្វើការសួរចម្លើយបុគ្គលមកពីគ្រប់ផ្នែកទាំងអស់ និងគ្រប់ថ្នាក់ទាំងអស់ដែលមកពីទូទាំងប្រទេស ។ ហើយដោយសារនៅក្នុងដំណើរការងារទាំងអស់នោះ គឺគាត់បានដឹងថា មានអ្វីកើតឡើងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។

**ស៖** ដូច្នេះគឺគាត់ទទួលបានព័ត៌មាន ហើយគាត់ត្រូវរាយការណ៍ ថាទៅនរណាគេ? ទៅគណៈមជ្ឈិមឬយ៉ាងម៉េច? អ៊ីចឹងបានន័យថា នៅពេលដែលគាត់រាយការណ៍ គាត់រាយការណ៍ទៅគណៈមជ្ឈិម។

**ឆ៖** គឺត្រឹមត្រូវហើយ គឺពិតជាដូច្នោះមែន ។

[១៤:១៩:៥៧]

**ស៖** នៅពេលនេះ គឺខ្ញុំចង់ផ្អែកទៅលើការរៀបចំចាត់តាំងជាទូទៅនៅក្នុងកថាខណ្ឌ៩៩ នៅក្នុងរបាយការណ៍របស់លោក ។ លោកលើកឡើងអំពីគណៈយោធាមជ្ឈិម ហើយលោកបានបញ្ជាក់ថា

ទោះបីមិនមានចែងនៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ដែលជាអង្គការមួយរបស់បក្សកុម្មុយនីស្តកម្ពុជា គឺវាមានសរសេរនិងបញ្ជាក់នៅក្នុងឯកសារនិងចម្លើយផ្សេងៗ ។ ដូច្នេះ យើងឃើញមានគណៈយោធាមជ្ឈិមបក្សដែលលោកបានរៀបរាប់នៅក្នុងរបាយការណ៍របស់លោក ។

**ឆ៖** គឺត្រឹមត្រូវនូវអ្វីដែលលោកបានលើកឡើង ។

**ស៖** តើលោកអាចជម្រាបអង្គសវនាការបានដែរឬទេ? តួនាទីរបស់ សុន សេន នៅក្នុងគណៈយោធាមជ្ឈិមបក្សនេះ តើគាត់មានតួនាទីអ្វី?

**ឆ៖** សុន សេន គឺត្រូវបានគេហៅថា លេខានៃគណៈយោធា គឺមិនមែនជាលេខាក្នុងន័យអ្នកជាថ្នាក់លើនោះទេ ។ ដូច្នេះ គាត់គឺជាអ្នកដែលថ្នាក់ខ្ពស់ ហើយជាអ្នកដែលធ្វើការរាយការណ៍ទៅលើបញ្ហានេះ ។

**ស៖** សូមអនុញ្ញាតពីលោកចៅក្រម គឺអេក្រង់អ្នកបកប្រែមើលអត់ឃើញ ។ បាទ, ឥឡូវមើលឃើញវិញហើយសូមអរគុណ ។

**ឆ៖** ប៉ុល ពត គឺជាប្រធាននៃមជ្ឈិមបក្ស តាមការយល់របស់ខ្ញុំ ។

**ស៖** លោកបានលើកឡើងព្រឹកមិញថា នៅក្នុងទូទាំងប្រទេស គឺគោលនយោបាយយើងឃើញមានអំណាចនៅក្នុងជួរយោធា ហើយនៅទីនេះ យើងឃើញថាប៉ុល ពត អ្នកដែលជាថ្នាក់លើបំផុតនោះគឺគាត់មានតួនាទីជាប្រធានគណៈយោធានៃមជ្ឈិមបក្ស ។ ក៏ប៉ុន្តែ វាមិនមែនជាអ្វីដែលបានប្រកាសជាក់ស្តែងចំពោះគណៈយោធាមជ្ឈិមបក្សនោះទេ ។

**ឆ៖** គឺត្រឹមត្រូវ ។

**ស៖** ដូច្នេះ ប៉ុល ពត ហើយនិង សុន សេន គឺជាអនុ ហើយលោកក៏បានបញ្ជាក់ ប្រាប់យើងនៅក្នុងសវនាការលើកមុន លោកបានរៀបរាប់ជូនយើងខ្ញុំថា សុន សេន ខ្ញុំមិនចាំពាក្យរបស់លោកនោះទេ ។ សុន សេន មិនបានផ្តួចផ្តើមដោយខ្លួនឯងនោះទេ គឺគាត់ត្រូវការរាយការណ៍ទៅ ប៉ុល ពត ។ នេះជាអ្វីដែលខ្ញុំយល់ពីសម្តីរបស់លោក ត្រឹមត្រូវនោះតែម្តង ឬក៏យ៉ាងម៉េច?

**ឆ៖** មេធាវីប្រសិនបើខ្ញុំចងចាំអ្វីទាំងអស់ឲ្យបានត្រឹមត្រូវនោះ គឺខ្ញុំបានរៀបរាប់គោលការណ៍ចម្បងពីររបស់បក្ស ដែលបានចែងនៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ។ ជាពិសេសនោះ គឺសម្ភូហ-ភាពនិយម និងមជ្ឈិមសម្ភូហភាព ។ ហើយគោលការណ៍នេះនៅពេលដែលយើងអនុវត្តនោះ គឺវានាំទៅ

ដល់ការធ្វើសេចក្តីសម្រេចដោយផ្អែកលើសមូហភាព ។ នេះគឺជាអ្វីដែលខ្ញុំយោងទៅលើចំណុចទាំងអស់នេះ ប្រសិនបើខ្ញុំមិននិយាយខុសទៅលើចំណុចទាំងអស់នេះទេ ។

**ស៖** តើលោកអាចជម្រាបបានទេថា សុន សេន អាចធ្វើសេចក្តីសម្រេចដោយមិនចាំបាច់មានការយល់ព្រមពី ប៉ុល ពត ។ នេះជាអ្វីដែលលោកចង់ផ្តល់ន័យក្នុងន័យហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** មិនមែនទេ គឺខ្ញុំមានន័យផ្ទុយពីហ្នឹង ។ ទោះបីជាចំណុចនេះវាអាចពិតក៏ដោយ គឺអង្គការទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចនោះ គឺមានដូចជាគណៈអចិន្ត្រៃយ៍ ឬក៏គណៈយោធានៃមជ្ឈិមបក្ស ដែលនឹងធ្វើសេចក្តីសម្រេចទៅលើគោលការណ៍ទូទៅនិងគោលការណ៍ទូលំទូលាយ ។ ហើយនៅក្នុងករណីមួយចំនួនទៀត ចំណុចពិស្តារទៅនឹងការអនុវត្តនោះ គឺវាទាក់ទងទៅនឹងការទទួលខុសត្រូវរបស់អង្គការដែលទទួលខុសត្រូវលើការអនុវត្ត ។

**ស៖** លោកបាននិយាយប្រាប់ខ្ញុំថា អង្គភាពអង្គការចាត់តាំងដូចជាគណៈយោធានេះ គឺអនុវត្តគោលនយោបាយទូទៅ ដែលអនុម័តដោយបក្ស ។ តើយើងយល់ស្របទៅលើចំណុចនេះដែរឬទេ? បានន័យថា នៅក្នុងសកម្មភាពការងាររបស់ពួកគេ គឺគេអនុវត្តទៅតាមគោលនយោបាយរបស់បក្សនោះ ។

**ឆ៖** ខ្ញុំសូមអភ័យទោស ខ្ញុំហាក់ដូចជានិយាយបញ្ឆោក់ប្រាប់លោកខុសទៅលើចំណុចនេះ ។ គឺខ្ញុំនិយាយផ្ទុយពីហ្នឹងទេ ។ គណៈយោធាមជ្ឈិមបក្ស គឺបង្កើតគោលនយោបាយហើយស្វែងរកគោលនយោបាយរបស់ខ្លួន ហើយអង្គការផ្សេងទៀត គឺគាត់ទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយ ។

**ស៖** គឺខ្ញុំយល់ច្បាស់ហើយទៅលើចំណុចទាំងអស់នេះ ។ ខ្ញុំសូមបន្តទៅលើប្រជាធិបតេយ្យប្រមូលផ្តុំ ដែលលោកបាននិយាយអម្បាញ់មិញនេះ ។ ហើយខ្ញុំចង់ធ្វើការផ្តោតទៅលើចំណុច និងផលប៉ះពាល់មួយទាក់ទងទៅនឹងប្រមូលផ្តុំដាច់ខាត នៅពេលដែលយើងនិយាយអំពីរបបនេះ ។ ផលលំបាកមួយនោះ គឺដូចដែលលោកបានលើកឡើងនៅក្នុងកថាខណ្ឌ២៦ ។ មន្ទីរ៨៧០ គឺត្រូវការរាយការណ៍ និងលើកឡើងជូន ខៀវ សំផន និងលើកឡើងបញ្ហាផ្សេងៗ ហើយជាពិតទៅលោកបានបង្ហាញនូវបញ្ជីដែលបានរៀបរាប់យ៉ាងច្រើនទៅលើចំណុចទាំងអស់នេះ ។

[១៤:២៨:០៩]

**ឆ៖** តើលោកមេធាវីសំដៅលើវាក្យខណ្ឌមួយណា?

**ស៖** គឺកថាខណ្ឌ១៤៦ ។

**ឆ៖** វាហាក់ដូចជាអត់ដូចអ្វីដែលលោកបានលើកឡើង ។

**ស៖** ប្រហែលជាកថាខណ្ឌ១៤១ ប៉ុន្តែ អាចជាកថាខណ្ឌ១៩ ផងដែរ ។ នៅពេលដែលលោកនិយាយអំពីការរាយការណ៍ប្រចាំសប្តាហ៍ គឺវាមិនមែនកថាខណ្ឌ១៤៦ នោះទេ ។ (សូមអភ័យទោសគឺកថាខណ្ឌ១៤៦ គឺជាកំហុសរបស់យើងខ្ញុំ)

គឺខ្ញុំគិតថា ការដកស្រង់ពាក្យសម្តីនោះ គឺត្រឹមត្រូវជាក់ស្តែងតែម្តង មាននិយាយនៅជើងទំព័រលេខ៣៤០ ។ អ៊ីចឹងយើងមើលលេខយោងនៅចុងទំព័រហ្នឹង៣៤០ គឺក្នុងកថាខណ្ឌ១៤៦ គឺទាក់ទងទៅនឹងផ្នែកដែលនិយាយអំពីការទំនាក់ទំនងនៅជិតចុងរបាយការណ៍របស់លោក។

ឧទាហរណ៍ មានរបាយការណ៍យ៉ាងច្រើនជូនចំពោះ ខៀវ សំផន នៅមន្ទីរ៨៧០ គឺកថាខណ្ឌ១៤៦ ។ ដូច្នេះ សំណើររបស់ខ្ញុំសូមឲ្យបំភ្លឺលើបញ្ហាគឺបញ្ហានេះ គឺផ្តោតលើចំណុចនេះ ។ យើងអាចគិតទៅលើអ្វីដែលលោកបានរៀបរាប់ គឺចំនួនរបាយការណ៍គឺវាទទួលបានជារៀងរាល់ថ្ងៃមកពីមន្ទីរ៨៧០ ។ តើដូច្នេះដែរឬទេ ឬក៏ខ្ញុំយល់ខុស?

**ឆ៖** ទេ ខ្ញុំមិនគិតថា ដូច្នេះទេ ។

*(អ្នកបកប្រែមិនអាចឮសំឡេងលោក អេតធេសាន់បានទេ ។ បាទឥឡូវឮហើយ)*

ខ្ញុំគិតថាអ្វីដែលលោកលើកឡើងគឺត្រឹមត្រូវហើយ គឺថាមានរបាយការណ៍ច្រើនណាស់ ដែលមានជាប្រចាំដែលត្រូវបានបញ្ជូនមកមន្ទីរមជ្ឈិម ។

**ស៖** នេះជាសំណួរដាច់តែឯងមួយ នៅក្នុងបណ្ណសារនៃមន្ទីរ៨៧០ តើមានគេរកឃើញបណ្ណសាររបស់មន្ទីរ៨៧០ ដែរឬទេ?

**ឆ៖** បើសិនជាយើងសន្មតថាមន្ទីរ៨៧០ ពិតជាមានបណ្ណសារមែននោះលោកមេធាវី គឺខ្ញុំគិតថាបណ្ណសារហ្នឹង នឹងត្រូវបានគេបំផ្លាញចោលទាំងស្រុងតែម្តងហើយនៅពេលណាមួយនោះ ប្រហែលជានៅមុនពេលការចាកចេញពីទីក្រុងភ្នំពេញ ។

ឧទាហរណ៍ ចំនួនតូចនៃការប្រាស្រ័យទាក់ទងគ្នារបស់មន្ទីរ ៨៧០ ហ្នឹងត្រូវបានគេរកឃើញនៅឯទីតាំងផ្សេងៗទៀត ។

**ស៖** តើលោកឯកភាពជាមួយនឹងខ្ញុំទេ? ទាក់ទងទៅនឹងលទ្ធភាពមួយដែលថា ពាក្យដែលលោកប្រើ ឬក៏អ្នកជំនាញដទៃទៀតប្រើថា រហូតដល់ដំណាក់កាលចុងក្រោយ ប៉ុល ពត មិនបានជឿនៅក្នុងការចុះចាញ់សង្គ្រាមនោះទេ ។ ដូច្នេះ គឺថាគាត់បានចាកចេញនៅដំណាក់កាលចុងក្រោយ ។ ដូច្នេះខ្ញុំមិនដឹងទេថា តើពួកគេមានឱកាសនៅក្នុងការបំផ្លាញឯកសារនៅក្នុងបណ្ណសាររបស់មន្ទីរ៨៧០ នោះដែរ

ឬទេ? ប៉ុន្តែ នោះគឺជាគ្រាន់តែជាសំណួរដាច់ផ្សេងដែលខ្ញុំចង់លើកឡើងតែប៉ុណ្ណោះ ។

ឥឡូវនេះ ខ្ញុំចង់ឲ្យយើង ធ្វើការបន្តទៅលើបញ្ហាទាក់ទងទៅនឹងការចាត់តាំង និងមាគ៌ានយោបាយ ។ ខ្លួនលោកផ្ទាល់ លោកបានដកស្រង់នូវសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ហើយសហសេវិករបស់ខ្ញុំ គឺលោក ការ សាវុត្ថ កាលពីព្រឹកមិញនេះបានរំឭកឡើងវិញពីអ្វីដែលលោកបាននិយាយ ដែលថាសេចក្តីសម្រេចចិត្ត ចុះថ្ងៃទី៣០ មីនា ឆ្នាំ៧៦ នោះ ដែលបង្ហាញទៅតាមលំដាប់សម្រាប់ធ្វើការកម្ទេច ឬក៏ប្រហារជីវិតទាំងក្នុង និងក្រៅជួរ ។ នេះគឺជាបញ្ហាដែលគេផ្តល់ឲ្យទៅស្ថាប័នមួយចំនួន ឬក៏ផ្តល់អំណាចឲ្យទៅស្ថាប័នមួយចំនួនក្នុងការធ្វើសេចក្តីសម្រេចនៅក្នុងការសម្លាប់ ។ ដូច្នេះគឺថាយើងបានឯកភាពគ្នាថា សេចក្តីសម្រេចចិត្តរបស់គណៈអចិន្ត្រៃយ៍នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ បានសម្រេចទៅលើចំណុចអស់ទាំងហ្នឹង ។ មានន័យថា ជាទូទៅ គោលនយោបាយទូទៅ គឺការប្រហារនិងសម្លាប់នៅខាងក្នុងនិងខាងក្រៅជួរ តើត្រឹមត្រូវដែរឬទេ?

[១៤:៣៤:៤១]

**ឆ៖** លោកមេធាវី ខ្ញុំអាចនិយាយថា សេចក្តីសម្រេចចុះថ្ងៃទី៣០ មីនា ឆ្នាំ៧៦ នៅក្នុងទម្រង់មួយដែលវាខុសបន្តិចពីអ្វីដែលលោកលើកឡើង ។ ខ្ញុំយល់ថា ការសម្លាប់ក្រៅច្បាប់នៅក្នុង និងក្រៅជួរបក្ស នៅក្នុងនិងក្រៅជួរ គឺបានកើតមានឡើងមួយរយៈមុនរួចទៅហើយ នៅពាសពេញទីកន្លែងទាំងអស់ក្នុងទឹកដីកម្ពុជា ដែលស្ថិតក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជានៅរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ទោះបីជាសេចក្តីសម្រេចចិត្តចុះថ្ងៃ ទី៣០ ខែមីនា ឆ្នាំ១៩៧៦ ជាផ្លូវការ បង្កើតផ្តល់ឲ្យមានការសម្លាប់បែបនេះក៏ដោយ ហើយនិងការប្រើពាក្យពេចន៍ជាក់លាក់មួយចំនួន យើងក៏អាចធ្វើការបកស្រាយថា សេចក្តីបញ្ហានេះ គឺគ្រាន់តែជាការបញ្ជាក់ទៅលើការអនុវត្តដែលមានរួចជាស្រេចមកហើយនោះ ។

**ស៖** នៅពេលដែលលោកនិយាយអំពីការអនុវត្ត តើខ្ញុំអាចនិយាយថា គឺគោលនយោបាយ និងការអនុវត្តដែលមានរួចជាស្រេចមកហើយនោះ តើខ្ញុំអាចនិយាយបានដូច្នេះទេ?

**ឆ៖** បាទ, មេធាវី ខ្ញុំគិតថា នេះគឺវាមានហេតុផលសមរម្យហើយក្នុងការនិយាយបែបនេះ ។

**ស៖** លោកមិនបាននិយាយច្រើនទេ អំពីសេចក្តីសម្រេចនៅខែតុលា ឆ្នាំ១៩៧៥ ។ តើលោកអាចនិយាយបញ្ជាក់បន្ថែមទេ ទាក់ទងទៅនឹងសេចក្តីសម្រេចនោះ? គឺសេចក្តីសម្រេចចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ដែលជាសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ ហើយជាទូទៅមិនត្រូវបានគេយកយោងប៉ុន្មានទេទាក់ទងទៅនឹងសេចក្តីសម្រេចនោះ ។ នៅក្នុងភាសាបារាំង គឺមានលេខ 00292868 រហូតដល់លេខ

00292886 ។ នៅក្នុងភាសាខ្មែរដែលជាភាសាដើមនោះ មានលេខ ERN00019108 រហូតដល់លេខ 00019126 ។

ដូច្នេះ ជាដំបូង តើលោកអាចបញ្ជាក់បានទេ ដើម្បីឱ្យសវនាការយល់ដឹងច្បាស់លាស់ទាំងអស់គ្នា តើនរណាគេនៅក្នុងអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកខាងអគ្គសេនាធិការ និងខាងផ្នែកសន្តិសុខនោះ ។ តើនរណាគេត្រូវបានចាត់តាំងឱ្យកាន់តំណែងនេះ?

**ឆ៖** ខ្ញុំអាចបញ្ជាក់បានលោកមេធាវី។ ខ្ញុំគិតថា នៅចុងទំព័រទី៦ នៃអត្ថបទដើមជាភាសាខ្មែរ និងនៅខាងដើមភាសា៧ នៃច្បាប់ភាសាខ្មែរដែលជាច្បាប់ដើមនោះ ដោយមានទំព័រ៤ ឬក៏៥ នៃច្បាប់ជាភាសាអង់គ្លេស ។ ឯកសារនេះ និយាយអំពីការងារយោធាទាក់ទងទៅនឹងការរៀបចំសេនាធិការ ។

ចំណុចទីមួយ និយាយអំពីការចែកភារកិច្ច ហើយបាននិយាយថា ផ្នែកនយោបាយ គឺសមមិត្តខៀវ នេះគឺជាឈ្មោះក្រៅរបស់ សុន សេន ។

[១៤:៤០:០២]

**ស៖** នៅទំព័រទី១ ដែលមានជាភាសាអង់គ្លេស និងបារាំង នៅក្នុងកថាខណ្ឌទី៦ ក៏មានការយោងទៅលើឈ្មោះសមមិត្ត ខៀវ ដែរ ដែលគាត់ទទួលបន្ទុកខាងផ្នែកសេនាធិការនិងសន្តិសុខ ។ តើលោកអាចបញ្ជាក់អង្គសវនាការបានទេ តើគាត់នឹងត្រូវបានគេចាត់តាំងដោយរបៀបណា?

**ឆ៖** លោកមេធាវីខ្ញុំមិនជឿថា ខ្ញុំអាចប្រាប់លោកបានទេ ឬក៏ប្រាប់ឱ្យបានពិស្តារនោះទេ ក្រៅពីការប៉ាន់ស្មានឡើងថា នោះគឺជាសេចក្តីសម្រេចចិត្តរួមរបស់គណៈអចិន្ត្រៃយ៍ និង/ឬ របស់គណៈយោធាមជ្ឈិម ។ ហើយគណៈយោធាមជ្ឈិមបានធ្វើសេចក្តីសម្រេច ហើយត្រូវបានធ្វើជាសេចក្តីរាយការណ៍ទៅគណៈមជ្ឈិម ។ ខ្ញុំគិតថា យើងអត់មានព័ត៌មានអ្វីនៅពេលបច្ចុប្បន្ននេះ ដើម្បីធ្វើការកំណត់ថា តើដំណើរហ្នឹង ត្រូវបានធ្វើឡើងយ៉ាងដូចម្តេចនោះ?

**ស៖** អ្វីដែលខ្ញុំសួរនោះ គឺប្រហែលជាអាចបញ្ហានៃការបកប្រែ អ្វីដែលខ្ញុំចង់សួរនោះគឺថា ខ្ញុំចង់ឱ្យលោកនិយាយប្រាប់យើងថា នៅចំណុចទី៦ តើមានគេថា សមមិត្តខៀវហ្នឹង ក៏ទទួលបន្ទុកខាងផ្នែកសេនាធិការ និងសន្តិសុខ ។ តើនេះគឺជាអ្វីដែលលោកមាននៅលើឯកសាររបស់លោកដែរឬទេ?

**ឆ៖** *(អ្នកបកប្រែមិនបានឮសំឡេងលោក អេតធេសាន់ទេ)* ។

**ស៖** អ៊ីចឹង យើងបានដឹងថា នៅថ្ងៃទី៩ ខែតុលា--

**ប្រធានអង្គជំនុំ៖**

និយាយម្តងទៀត ព្រោះមិញអ្នកបកប្រែអត់បានស្តាប់ចម្លើយលោកបណ្ឌិតឆ្លើយតបនឹងចុងក្រោយនេះទេ ។ សូមលោកបណ្ឌិតបញ្ជាក់ចម្លើយសាជាថ្មីម្តងទៀត ដើម្បីឲ្យអ្នកបកប្រែអាច បកប្រែបាន និងធ្វើកត់ក្នុងប្រតិចារឹកបាន ។

**លោក ក្រេក អេតធេសាន់៖**

ពិតជាបានលោកប្រធាន ។ ខ្ញុំបានធ្វើការបញ្ជាក់ទៅលើសំណួររបស់មេធាវីការពារក្តីថា នៅក្នុងចំណុចទីមួយនៃរបៀបវារៈ នៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ នៅចំណុចទី៦ បានចែងថា សមមិត្ត ខៀវ គឺទទួលបន្ទុកលើសេនាធិការ និងសន្តិសុខ ។

[១៤:៤៣:៣៦]

**លោក ហ្វេង់ស្វ័រ រូ៖**

**ស៖** ដូច្នេះ ជាមួយនឹងឯកសារនេះ គឺយើងមានភស្តុតាងបង្ហាញថា នៅខែតុលា ឆ្នាំ១៩៧៥ គឺថា គាត់បន្ទុកលើសេនាធិការនិងសន្តិសុខ រួចទៅហើយ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ត្រឹមត្រូវហើយមេធាវី ។

**ស៖** ដូច្នេះ យើងអាចបន្តទៀត ។ ដើម្បីពិនិត្យទៅមើលរបបនោះ ហើយនៅក្នុងរបាយការណ៍របស់លោក ហើយដូចដែលលោកបានថ្លែងនៅក្នុងអង្គសវនាការ ដែលថា របបនោះគឺពឹងផ្អែកទៅលើការបញ្ចូលមនោគមវិជ្ជា ហើយរបបនេះអាស្រ័យលើការបញ្ចូលមនោគមវិជ្ជា ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈនៅត្រង់មាត្រាទី២៣ ។

**ឆ៖** បាទ, ត្រឹមត្រូវហើយលោកមេធាវី ប្រហែលជាដូច្នេះហើយ ។

**ស៖** នៅអំឡុងពេលជាច្រើន លោកបាននិយាយអំពីវគ្គបណ្តុះបណ្តាលដែលជាទៀងទាត់ត្រូវបានធ្វើឡើងនៅតាមអង្គភាព ឬក៏នៅថ្នាក់មូលដ្ឋាន ឬក៏នៅថ្នាក់មជ្ឈិម ។ ហើយលោកបាននិយាយថា ជនណាម្នាក់នឹងអាចទទួលព័ត៌មានពីមាគ៌ានយោបាយ ហើយជាពិសេសជាងនេះទៅទៀត គឺមាគ៌ានយោ-បាយត្រូវបានគេយកមកអនុវត្តនៅពេលនោះ ។ ដូច្នេះ ខ្ញុំនិយាយថា អំពីការបញ្ចូលមនោគមវិជ្ជាដែលមានលក្ខណៈជាប្រព័ន្ធស្តីអំពីមាគ៌ានយោបាយ មាគ៌ារបស់បក្ស តើអ្វីដែលខ្ញុំលើកឡើងនេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ទេ, មិនដូច្នេះទេ លោកមេធាវី ។ លោកនិយាយថា នរណាម្នាក់ អាចនឹងត្រូវបានទទួលព័ត៌មានអំពីពីមាគ៌ាបក្ស ។ ខ្ញុំវិញនិយាយថា សមាជិកណាម្នាក់របស់បក្សនោះឯង ។

**ស៖** នេះគឺជាអ្វីដែលខ្ញុំចង់និយាយ គឺសមាជិកនៃបក្សណាមួយ ឬក៏នរណាម្នាក់ តើលោកឯកភាពអ៊ីចឹងទេ?

**ឆ៖** *(អ្នកបកប្រែមិនបានឮចម្លើយរបស់លោក អេតធេសាន់ទេ)* ។

**ប្រធានអង្គជំនុំ៖**

មើលមន្ត្រីតុលាការរៀបរយមើល ពិនិត្យមើលទៅមើល តើមានបញ្ហាអីខ្លះ? ពីរដងហើយ ។ មីក្រូហ្វូនរបស់អ្នកជំនាញមានបញ្ហា ។

លោកបណ្ឌិតអាចឆ្លើយម្តងទៀត ពីព្រោះអម្បាញ់មិញនេះ អ្នកបកប្រែស្តាប់ចម្លើយរបស់លោកមិនបានទេ ហើយមិនអាចបកប្រែបាន ។

[១៤:៤៧:១២]

**លោក ក្រេក អេតធេសាន់៖**

**ឆ៖** បាទ, លោកមេធាវី ។ នោះគឺជាសំណួរដែលលោកសួរ ទាក់ទងទៅនឹងមាគ៌ាបក្ស ដែលត្រូវបានផ្សព្វផ្សាយដល់គ្រប់សមាជិកទាំងអស់របស់បក្ស។ ខ្ញុំឯកភាពជាមួយលោកទៅលើចំណុចនេះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

**ស៖** ដូច្នេះ លោកបានយោងទៅលើវគ្គបណ្តុះបណ្តាលដ៏ច្រើនអស់ទាំងនេះ ជាពិសេសលោកបាននិយាយថា ជនជាប់ចោទហ្នឹង បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលបែបនេះ ហើយពិធីហ្វឹកហ្វឺនហ្នឹង ត្រូវបានគេរៀបចំតាមអង្គភាពយោធានិងនៅស-២១ សម្រាប់បុគ្គលិក ស-២១ ព្រមទាំងកម្មាភិបាលស-២១ ផងដែរ ដែលបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល ដែលជនជាប់ចោទជារៀបចំវគ្គបណ្តុះបណ្តាលអស់ទាំងនុ៎ង ឬមួយដោយ សុន សេន ។ កាលពីព្រឹកមិញនេះ គឺថា យ៉ាងហោចណាស់ សុន សេន បានមក ស-២១ ម្តងដែរ ដើម្បីនិយាយ ឬក៏ធ្វើការផ្សព្វផ្សាយនៅក្នុងវគ្គបណ្តុះបណ្តាលអស់ទាំងហ្នឹង ។ ហើយនេះគឺជាសំណួររបស់ខ្ញុំ ប្រសិនបើនរណាម្នាក់ មិនមែនជាសមាជិករបស់បក្ស ហើយដែលជាកម្មាភិបាល តើគេមានជម្រើសទេក្នុងការចូលរួម ឬក៏មិនរួមនៅក្នុងវគ្គបណ្តុះបណ្តាលបែបនេះ?

**ឆ៖** បាទ, លោកមេធាវី ។ គឺថា នរណាគេក៏មានជម្រើសដែរ ក៏ប៉ុន្តែប្រហែលជាមិនមែនជាការប្រសើរទេ ។

**ស៖** បាទ គឺថាខ្ញុំអាចទទួលបាន នូវការទទួលចម្លើយបែបនេះ ។ អ៊ីចឹង តើនឹងមានអ្វីកើតឡើងទៅសម្រាប់កម្មាភិបាលណាម្នាក់ ដែលថា គាត់មិនចង់ទៅចូលរួមវគ្គបណ្តុះបណ្តាលបែបនេះ?

**ឆ៖** ខ្ញុំគិតថា ហ្នឹងនឹងអាចនាំឲ្យមានការដាក់ពិន័យណាមួយមកលើកម្មាភិបាលនោះ ហើយតើពិន័យក្នុងទម្រង់ណានោះ គឺវាអាស្រ័យទៅលើស្ថានភាពជាក់ស្តែង ។

[១៤:៤៩:៥០]

**ស៖** តើលោកឯកភាពហ្នឹងខ្ញុំទេ ក្នុងការនិយាយថា មានមនុស្សដែលត្រូវបានគេកម្ទេច ដោយក្នុងការប្រើពាក្យថា កម្ទេច ហ្នឹង គឺថាដោយសារគាត់ប្រព្រឹត្តកំហុសអ្វីតិចតួចតែប៉ុណ្ណោះ ហើយអ្នកខ្លះទៀតអាចត្រូវបានគេកម្ទេច គឺមកគ្រាន់តែគាត់មិនបានទៅចូលរួមវគ្គបណ្តុះបណ្តាលបែបនោះ ។ តើលោកឯកភាពនឹងខ្ញុំត្រង់ចំណុចហ្នឹងទេ?

**ឆ៖** ខ្ញុំមិនដែល បានដឹងអំពីការកើតឡើងជាក់លាក់បែបនេះទេ លោកមេធាវី ។ ក៏ប៉ុន្តែមិនមែនជាការលំបាកនៅក្នុងការស្រមើលស្រមៃថា នឹងអាចកើតមាននៅទិដ្ឋភាពបែបនេះនោះ ។

**ស៖** ទាក់ទងនឹងប្រធានបទដដែលនេះ គឺយើងនឹងពិនិត្យឡើងវិញម្តងទៀត ទាក់ទងទៅនឹងជម្រើស ។ ហ្នឹងគឺថា បច្ច័យនៃអ្វីដែលកើតឡើង ថាតើពេលនោះ គេស្តាប់តាមបង្គាប់ ឬក៏មិនស្តាប់តាមបង្គាប់នោះ ។ តើខ្ញុំខុសទេ បើសិនជាខ្ញុំនិយាយថា នៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ បើសិនជាជនណាម្នាក់ជ្រើសរើសមិនស្តាប់បង្គាប់ តើអ្នកនោះនឹងមានបញ្ហាឬ? ហើយដូច្នេះ ជាលទ្ធផលដែលបណ្តាលឲ្យគេស្តាប់បាននោះ?

**ឆ៖** បាទ, ពិតប្រាកដហើយ មិនចាំបាច់សួរទេត្រង់ចំណុចនេះ លោកមេធាវី ។

**ស៖** ទាក់ទងទៅនឹងបញ្ហានៃការចាត់តាំង ការធ្វើមនោគមវិជ្ជា គឺវាស៊ីគ្នាទៅនឹងចំណុចដែលលោកបានលើកពីការចាក់ផ្សាយ ការឃោសនា ជាពិសេសទាក់ទងទៅនឹងទស្សនាវដ្តីទង់បដិវត្តន៍ ។ នេះដែលជាមធ្យោបាយជាឧបករណ៍មួយសម្រាប់ធ្វើការឃោសនានោះ ។ ហើយទស្សនាវដ្តីនេះត្រូវតែអាននេះគឺជាកាតព្វកិច្ច ដែលត្រូវតែអានទស្សនាវដ្តីទង់បដិវត្តន៍នោះ ហើយបើសិនជានរណាម្នាក់មិនព្រមអាននោះ គឺអ្នកនោះឯងនឹងត្រូវបានចាត់ទុកថា ជាក្បត់ជាតិ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំបានឃើញនូវឧទាហរណ៍មួយចំនួន ដែលការខកខានក្នុងការចែកចាយទស្សនាវដ្ដីទង់បដិវត្តន៍នោះ ។ គេចាត់ទុកថាហ្នឹង គឺជាសកម្មភាពក្បត់ ។ បាទ, ពិតមែនហើយ ។

**ស៖** នៅក្នុងកថាខណ្ឌ៦៣ លោកបានដកស្រង់សម្ដីនៅក្នុងផ្នែកមួយ ដែលដកស្រង់ចេញពីទស្សនាវដ្ដីទង់បដិវត្តន៍ ហើយក៏បានសរសេរនៅក្នុងលេខជើងទំព័ររបស់លោកផងដែរ ។ យើងអាចឃើញភារកិច្ចក្នុងការប្រហារខ្មាំងនៅខាងក្នុង ដែលនេះពាក់ព័ន្ធទៅនឹងតួនាទីរបស់យើងគ្រប់គ្នា ។ គ្រប់ថ្នាក់ បក្សទាំងអស់ត្រូវតែទទួលយកតួនាទីដឹកនាំកងទ័ព និងប្រជាជនដើម្បីវាយប្រហារខ្មាំងសត្រូវទាំងអស់ ។ បោសសំអាតឲ្យអស់ បោសសំអាតហើយ បោសសំអាតទៀតមិនចេះចប់ មិនចេះឈប់ឈរ ។ ដើម្បីកម្លាំងបក្សយើងមានភាពបរិសុទ្ធ កម្លាំងដឹកនាំរបស់យើងនៅគ្រប់ជាន់ថ្នាក់ និងគ្រប់ទិសទី មានភាពស្អាតស្អំ គ្រប់ពេលវេលា ។ ជនជាប់ចោទ គឺគាត់បានលើកឡើងថា អ្នកដែលសរសេរទង់បដិវត្តន៍ គឺជាប៉ុល ពត ។ តើលោកយល់ស្របទៅលើការអះអាងដូច្នេះដែរឬទេ?

[១៤:៥៤:៥0]

**ឆ៖** លោកមេធាវី ។ ប្រភពផ្សេងៗទៀតក៏បានរៀបរាប់ថា ប៉ុល ពត គឺជាអ្នកដែលពាក់ព័ន្ធនៅក្នុងការបោះពុម្ពផ្សាយទស្សនាវដ្ដីទង់បដិវត្តន៍ ។ ហើយប្រភពមួយចំនួនទៀត បានអះអាងថា គាត់បានសរសេរគ្រប់ឃ្លោងឃ្លា គ្រប់ពាក្យទាំងអស់ ។ ប៉ុន្តែ ខ្ញុំយល់ឃើញថា ចំណុចនេះ គឺវាមានលក្ខណៈគួរឲ្យយើងជឿណាស់ គឺវាមិនអាចដែលថា គាត់ត្រូវការយកចិត្តទុកដាក់ចំពោះគ្រប់ពាក្យសម្ដីទាំងអស់ ទាក់ទងទៅនឹងការបំពាក់បំប៉នមនោគមវិជ្ជា ទៅដល់កម្មាភិបាលនោះទេ ។

**ប្រធានអង្គជំនុំ៖**

មេធាវីអាចត្រូវ ដល់ម៉ោងអង្គជំនុំជម្រះប្រកាសសម្រាកម្ដៃមីនុត រហូតដល់ម៉ោងបីនិងដប់ប្រាំនាទី សូមអញ្ជើញចូលវិញ ហើយបន្តកិច្ចពិភាក្សាដេញដោយតទៅទៀត ។ ហើយមន្ត្រីតុលាការសម្របសម្រួលរកកន្លែងសម្រាកសមរម្យសម្រាប់លោកបណ្ឌិតជាអ្នកជំនាញផង ។

*[សវនាការសម្រាកពីម៉ោង១៤:៥៦នាទី ដល់ម៉ោង ១៥:១៨នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ មុននឹងផ្តល់វេទិកាជូនទៅលោក ហ្វ្រង់ស្វ័រ រូ ជាមេធាវីការពារក្តី អង្គជំនុំជម្រះសូមប្រកាសនូវសេចក្តីសម្រេចមួយដូចខាងក្រោមនេះ៖

សេចក្តីសម្រេចកែប្រែកាលបរិច្ឆេទចំពោះការផ្តល់យោបល់លើសំណុំរឿង ដែលទទួលបានពីតុលាការយោធា ។ ដោយសារតែមានមូលហេតុមួយចំនួន សំណុំរឿងរបស់តុលាការយោធាទាំងមូលមិនទាន់បានបកប្រែចប់នៅឡើយទេ ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ផ្នែកដែលមិនទាន់បានបកប្រែចប់នោះ គឺមិនមានសារសំខាន់ចំពោះអង្គជំនុំជម្រះក្នុងការធ្វើសេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំនោះទេ ។ អង្គជំនុំជម្រះសាលាដំបូងដឹងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើសំណើសុំដោះលែងជនជាប់ចោទ គឺត្រូវប្រកាសនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ។ អង្គជំនុំជម្រះទទួលស្គាល់ថា ការលំបាកនៃការបកប្រែ ធ្វើឲ្យភាគីមានរយៈពេលតិចក្នុងការផ្តល់យោបល់របស់ខ្លួនលើសំណុំរឿងរបស់តុលាការយោធានេះ ។ ប៉ុន្តែ ដើម្បីឲ្យអង្គជំនុំជម្រះអាចចេញសេចក្តីសម្រេចរបស់ខ្លួនបាននៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងសូមស្នើដល់ភាគីទាំងអស់ឲ្យផ្តល់យោបល់លើសំណុំរឿងនេះ យ៉ាងយូរបំផុតត្រឹមម៉ោងបួនរសៀលថ្ងៃទីមួយខែមិថុនា ឆ្នាំ២០០៩ ។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកានេះទៅមេធាវី ហ្វ្រង់ស្វ័រ រូ ដែលជាមេធាវី ការពារជនជាប់ចោទ ។ អញ្ជើញឡើង អាចតសំណួរសួរពាក់ព័ន្ធទៅនឹងបណ្ឌិត ក្រេក អេតធេសាន់ ដែលជាអ្នកជំនាញ ។ សូមអញ្ជើញលោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ លោក អេតធេសាន់ ខ្ញុំចង់បន្តទៀត ទាក់ទងទៅតាមប្រធានបទនីមួយៗ ដូចដែលមានចែងនៅក្នុងរបាយការណ៍របស់លោក ដែលមានដាក់នៅចំពោះមុខអង្គសវនាការ ។ ដូចដែលខ្ញុំបានប្រាប់ទៅលោកអ៊ីចឹង ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា យើងនឹងនិយាយអំពីការសម្រិតសម្រាំងនៅពេលក្រោយ ។ ប៉ុន្តែ នៅពេលនេះ គឺខ្ញុំផ្តោតអារម្មណ៍ទៅលើគោលនយោបាយទូទៅ និងទៅលើការអនុវត្តគោលនយោបាយទូទៅនៃកម្ពុជាប្រជាធិបតេយ្យ ។

[១៥:២១:៥៤]

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីទំនាក់ទំនងខ្សែបណ្តោយ ហើយខ្ញុំនឹងមិននិយាយអីវែងឆ្ងាយទេ ពីចំណុចនេះ ពីព្រោះយើងបានពិភាក្សាជាលម្អិតមកហើយ ។ ប៉ុន្តែ ខ្ញុំសូមរំឭកលោកថា នៅកថាខណ្ឌទី

៣៦ នៃរបាយការណ៍របស់លោកៗបានបញ្ជាក់ថា គណៈអចិន្ត្រៃយ៍គ្រប់គ្រងទៅលើប្រព័ន្ធទំនាក់ទំនងទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយការទំនាក់ទំនងគ្នានោះត្រូវបានរៀបចំទៅតាមលំដាប់ ហើយដោយមានលក្ខណៈជាខ្សែបណ្តោយយ៉ាងហ្មត់ចត់បំផុត ។ នោះគឺជាអ្វីដែលលោកនិយាយ ហើយពីមុនមកលោកក៏បាននិយាយថា នេះគឺជាអ្វីដែលលោកបានបញ្ជាក់នៅក្នុងដំណើរការនីតិវិធីរហូតមកដល់ពេលនេះ ។

**ឆ៖** បាទ, ជាការត្រឹមត្រូវហើយលោកមេធាវី ។

**ស៖** ហើយលោកក៏បាននិយាយបន្ថែមទៀតថា នេះគឺនៅក្នុងកថាខណ្ឌ៥៦ ទំនាក់ទំនងនៅតាមភូមិភាគត្រូវបានធ្វើឡើងតាមរយៈខ្សែបណ្តោយទៅតាមលំដាប់លំដោយនៃបញ្ជា ហើយបើសិនជាមានបំណងធ្វើការប្រាស្រ័យទាក់ទងគ្នាតាមរយៈទទឹងនោះ ។ នោះមានន័យថា ជាបំណងនៃការធ្វើសកម្មភាពក្បត់ ។ ខ្ញុំចង់លើកអំពីឧទាហរណ៍ទាក់ទងទៅនឹងភូមិភាគ នៅពេលដែលពួកគេធ្វើការប្រាស្រ័យទាក់ទងរវាងភូមិភាគមួយទៅភូមិភាគមួយនោះ គឺត្រូវធ្វើឡើងតាមរយៈមជ្ឈិម ។ តើលោកមានអធិប្បាយអ្វីទេទាក់ទងទៅលើចំណុចនេះ?

**ឆ៖** បាទ, លោកមេធាវី ខ្ញុំជឿថាគំរូនៃការអនុវត្តយ៉ាងតឹងរឹងទៅលើការប្រាស្រ័យទាក់ទងតាមរយៈខ្សែបណ្តោយ គឺជាវិធានមួយដ៏តឹងរ៉ឹងបំផុត លើកលែងតែនៅក្នុងករណីពិសេសជាក់លាក់ណាមួយដែលត្រូវបានអនុញ្ញាតដោយគណៈមជ្ឈិម ។

**ស៖** ដូច្នេះមានន័យថា លោកក៏បានបញ្ជាក់នៅថ្ងៃទី២១ ខែឧសភា ទាក់ទងទៅនឹងសំបុត្ររបស់ ស៊ូ ម៉េត លោកបាននិយាយថា ជនជាប់ចោទត្រូវរាយការណ៍ទៅថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយតាមរយៈ សុន សេន គាត់ត្រូវសហប្រតិបត្តិការជាមួយនឹងកងពលនានា ដើម្បីជួយហើយក្រោយមកទៀត ដើម្បីអនុវត្តនៅក្នុងការធ្វើការសម្រិតសម្រាំងទ្រង់ទ្រាយធំនៅក្នុងអង្គភាពយោធា ។ កាលពីម្សិលមិញនៅពេលព្រឹក បន្ទាប់ពីយើងបានឈប់សម្រាកនៅពេលព្រឹករួចហើយនោះ នៅពេលដែលជនជាប់ចោទបានឆ្លើយទាក់ទងទៅនឹងសំបុត្ររបស់ ស៊ូ ម៉េត នោះ លោក អាឡិច ប៊េត បានសួរទៅលោកហើយលោកបានឆ្លើយទៅតាមកំណត់សម្គាល់ដែលខ្ញុំមាន គឺថាខ្ញុំអត់មានប្រតិចារឹកនៅក្នុងដៃខ្ញុំទេ ខ្ញុំមានតែកំណត់សម្គាល់តែប៉ុណ្ណោះ ។ លោកបានឆ្លើយថា “ការពិតដែលថា ការប្រាស្រ័យទាក់ទងរវាងមេដឹកនាំកងពលនានា និងស-២១ គឺចាំបាច់ត្រូវធ្វើឡើងតាមរយៈខ្សែបណ្តោយ។ ដូច្នេះគឺ ដូចដែលជនជាប់ចោទបានរៀបរាប់អ៊ីចឹង ។ ហើយគំរូនៃការប្រាស្រ័យទាក់ទងគ្នានេះ គឺឯកភាពគ្នា ឬក៏ស៊ីគ្នាទៅ

នឹងវិធីដែលខ្ញុំយល់ថា នេះគឺជាគោលនយោបាយអត្តនោម័តិតែមួយគត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយនិងនៅក្នុងស្ថាប័នយោធាផងដែរ" ។

[១៥:២៦:៣៦]

ដូច្នេះ នេះគឺជាសេចក្តីសន្និដ្ឋានដែលលោកបានធ្វើ នៅចុងបញ្ចប់នៃវគ្គសវនាការពេលព្រឹកកាលពីម្សិលមិញ ។ ហើយនៅចុងបញ្ចប់នៃការពិភាក្សាគ្នាហ្នឹង ទាក់ទងទៅនឹងសំបុត្ររបស់ ស៊ូ ម៉េត ផ្ញើមក ស-២១ តាមរយៈ ស៊ូ ម៉េត លោកនិយាយថា ទម្រង់នៃការប្រាស្រ័យទាក់ទងដែលជនជាប់ចោទបានលើកឡើង គឺវាស៊ីគ្នាទៅនឹងគោលនយោបាយដ៏តឹងរ៉ឹងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ តើដូច្នេះទេលោក?

**ឆ៖** លោកមេធាវី ប្រសិនបើខ្ញុំមិនច្រឡំទេនោះ ខ្ញុំមិនមានឱកាសក្នុងការនិយាយអ្វីបន្តិចសោះកាលពីព្រឹកម្សិលមិញ ។

**ស៖** ខ្ញុំសូមទោសប្រសិនបើសិនជាមានការបកប្រែខុស គឺបន្ទាប់ ខ្ញុំចង់និយាយថា គឺនៅពេលរសៀលពីម្សិលមិញនៅពេលដែលលោក បានសួរលោកនោះ ។

**ឆ៖** បើអ៊ីចឹងបានវាត្រូវ ។

**ស៖** ចំណុចមួយទៀតដែលលោកបានរាយការណ៍នៅក្នុងរបាយការណ៍របស់លោក គឺបានចេញមកពីការពិភាក្សាដែល នៅពេលដែលលោកមានវត្តមាននៅទីនេះ គឺទាក់ទងទៅនឹងនយោបាយក្នុងការធ្វើវិទ្ធង្សនា និងនៅក្នុងការស៊ើបអង្កេត គឺនៅចុងទំព័រ១១៧, ១១៤, ១១២ នៃរបាយការណ៍របស់លោក ហើយខ្ញុំចង់ផ្តោតអារម្មណ៍ទៅលើកថាខណ្ឌទី៨០ (សូមទោស)គឺ៨៩ គឺនៅឃ្លាចុងក្រោយទេ ។ ពាក្យថា "ឈ្លប" ដែលលោកបាននិយាយថា "ឈ្លប" ក៏យកការណ៍ពីប្រជាពលរដ្ឋដើម្បីកំណត់អត្តសញ្ញាណអ្នកមានគំនិតប្រឆាំង ។ នៅពេលយប់ងងឹត ទាហានដើរល្បាតយកការណ៍ ដែលជាឈ្លបនោះ មកពីជួនកាលបានលួចចូលមកលាក់ខ្លួនក្នុងភូមិ ក្រោមផ្ទះ ហើយដើម្បីស្តាប់អ្វីដែលសមាជិកគ្រួសារនិយាយគ្នា ។

[១៥:២៩:៥៣]

ហើយលោកក៏បានបន្ថែមទៀតថា នៅកថាខណ្ឌ៤៥ ការត្រួតពិនិត្យជាក់លាក់ជាអចិន្ត្រៃយ៍របស់ប្រវត្តិរូបនោះ គឺគណៈភូមិភាគបានប្រមូល និងបានពិនិត្យមើលទៅលើប្រវត្តិផ្ទាល់ខ្លួន ដែលភាគី ដែលសមាជិករបស់បក្សនីមួយៗត្រូវតែរៀបចំនូវប្រវត្តិរូបជាប្រចាំ ជាទៀងទាត់ ហើយត្រូវបញ្ជូនទៅបក្ស ។ ហើយលោកក៏បាននិយាយទៀតដែរ នៅក្នុងកថាខណ្ឌទី៨៣ គឺទាក់ទងទៅនឹងរដ្ឋអំណាចនៅតាមឃុំ

ដែលជាអ្នកទទួលបន្ទុកក្នុងការចងក្រងប្រវត្តិរូបរបស់ប្រជាជនដែលរស់នៅក្នុងភូមិរបស់ខ្លួន ។ ហើយត្រូវផ្តល់នូវប្រវត្តិរូបហ្នឹងទៅឲ្យថ្នាក់ស្រុកដើម្បីត្រួតពិនិត្យក្នុងស្វែងរកខ្មាំង ។ តើលោកឯកភាពនឹងខ្ញុំទេ ដែលខ្ញុំនិយាយថា រដ្ឋនេះជារដ្ឋនគរបាល ទៅតាមន័យនៃអ្វីដែលខ្ញុំបានលើកឡើងនេះ?

**ឆ៖** បាទ, លោកមេធាវី ខ្ញុំនឹងរៀបរាប់ដូចគ្នាអ៊ីចឹងដែរ ។

**ស៖** ហើយក្នុងន័យមួយដែលជាសោកនាដកម្មនៅក្នុងចំណុចនេះ នៅពេលដែលយើងមានទស្សនទាននទៅលើចំណុចអស់ទាំងហ្នឹង សំណួររបស់ខ្ញុំ ដែលខ្ញុំចង់លើកឡើងថា តើលោកឯកភាពនឹងខ្ញុំទេ បើសិនជាខ្ញុំនិយាយថា ជាទូទៅគោលនយោបាយ ដែលយើងបាននិយាយមួយម៉ោងមកហើយនេះ គឺត្រូវបានអនុវត្តដោយអ្នកដឹកនាំ ឬក៏ថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាតាំងពីដើមទីមកម្ល៉េះ ហើយលោកក៏បាននិយាយដែរថា គឺនៅមុនថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៦ ទៅម្ល៉េះ ។ ហើយ ឌុច មិនមានតួនាទីអ្វីទេ នៅក្នុងការបង្កើត ឬក៏សម្រេចទៅលើគោលនយោបាយអស់ទាំងនេះ ។

**ឆ៖** ខ្ញុំប្រាកដទេ លោកមេធាវី ដែលថា យើងអាចនិយាយបានដូច្នេះ គឺមានដំណាក់កាលណាមួយគឺនៅមុនពេល នៅពេលដែលរបបនោះត្រូវបានបង្កើតឡើង គឺថ្ងៃទី១៧ មេសា ៧៥ និងរហូតដល់ពេលដែលមានបញ្ជាឲ្យបង្កើតស-២១ នៅថ្ងៃទី១៥ សីហា ៧៥ នោះ ខ្ញុំមិនអាននឹកឃើញឲ្យបានច្បាស់លាស់អំពីសកម្មភាពជាក់លាក់ណាមួយរបស់ជនជាប់ចោទនោះទេ ។ ដូច្នេះ ខ្ញុំមិនដឹងថា តើគាត់នឹងអាច ឬក៏បានមានតួនាទីបំពេញតួនាទីអ្វីនៅក្នុងអំឡុងពេលនោះ?

**ស៖** ដូច្នេះ បណ្ឌិត អេតឆេសាន់ តើជនជាប់ចោទដែលធ្វើជាសមាជិកគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ខ្ញុំមិនគិតថា ដូច្នេះទេ លោកមេធាវី ។

**ស៖** ខ្ញុំគិតថា នៅក្នុងចំណុចមួយនៃរបាយការណ៍របស់លោក គឺគណៈអចិន្ត្រៃយ៍ជាអ្នកសម្រេចទៅលើគោលនយោបាយ ។

**ឆ៖** តាមពិតគឺដូច្នេះហើយ លោកមេធាវី ។

**ស៖** សូមអរគុណ ។ ឥឡូវនេះខ្ញុំចង់និយាយពីការសម្រិតសម្រាំង ។ ខ្ញុំគិតថា ខ្ញុំអាចនិយាយបានថា បើសិនជាលោកអនុញ្ញាតនោះ គឺថាយើងអាចបង្ហាញនូវភាពខុសគ្នា ដើម្បីឲ្យយើងធ្វើការគិតឲ្យបានច្បាស់លាស់ដោយយកហេតុផលមកពិចារណាថា ជាទូទៅការសម្រិតសម្រាំងទូទៅហ្នឹងគឺថា វាមិនមែនស្ថិតនៅក្រោមអំណាចរបស់ជនជាប់ចោទទេ ។ ហើយការសម្រិតសម្រាំងដែលលោកបាននិយាយ

កាលពីព្រឹកមិញ ហើយដែលយើងនឹងត្រូវនិយាយទៀតនៅពេលនេះ គឺថាវិធីសាស្ត្រអាចជាបច្ច័យមួយនៅក្នុងការឲ្យកើតមាននូវការសម្រិតសម្រាំងបែបនេះ ។ សម្រាប់ខ្ញុំ គឺខ្ញុំថាដូចជាមានពីរប្រភេទ ប៉ុន្តែខ្ញុំមិនចង់ឲ្យលោកធ្វើការឆ្លើយភ្លាមៗទៅលើចំណុចនេះទេ ។ ខ្ញុំគ្រាន់តែចង់បង្ហាញពីគំរូទូទៅអំពីចំណុចដែលខ្ញុំនឹងលើកឡើង ។

[១៥:៣៦:០០]

នៅក្នុងរបាយការណ៍របស់លោក ខ្ញុំឃើញអំពីការរៀបរាប់អំពីការធ្វើការសម្រិតសម្រាំងទូទៅ។ នៅក្នុងកថាខណ្ឌ៨០ បានថែងថា នៅតាមភូមិ តាមកងចល័ត អ្នកដែលគេចោទប្រកាន់ថា ជាអ្នកជនសង្ស័យដោយប្រធានឃុំ ការសម្លាប់របស់ពួកគេត្រូវបានធ្វើឡើងនៅថ្នាក់ឃុំ នៅថ្នាក់ស្រុក ។ ហើយនៅក្នុងករណីខ្លះទៀត ប្រធានស្រុក គណៈស្រុកនឹងចេញបញ្ជាឲ្យកងកម្លាំងសន្តិសុខនៅថ្នាក់ឃុំ ឬក៏ឈ្លបធ្វើការសម្លាប់ជនដែលគេសង្ស័យថាជាជនក្បត់ ។ មន្ត្រីដែលធ្វើការនៅថ្នាក់ស្រុកក៏ចេញបញ្ជាឲ្យធ្វើការចាប់ចង នៅថ្នាក់ឃុំ និងនៅថ្នាក់សហករណ៍ បន្ទាប់ពីមានការចោទទៅលើជនទាំងនោះអំពីថាពួកគេជាខ្មែររបស់វៀតណាម ។ លោកបណ្ឌិត អេតឆេសាន់ នៅក្នុងទស្សនៈរបស់លោក ទាក់ទងទៅនឹងតួនាទីរបស់ ឌុច នៅស-២១ តើលោកគិតថា គាត់បានចូលរួមនៅក្នុងការសម្រិតសម្រាំងដែលលោកបានរៀបរាប់នៅក្នុងរបាយការណ៍ នៅក្នុងកថាខណ្ឌទី៨០ របស់លោកដែរឬទេ?

**ឆ៖** ទាក់ទងទៅនឹងការចូលរួមដោយផ្ទាល់ជាបុគ្គល ឬមួយក៏នៅក្នុងទាក់ទងទៅនឹងការបញ្ជាដោយផ្ទាល់ ខ្ញុំគិតថាគាត់មិនមានពាក់ព័ន្ធទេ ។ ទាក់ទងទៅនឹងដំណាក់កាលនៃយុត្តាធិការទៅលើបុគ្គលនេះ ។

**ស៖** សូមអរគុណ ។ ខ្ញុំនឹងបន្តទៀត ។ ខ្ញុំចង់រំឭកថា នៅកថាខណ្ឌទី៦៣ ដែលយើងបានលើកឡើងកាលពីមុននោះ ទាក់ទងទៅនឹងទស្សនាវដ្ដីទង់បដិវត្តន៍ ដើម្បីធ្វើការបោសសម្អាត ហើយបោសសម្អាតទៀត បោសសម្អាតជាបន្តបន្ទាប់នោះ ដូច្នេះ កម្លាំងបក្សរបស់យើងគឺនឹងបរិសុទ្ធ ហើយកម្លាំងដឹកនាំរបស់យើងនៅគ្រប់ជាន់ថ្នាក់ទាំងអស់ និងនៅគ្រប់វិស័យទាំងអស់ គឺស្អាតស្អំរាល់ពេល ។

លោកក៏បាននិយាយដែលថា ទាក់ទងទៅនឹងខ្សាំងនៅក្នុងកថាខណ្ឌ២៥ នៃរបាយការណ៍របស់លោក ដែលថា នយោបាយ គោលនយោបាយរបស់បក្ស ទាមទារឲ្យសមាជិកគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិមគឺត្រូវបានដឹងអំពីស្ថានភាពជាក់ស្តែងនៅថ្នាក់ស្រុក ។ ហើយដើម្បីធានាថាបានដូច្នោះ គឺថាដើម្បីឲ្យកម្មាភិបាលនៅថ្នាក់មូលដ្ឋានបានយល់ដឹងច្បាស់លាស់ នៅក្នុងការលុបបំបាត់ពួកប្រតិកិរិយាប្រឆាំង

បដិវត្តន៍នោះ ។ ហើយលោកក៏បាននិយាយដែលថា នៅចុងឆ្នាំ៧៧ បក្សបានកោះហៅឲ្យធ្វើការពិនិត្យឡើងវិញទៅលើការអនុវត្តរបស់លេខាស្រុកទាំងឡាយ និងការសម្រិតសម្រាំងទៅលើអ្នកដែលអនុវត្តន៍មិនបានល្អ ។ ហើយការអនុវត្តដែលមិនបានល្អនោះ គឺរួមបញ្ចូលទាំងការខកខានដោយមិនបានប្រុងប្រយ័ត្នស្មារតី ឬក៏សមាសភាពមិនល្អ រួមទាំងខ្មាំងដែលបង្កប់នៅផ្ទៃក្នុង ។

ហើយប្រសិនបើខ្ញុំចាំមិនខុសទេនោះ កាលពីព្រឹកមិញនេះ លោកបានផ្តល់នូវការពន្យល់មួយដោយយោងទៅលើការស្រាវជ្រាវរបស់លោកទៅលើសមាជិករបស់គណៈមជ្ឈិមនោះ ដែលបានចុះទៅតាមមូលដ្ឋាន ដើម្បីធ្វើការពិនិត្យមើលទៅលើការអនុវត្តមាគ៌ាបក្សនៅតាមមូលដ្ឋាន ។

ដូច្នេះ សំណួរស្រដៀងគ្នានេះដែរ ដែលខ្ញុំបានសួរពីមុនមកនោះគឺថា ទាក់ទងទៅនឹងគោលនយោបាយទាំងមូល ដូចដែលលោកបានរៀបរាប់នោះ តើលោកឯកភាពនឹងខ្ញុំទេ ក្នុងការនិយាយថា នេះគឺនៅខាងក្រៅយុត្តាធិការរបស់ ឌុច នោះ ឬក៏នៅខាងក្រៅសមត្ថភាពរបសគាត់នោះ?

**ឆ៖** ខ្ញុំមិនយល់ស្របដូច្នេះនឹងមេធាវីនោះទេ យើងអាចនឹកឃើញឡើងវិញ ពេលមួយនោះ គឺនៅថ្ងៃមួយនោះ គឺខ្ញុំអត់ចាំថ្ងៃច្បាស់លាស់ទេ ។ នៅពេលដែលខ្ញុំធ្វើការដេញដោលដោយលោកស្រីចៅក្រម ខាត់វ៉ាយថ៍ ។ លោកស្រីចៅក្រមបានសួរខ្ញុំថា ថាតើមានពេលមួយដែរឬទេ ដែលនៅពេលនោះវាមានចំនួនចាប់ខ្លួននៅក្នុងថ្នាក់ស្រុកច្រើនជាងពេលណាៗទាំងអស់ ។ ហើយក្នុងការឆ្លើយតបទៅនឹងសំណួររបស់លោកស្រីចៅក្រម ខ្ញុំបានលើកឡើងជាក់លាក់លើការសម្រិតសម្រាំង នៅចំពោះកម្មា-ភិបាលភូមិភាគពាយព្យនិងកម្មាភិបាលភូមិភាគបូព៌ា ។ នៅពេលនោះ គឺមានកម្មាភិបាលថ្នាក់ស្រុក គឺគាត់បានជាប់ខ្លួននៅស-២១ ហើយខ្ញុំជឿថាដំណើរការនៃការសម្រិតសម្រាំងនោះ គឺវាជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងអ្វីដែលខ្ញុំបានលើកឡើងពិភាក្សានៅក្នុងកថាខណ្ឌដែលលោកមេធាវីបានចង្អុលយោងនេះ ។

**ស៖** យើងត្រូវតែលើកឡើងអំពីបញ្ហានេះ ប៉ុន្តែ ខ្ញុំគិតថា កថាខណ្ឌ២៥ នៅពេលដែលលោកនិយាយអំពីខ្មាំងលាក់ខាងក្នុងប្រជាជននោះ គឺលោកមិនបានលើកឡើងអំពីការសម្រិតសម្រាំងដែលធ្វើឡើងដោយមជ្ឈិមនោះទេ ប៉ុន្តែ យ៉ាងណាគឺដោយខ្ញុំមិនបានកត់សម្គាល់ទៅលើការឆ្លើយតបរបស់លោកទៅលើបញ្ហានេះ ។ ដូចគ្នានេះដែរ នៅក្នុងកថាខណ្ឌ៧៩ គឺនៅកណ្តាលទំព័រ លោកបាននិយាយថាមជ្ឈិមបក្សគឺជំរុញដំណើរស្វែងរកនិងសម្រិតសម្រាំងខ្មាំងសង្ស័យនៅគ្រប់ជាន់ថ្នាក់របស់អង្គការ ។

ហើយលោកបានដកស្រង់សម្តីថា ដូច្នេះ ត្រូវធ្វើការត្រួតពិនិត្យនៅក្នុងសហករណ៍និងស្រុក ។ យកចិត្តទុកដាក់ត្រួតពិនិត្យថ្នាក់ទាំងនេះ ដោយសារតែថ្នាក់ទាំងពីនេះរស់នៅជាមួយប្រជាជន ។ ថ្នាក់

ផ្សេងៗទៀតក៏ត្រូវធ្វើការត្រួតពិនិត្យផងដែរ ។ ទាំងនេះគឺជាដង្កូវក្នុងសាច់របស់យើង ដែលយើងត្រូវតែជីកគាស់យកចេញ ។

[១៥:៤៥:00]

ចំពោះខ្ញុំកថាខណ្ឌមួយនេះ គឺវាមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ ឌុច នោះទេទេ? ថាតើលោកយល់ខុសពីនេះ ឬយ៉ាងម៉េច? ប្រហែលលោកអាចនិយាយដូច្នេះ ។ ហើយយើងអាចចូលទៅនឹងសំណួរមួយទៀត ដែលយើងអាចដោះស្រាយទៅលើបញ្ហានេះបាន ។

**ឆ៖** ជាការពិតណាស់ ខ្ញុំជឿថា ការលើកឡើងដោយមជ្ឈិមបក្សក្នុងការធ្វើវិសុទ្ធកម្ម អង្គការរបស់បក្សនោះ តាមរយៈការសម្រិតសម្រាំង ឬក៏តាមទម្រង់ដែលត្រូវផ្តល់ទៅលើខ្សែក្សត់ ហើយត្រូវបានលើកឡើងនៅក្នុងនេះ គឺវាទាក់ទងទៅនឹងដង្កូវនៅក្នុងសាច់ ។ ហើយខ្ញុំជឿថា ស-២១ គឺជាមន្ទីរមួយដែលអាចរកឃើញដង្កូវទាំងអស់នោះ ដើម្បីជីកយកចេញ ។

**ស៖** ចំណុចនេះ គឺនាំឲ្យយើងគិតទៅដល់សំណួរមួយ លោកបានរៀបរាប់កាលពីម្សិលមិញ ហើយយើងគួរតែធ្វើការដោះស្រាយដេញដោលទៅលើបញ្ហានេះ ។ ដោយសារតែសំណួរនេះ គឺវាទាក់ទងឲ្យមានការពន្យល់ ។ ចំណុចបឋម ខ្ញុំគួរតែសួរសំណួរមួយចំនួនលើករណីនេះ មុននេះលោក ការសាវុត្ត បានសុំធ្វើការបំភ្លឺពីលោក អំពីចំនួនមន្ទីរសន្តិសុខ ឬក៏មន្ទីរសន្តិសុខដទៃទៀត ដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តើលោកពន្យល់អង្គសវនាការអំពីចំនួននៃមន្ទីរសន្តិសុខទាំងអស់នោះ ដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានដែរឬទេ?

**ឆ៖** គឺបាន ខ្ញុំអាចជម្រាបជូន ទោះបីជាវាមានការលំបាកចំពោះការបកប្រែអីក៏ដោយ គឺមេធាវីមិនដែលបានសួរអំពីចំនួននៃមន្ទីរសន្តិសុខ ដែលគាត់បានបញ្ជាក់នោះទេ ។

នៅក្នុងសំណុំរឿងរបស់យើង ដែលមានលេខ ERN00194821 ដល់លេខ 00194829 ដែលមានលេខសំណុំរឿងឯកសារ D92/1 ឯកសារនេះគឺជាឯកសារភាសាអង់គ្លេស ។ សូមអភ័យទោស ខ្ញុំអត់មានលេខ ERN ជាភាសាបារាំង ឬជាភាសាខ្មែរនោះទេ ។ គឺនៅចុងៗមាត់ខ្ញុំ ហាក់ដូចជាចង់ចាំទៅលើឯកសារនេះ គឺឯកសារចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ដែលមានចំណងជើងថា “មន្ទីរសន្តិសុខ ឬក៏គុក ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ” ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា វាគឺជាបញ្ជីគុក និងមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ ដែលអង្គការមួយនេះបានប្រមូលផ្តុំ និងប្រមូលបាន ។ គឺយើងឃើញមានចំនួនគុកទាំងអស់ចំនួន១៩៥ នៅគ្រប់ទីកន្លែងទាំងអស់ជុំវិញប្រទេស នៅក្នុង

របបកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំបានដឹងថា តាំងពីពេលនោះមក ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា គឺបានកំណត់ និងរកឃើញគុកមួយចំនួនបន្ថែមទៀត ដែលមិនបានចូលនៅក្នុងបញ្ជីមួយដែលគេរៀបចំពីដំបូង ។

[១៥:៥០:២៦]

បន្ថែមទៅលើឯកសារមួយនេះ នៅក្នុងសំណុំរឿងរបស់យើងផងដែរ ដែលមានលេខ ERN 00087303 ដល់លេខ 00087332 គឺជារបាយការណ៍ជាភាសាអង់គ្លេស ដែលបានដកស្រង់ចេញពីសំណុំរឿងលេខ១ ដែលវាជាភាសាអង់គ្លេស ដែលមានលេខ ERN00217576 រហូតដល់លេខ 0021 7578 ។ នៅក្នុងឯកសារនេះជាភាសាបារាំង គឺមានលេខ ERN00292776 ដល់លេខ 00292802 ។ ហើយនៅក្នុងភាសាខ្មែរលេខ ERN គឺ 00233382 ដល់លេខ 00233428 ។

ខ្ញុំសូមអភ័យទោស ខ្ញុំអត់មានលេខសម្គាល់សំណុំរឿងនោះទេ ប៉ុន្តែ យ៉ាងណាក៏ដោយ ឯកសារនេះ គឺវាទាក់ទងទៅនឹងរបាយការណ៍មន្ទីរសន្តិសុខនៅស្វាយស៊ីសុផុន ខេត្តបាត់ដំបង ដែលរៀបចំឡើងអ្នកស្រាវជ្រាវបារាំងមួយរូប ឈ្មោះ ហង់រី ឡូកា តាមការស្នើសុំរបស់សហព្រះរាជអាជ្ញា ។ ឯកសារដកស្រង់នេះ គឺជារបាយការណ៍ដកស្រង់ចេញពីរបាយការណ៍ធំមួយ ប៉ុន្តែ គឺមិនមាននៅក្នុងសំណុំរឿងលេខមួយនោះទេ ។ ហើយឯកសារនេះបានរៀបរាប់អំពីមន្ទីរសន្តិសុខមួយចំនួន ដែលមិនបានបញ្ចូលនៅក្នុងបញ្ជីបោះពុម្ពឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ចំណុចចុងក្រោយ នៅក្នុងដំណាក់កាលស៊ើបសួរបឋម ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា និងនៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ខ្ញុំជឿថា យើងបានរកឃើញមន្ទីរសន្តិសុខមួយចំនួនច្រើនទៀត ដែលមិនបានបញ្ចូលនៅក្នុងរបាយការណ៍ស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏មិនបានបញ្ចូលនៅក្នុងរបាយការណ៍ស្រាវជ្រាវរបស់ ហង់រី ឡូកា ។ គឺខ្ញុំអត់មានពេលនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងការយកឯកសារទាំងអស់នេះ ។ ហើយប្រមូលផ្តុំចងក្រងរួមគ្នា ដើម្បីបង្កើតជាបញ្ជីថ្មីមួយ ដែលអាចបញ្ជាក់ថា តើមានចំនួនមន្ទីរសន្តិសុខទាំងអស់ប៉ុន្មាន ។ ប៉ុន្តែ ខ្ញុំគិតថា វាមន្ទីរសន្តិសុខនេះ វាមានចំនួនច្រើនជាងពីររយ ដែលលើកឡើង និងបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**ស៖** ដោយសារតែលោកលើកឡើងអំពីរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំយល់ថាលោកក៏បានដឹងអំពីការចាត់ថ្នាក់ឯកសារដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ក្នុងនោះគឺបានធ្វើការ

បញ្ជាក់អំពីចំនួនជនរងគ្រោះផងដែរ ។

**ឆ៖** ខ្ញុំដឹងអំពីការធ្វើការងារ ធ្វើការកំណត់ទៅលើចំនួនជនរងគ្រោះ ។

**ស៖** តើលោកអាចជម្រាបអង្គសវនាការបានដែរឬទេ ថាតើមានមនុស្សចំនួនប៉ុន្មាន ដែលមជ្ឈ-មណ្ឌលឯកសារកម្ពុជាបានកំណត់ឃើញ ហើយយើងឃើញថា វាជាចំនួនមួយដែលបានរៀបរាប់ ទាក់ទងទៅនឹងជនរងគ្រោះនៅស-២១?

**ឆ៖** មេធាវី ខ្ញុំត្រូវតែធ្វើការពិនិត្យ និងពិភាក្សាទៅលើបញ្ហានេះ ដោយខ្ញុំកត់សម្គាល់ឃើញថា នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្ដើមការងារទាំងអស់នេះ មជ្ឈមណ្ឌលនេះ គឺមិនមានបទពិសោធន៍ ហើយមិនអាចស្វែងរកយុត្តិសាស្ត្រពីប្រទេសផ្សេងៗ ទាក់ទងទៅនឹងការងារនេះទេ ដើម្បីព្យាយាមធ្វើការស្ទាបស្ទង់ទៅលើករណីនេះ ។ ប៉ុន្តែ យើងឃើញថា មានផ្នូររួមនោះប្រហែលជារាប់ម៉ឺន ប្រហែលជាមួយម៉ឺន ។ ហើយនៅក្នុងដំណាក់កាលដំបូងនោះ ឆ្នាំដំបូងនោះ យើងឃើញថា វាមានរយៈ ដំណើរការងាររបស់គេបានធ្វើឡើងក្នុងរយៈពេលយូរមកហើយ ។ ដូច្នេះ ខ្ញុំពិចារណាឃើញថា ទិន្នន័យមួយចំនួន ចំពោះចំនួននៃជនរងគ្រោះនៅក្នុងឆ្នាំដំបូង នៃគម្រោងស្រាវជ្រាវរបស់គេ គឺត្រូវតែយកមកពិចារណាថា មិនអាចជឿជាក់បាននោះទេ ។ ហើយដើម្បីឆ្លើយតបទៅនឹងសំណួររបស់លោកមេធាវី ប្រសិនបើខ្ញុំអាចរកឃើញឧទាហរណ៍ជាក់លាក់ទៅលើចំណុចនេះ ។

អ៊ីចឹងឃើញថា វាជាផ្នូរនៅខេត្តកំពង់ចាម ស្រុកក្រូចឆ្មារ ដែលទីកន្លែងហៅថា គោកផល ។ ហើយបានលើកឡើងនៅក្នុងឯកសារទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ យើងឃើញថា មានចំនួនជនរងគ្រោះ៥០១០នាក់ ហើយខ្ញុំជឿថា ចំនួនទិន្នន័យនេះគឺត្រឹមត្រូវនោះទេ ។ ហើយប្រសិនបើខ្ញុំគិតពិចារណាទៅលើទិន្នន័យតួលេខនេះ គឺខ្ញុំនឹងធ្វើការកែប្រែនូវចំនួននេះ ។ ហើយផ្នែកទី២ នៃសំណួររបស់លោកដែលបានសួរឡើង គឺវាជាប់ពាក់ព័ន្ធទៅនឹងភ្នំពេញ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺទិន្នន័យរបស់គេទៅលើចំនួនដែលជាជនរងគ្រោះនៅទួលស្លែងនោះគឺមានចំនួន១៥០០០នាក់ ។

[១៦:០០:០៧]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

តើខ្ញុំអាចសុំលេខ ERN និងលេខសំណុំរឿងដែលអ្នកជំនាញបានយោងទៅដល់ឯកសារទាំងអស់នោះដែរ ឬទេ? សូមអរគុណ ។

**លោក ក្រេក អេតឆេសាន់៖**

ខ្ញុំមានសោកស្តាយក្នុងការជម្រាបទៅដល់សហព្រះរាជអាជ្ញាដែលថា ខ្ញុំហាក់ដូចជាធ្វេសប្រហែសក្នុងការកត់យកលេខ ERN ចំពោះឯកសារនេះ ។ ប៉ុន្តែ ខ្ញុំអាចផ្តល់ជូនអង្គសវនាការ នៅពេលណាមួយឲ្យបានលឿនបំផុត ។ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺបានលើកឡើងអត្ថបទនេះស្តីអំពីមន្ទីរកប់សាកសពកន្លែងកប់សាកសព ហើយគឺវាជាឯកសារមួយដែលមិនមានចុះកាលបរិច្ឆេទនោះ ទេ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោកបណ្ឌិត អេតឆេសាន់ សូមអរគុណលោកយ៉ាងខ្លាំងទាក់ទងទៅនឹងការងាររបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា ហើយខ្ញុំគិតថា នេះជាអត្ថប្រយោជន៍មួយ ប៉ុន្តែសំណួររបស់ខ្ញុំនោះ គឺលោកមិនបានឆ្លើយនៅឡើយទេ ។ សំណួររបស់ខ្ញុំច្បាស់លាស់ណាស់ គឺថាតើលោកមានបានដឹងទេអំពីតារាងដែលខាងមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតឡើងនោះ ។ បើសិនជាលោកបានដឹងមែនតើលោកអាចប្រាប់បានទេ? តើនរណាគេ គុកណាជាគុកទីមួយ ហើយមានចំនួនមនុស្សប៉ុន្មាននាក់? គុកណាជាគុកទីពីរ? ទាក់ទងទៅនឹងចំនួនតួលេខរបស់ *ឌីស៊ីខេម* នោះ ហើយថាតើ ស-២១ នុំងខាង *ឌីស៊ីខេម*ចាត់ទុកថាជាឋានៈទីប៉ុន្មាន?

**លោក ក្រេក អេតឆេសាន់៖**

---

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដែលលោកនិយាយអំពីឯកសារមួយ ដែលលោកលើកឡើងនោះ តើលោកអាចផ្តល់លេខយោងបានទេ?

[១៦:០២:១៦]

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

អត់មានលេខយោងទេ ។ នេះគ្រាន់តែជាព័ត៌មានមួយ ដែលត្រូវបានគេបែងចែករួមគ្នា បើសិនជាគាត់អត់ដឹងក៏មិនអីដែរ ។ ប៉ុន្តែ ខ្ញុំជឿថា--

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ខ្ញុំមិនដឹង ថាតើមេធាវីការពារក្តីព្យាយាមបង្ហាញនូវភស្តុតាងថ្មីនៅក្នុងសំណុំរឿង ដោយតាមចូលតាមផ្លូវក្រោយឬក៏យ៉ាងម៉េចទេ ។ បើសិនជាគាត់ធ្វើដូច្នេះមែន គឺបើសិនជាគាត់ចង់បង្ហាញភស្តុតាង

មែនត្រូវធ្វើដាក់តាមលក្ខណៈជាផ្លូវការ ដើម្បីដាក់តាំងនៅចំពោះមុខអង្គសវនាការ ។ ប៉ុន្តែ ខ្ញុំយល់ថា នេះគឺជាការព្យាយាមដាក់បញ្ចូលភស្តុតាងនៅក្នុងសំណុំរឿង ដែលឯកសារនេះមិនមានពីមុនមក ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

មិនមែនដូច្នេះទេ ។ ខ្ញុំចង់សួរទៅលើអ្នកជំនាញ អំពីចំណេះនេះ តើគាត់ដឹងឬក៏មិនដឹង បើគាត់ដឹង គាត់និយាយថាគាត់ដឹងទៅ បើគាត់មិនដឹងគ្រាន់តែគាត់និយាយថា គាត់មិនដឹងទៅវាមិនពិបាកណាស់ណានោះទេ ។ ខ្ញុំមិនព្យាយាមក្នុងការបង្ហាញឯកសារថ្មីណាមួយនោះទេ ខ្ញុំគ្រាន់តែចង់សួរទៅលើជនអ្នកជំនាញដែលគាត់បានស្បថរួចហើយ ថាតើគាត់មានបានដឹងអំពីការចំណាត់ថ្នាក់របស់ *ឌីស៊ីខេម* ដែរឬអត់? តែប៉ុណ្ណឹងទេ ។

**ឆ៖** បាទ លោកមេធាវី គឺខ្ញុំអត់បានដឹងទេ ។

**ស៖** វាស្រួលតែប៉ុណ្ណឹងទេតើ ។ ឥឡូវនេះ ដើម្បីនិយាយទៅលើសំណួរដ៏សំខាន់របស់ខ្ញុំ ខ្ញុំចង់ឲ្យរំឭកដល់លោក អំពីអ្វីដែលលោកបាននិយាយនៅក្នុងដំណើរការនីតិវិធីទាក់ទងទៅនឹងអ្វីដែលលោកហៅថាការស្តាប់តាមបង្គាប់ ហើយលោកបានបង្ហាញថាបក្សកុម្មុយនីស្តកម្ពុជាបង្កើតឲ្យមានការស្តាប់បង្គាប់ និងការឲ្យអនុវត្តតាមវិន័យ ដូចដែលមានបានចែងនៅក្នុងមាគ៌ាបក្ស ហើយកម្មាភិបាលបានព្យាយាមអស់ពីសមត្ថភាពដើម្បីអនុវត្តនូវមាគ៌ាគោលនយោបាយរបស់បក្ស តើនេះជាអ្វីដែលលោកនិយាយមែនទេលោក អេតឆេសាន់?

[១៦:០៤:៤៦]

**ឆ៖** បាទ, ខ្ញុំគិតថាខ្ញុំនិយាយប្រហាក់ប្រហែលគ្នានេះ បាទពិតជាអ៊ីចឹងហើយ ។

ស៖ ហើយបើយោងទៅតាមលោកវិញ តើលោកជឿថា ឌុច ជាផ្នែកមួយនៃកម្មាភិបាលដែលព្យាយាមអស់ពីសមត្ថភាពក្នុងការអនុវត្តនូវគោលនយោបាយរបស់បក្សនេះ?

**ឆ៖** បាទ ។

**ស៖** លោកបាននិយាយកាលពីព្រឹកមិញថា ឌុច អាចជួបជាមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា បាន តើលោកអាចបញ្ជាក់ត្រង់ចំណុចបានទេ?

**ឆ៖** បាទ, លោកមេធាវី ។ ឌុច គឺថាអាចទៅជួបនៅតាមដំណាក់កាលផ្សេងៗគ្នា ជាមួយនឹង សុន សេន ហើយនិង នួន ជា ដែលទាំងពីរនាក់នេះ គឺជាសមាជិករបស់គណៈអចិន្ត្រៃយ៍ ហើយនិងសមាជិកផ្សេងៗទៀតរបស់គណៈអចិន្ត្រៃយ៍ ព្រមទាំងចំនួនដែលយើងមិនអាចបានដឹងអំពីសមាជិករបស់

គណៈ មជ្ឈិម និងជាមួយនិងលេខាផ្សេងៗទៀតនៅតាមតំបន់ និងនៅតាមភូមិភាគ ដែលចំនួនយើងមិនបានដឹង ហើយអ្នកសួរចម្លើយស្ថិតនៅក្រោមបង្គាប់របស់ជនជាប់ចោទនេះ នៅក្នុងដំណើរការសួរចម្លើយគឺជន ជាប់ចោទបានដឹង ឬក៏បានទទួលព័ត៌មានជាច្រើន អំពីរចនាសម្ព័ន្ធ អំពីប្រតិបត្តិការ និងអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ទៅតាមការអនុវត្តនៅទូទាំងប្រទេស ។

**ស៖** ដូច្នេះ នៅពេលដែលលោកនិយាយថា គាត់អាចទៅជួបមេដឹកនាំជាន់ខ្ពស់ យើងនិយាយអំពី មនុស្សពីរនាក់ដែលជាមេរបស់គាត់ គឺ សុន សេន ហើយនិង នួន ជា តើដូច្នេះទេ?

**ឆ៖** បាទ ។ ហើយខ្ញុំក៏បាននិយាយយោងផងដែរ ទៅលើថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងៗទៀតដែលត្រូវបានសួរចម្លើយជាលម្អិតនោះ ។

[១៦:០៧:២៩]

**ស៖** ដូច្នេះ មេដឹកនាំជាន់ខ្ពស់ដែលគាត់ នៅពេលដែលគាត់បានសួរសំណួររបស់ពួកគាត់នោះ គឺថា ពេលនុំងមេដឹកនាំទាំងនោះ គឺថា គាត់អត់មានឥទ្ធិពលទៅលើគោលនយោបាយរបស់បក្សកុម្មុយ-នីស្តទេ នៅពេលដែលគាត់សួរចម្លើយមេដឹកនាំអស់ទាំងនោះ មែនទេ?

**ឆ៖** បាទ, ត្រឹមត្រូវហើយ គឺថាមិនមានសំណួរអីផ្សេងទៀតទៅលើចំណុចនោះ ។ គឺពេលនុំងពួកគេបញ្ចប់នូវអាជីពរបស់គេហើយ ។

**ស៖** មានការចង់ឲ្យបញ្ជាក់នូវចំណុចមួយទៀត កាលពីព្រឹកមិញ លោកនិយាយៗ នៅពេលដែល លោកឆ្លើយសំណួររបស់លោក វ៉ែនណឺ ថា ឌុច បានចូលរួមនៅក្នុងការធ្វើបញ្ជីឈ្មោះជនក្បត់ ហើយនៅពេលដែលគាត់បានសួរលោកអំពីចំនួននោះ លោកបានឆ្លើយថា បញ្ជីនោះគឺអាចមានជនក្បត់ជាងមួយពាន់នាក់ ។ ដូច្នេះ ជាការចាំបាច់ដើម្បីធ្វើការបញ្ជាក់ឲ្យបានច្បាស់ ថាតើយើងនិយាយអំពីអ្វីនៅពេលហ្នឹង តើចំនួនមួយពាន់ជាងហ្នឹង គឺនិយាយអំពីចម្លើយសារភាពជាងមួយពាន់ ដែលមានបញ្ជីឈ្មោះជនក្បត់ ឬមួយក៏លោកចង់និយាយថា ខ្លួន ឌុច ឯងផ្ទាល់ហ្នឹងបានបង្កើត ឬក៏បានធ្វើនូវបញ្ជីឈ្មោះជនក្បត់នោះជាងមួយពាន់?

**ឆ៖** ប្រសិនបើខ្ញុំចាំមិនខុសទេ លោកមេធាវី ការសន្ទនារបស់ខ្ញុំជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីការពីព្រឹកមិញស្តីអំពីប្រធានបទនេះ ខ្ញុំបានរៀបរាប់នូវប្រភេទពីរនៃបញ្ជីជនក្បត់ ។ បញ្ជីមួយប្រភេទនោះ គឺជាបញ្ជីដែលត្រូវបានសរសេរដោយជនរងគ្រោះនៅក្នុងដំណើរការក្នុងការរៀបចំចម្លើយសារភាពរបស់ខ្លួន ហើយបញ្ជីមួយប្រភេទទៀតនោះ គឺជាលទ្ធផលនៃការវិភាគដែលត្រូវបានបង្កើត

ឡើងដោយជនជាប់ចោទ ឬក៏អ្នកសួរចម្លើយរបស់គាត់ ឬក៏បុគ្គលិកដទៃទៀតដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ជនជាប់ចោទនេះ ។ ហើយអ្វីដែលខ្ញុំចង់និយាយនោះគឺថា សរុបទៅអាចមានចំនួនច្រើននៃបញ្ជីបែបនេះ គឺថាអាចរហូតឡើងដល់ទៅជាងមួយពាន់ឯណោះ ។

**ស៖** តើលោកចាំទេថា មានបញ្ជីប៉ុន្មានដែលជនជាប់ចោទបានធ្វើដោយខ្លួនឯង ដែលអ្នកបានឃើញ គឺជាបញ្ជីដែលជនជាប់ចោទនោះបានធ្វើនោះ ។

**ឆ៖** មិនមែនទេ លោកមេធាវី ខ្ញុំមិនដែលមានបំណងព្យាយាមពិនិត្យមើលបែបនេះទេ ។

**ស៖** ដូច្នេះលោកបណ្ឌិត អេតឆេសាន់ កាលពីម្សិលមិញលោកបាននិយាយនៅចុងបញ្ចប់នៃបទសម្ភាសន៍របស់លោកនៅពេលដែលលោកឆ្លើយសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមួយទាក់ទងទៅនឹងអំណាចក្នុងការធ្វើសេចក្តីសម្រេចរបស់ជនជាប់ចោទ ។

តាមពិត លើសពីនេះទៅទៀត លើសពីអ្វីដែលលោកបានសរសេរនៅក្នុងរបាយការណ៍របស់លោក ទៅតាមការយល់ដឹងរបស់យើងនោះ គឺថាគោលបំណងនៃសំណួរដែលលោក វ៉ែនណឺ បានសួរព្រឹកមិញនេះ លោកបាននិយាយដូចខាងក្រោមនេះ៖

នេះគឺជាចំណុចសំខាន់នៃសំណួរ ដែលអង្គសវនាការនេះត្រូវពិនិត្យសម្រេច។ ចំណុចមួយនោះគឺថាការសម្រិតសម្រាំងនោះ គឺជាលទ្ធផលនៃការប្រយ័ត្នប្រយែងហួសហេតុរបស់បក្សកុម្មុយនីស្តកម្ពុជា។ ហើយចំណុចមួយទៀតនោះ យើងអាចនិយាយថា នោះគឺជាលទ្ធផលនៃវិធីសាស្ត្រដែលជនជាប់ចោទបានប្រើដើម្បីៗដេញរកខ្មាំង ខ្ញុំមិនដឹងថាពាក្យ “ដេញរកខ្មាំង” នោះត្រឹមត្រូវឬក៏អត់ទេ ។ ប៉ុន្តែ កាលពីព្រឹកមិញនៅពេលដែលលោកបានឆ្លើយសំណួររបស់លោក វ៉ែនណឺ ។ ជាថ្មីម្តងទៀត លោកបានបន្ថែមថា ការបញ្ជាក់នេះដោយបានថ្លែងថា ទាក់ទងទៅនឹងការប្រយ័ត្នប្រយែងជ្រុល នេះគឺជាបាតុភាពមួយដែលត្រូវបានគេដឹងយ៉ាងច្បាស់ពីអ្នកវិភាគនានា ទៅលើប្រព័ន្ធមួយ មានន័យថាប្រព័ន្ធហ្នឹងផ្តល់លទ្ធផលមកឲ្យក្នុងប្រព័ន្ធខ្លួនឯង ។ ហើយលោកបណ្ឌិត អេតឆេសាន់ ខ្ញុំជឿថាលោកបានផ្តល់នូវការវិនិច្ឆ័យមួយដ៏សំខាន់ ហើយដែលវាថ្មីទាំងស្រុងទៅលើអ្វីដែលលោកបានសរសេរនៅក្នុងរបាយការណ៍របស់លោក ហើយខ្ញុំត្រូវសួរលោកអំពីចំណុចនេះ ។

ដោយយោងទៅតាមការស្រាវជ្រាវរបស់លោក តើអ្វីទៅជាសមាសភាព ឬក៏ធាតុផ្សំដែលអាចផ្តល់ការគាំទ្រនូវការលើកឡើងលើកទីពីររបស់លោក ដែលលោកបាននៅក្នុងទម្រង់ ដែលមានលក្ខខណ្ឌមានន័យថា យើងអាចនិយាយថា ការធ្វើការសម្រិតសម្រាំងហ្នឹង គឺជាលទ្ធផលនៃវិធីសាស្ត្រដែលជន

ជាប់ចោទបានប្រើ ។ តើអ្វីទៅគឺជាធាតុផ្សំដែលធ្វើការគាំទ្រនូវការលើកឡើងរបស់លោកនេះ?

[១៦:១៤:០៤]

ដើម្បីបញ្ជាក់ឲ្យបានច្បាស់លើសនេះទៀត គឺយើងបាននិយាយអំពីគោលនយោបាយរបស់បក្ស ដែលខ្ញុំជឿថា វាឯករាជ្យ វាដាច់គ្នាពីអ្វីដែល ឌុច បានធ្វើ ឬក៏និយាយអំពីការភ័យខ្លាច យើងក៏និយាយអំពីការស្តាប់បង្គាប់ទាំងស្រុង ហើយដើម្បីបង្ហាញអំពីសំណួររបស់ខ្ញុំ ថាតើវិធីសាស្ត្រដែល ឌុច បានប្រើ តើវាខុសគ្នាយ៉ាងម៉េចពីមាគ៌ាដែលបក្សកុម្មុយនីស្តកម្ពុជាបានដាក់ឲ្យអនុវត្តនោះ? ហើយថាតើវិធីសាស្ត្រនេះវាខុសគ្នាយ៉ាងដូចម្តេច ឬក៏ តើវាកើតចេញពីលទ្ធផលនៃការអនុវត្តផ្ទាល់ខ្លួនយ៉ាងដូចម្តេចនោះ?

[១៦:១៥:០៨]

**ផ៖** សូមអរគុណលោកមេធាវី ។ នេះគឺជាសំណួរដ៏សំខាន់មួយតាមពិតទៅ ។ ជាដំបូង ខ្ញុំចង់ផ្តល់នូវការកែតម្រូវខ្លីតូចមួយ ឬក៏មួយនេះអាច នេះអាចជាបញ្ហានៃការបកប្រែ ខ្ញុំក៏មិនដឹងដែរ ។ អ្វីដែលខ្ញុំទើបតែបានឮពីការបកប្រែ ពីអ្វីដែលលោកបាននិយាយនោះ គឺថាលោកលើកឡើងថា នៅពេលដែលខ្ញុំពិភាក្សាអំពីបញ្ហានេះ ខ្ញុំបានយោងទៅលើវិធីដែលជនជាប់ចោទបានប្រើ ។ ខ្ញុំជឿថា ប្រសិនបើខ្ញុំនៅចាំមិនខុសទេនោះ អ្វីដែលខ្ញុំបាននិយាយពិតនោះ គឺថាវិធីដែលត្រូវបានកែសម្រួល និងបង្ខំឲ្យអនុវត្តដោយជនជាប់ចោទ ។ ហើយចំណុចនេះចាប់ផ្តើមឡើងនៅក្នុងការឆ្លើយតបសំណួររបស់លោក ។ ទៅតាមការយល់ដឹងរបស់ខ្ញុំ ដែលអាស្រ័យទៅលើការសិក្សាអស់រយៈពេលយូរអង្វែងមកហើយទៅលើរបបកម្ពុជាប្រជាធិបតេយ្យជាទូទៅ និងនៅក្នុងប្រតិបត្តិការរបស់ស-២១ ដែលជាចំណុចពិសេសនោះ ។ ព្រមទាំងអ្វីដែលកើតមានមុនស-២១ នៅក្នុងការអភិវឌ្ឍនៃវិធីរបស់អង្គការនៅក្នុងការសម្គាល់រក ការស្វែងរកខ្មាំង ។ ហើយការយល់របស់ខ្ញុំនោះគឺថា ជនជាប់ចោទនេះ គឺជាមនុស្សដែលពូកែច្នៃប្រឌិតដែលជាមេដឹកនាំ ដែលជាអ្នកអភិវឌ្ឍ និងជាអ្នកដែលគ្រប់គ្រងស្ថាប័នម្នាក់ ។ ហើយវិធីដែលធ្វើនូវចម្លើយសារភាពដ៏លម្អិត និងពិស្តារ ដែលត្រូវបានធ្វើឡើងនៅក្នុងរយៈដ៏វែងអន្លាយនោះ ។

[១៦:១៧:៣៧]

ដូច្នេះនៅក្នុងករណីខ្លះហាក់បីដូចជាបង្ហាញថា ជនរងគ្រោះត្រូវបង្ខំឲ្យសរសេរឈ្មោះអំពីមនុស្សគ្រប់គ្នាទាំងស្រី ទាំងប្រុសក្តី ដែលពួកគាត់ធ្លាប់បានជួបពីមុនមក ទោះបីជាពួកគាត់មិនចាំឈ្មោះក៏ដោយ ។ ហើយបញ្ជីទាំងនោះ ត្រូវបានគេប្រើដើម្បីយកចេញទៅក្រៅ ដើម្បីប្រមូលមនុស្សដែលមានឈ្មោះទាំងអស់នោះ ។ ហើយដំណើរបែបនេះ ត្រូវបានគេយកមកអនុវត្ត ពេលនុ៎ងយើងអាចឃើញថា

គឺជាការពន្លាតដ៏ច្រើនទៅលើចំនួនអ្នកដែលត្រូវបានគេចោទប្រកាន់ថាជាជនក្បត់ ។ ហើយចំនួនជនរងគ្រោះត្រូវបានគេសម្រិតសម្រាំងជាមួយផ្នែក ។ នេះគឺជាការបិទបាំងមួយដែលជនជាប់ចោទបានអនុវត្តទៅលើគម្រោងនេះ មានន័យថាដើម្បីបង្កើតឲ្យមានវិធីសាស្ត្រនេះ ដើម្បីដោះស្រាយទៅលើចំនួនជនរងគ្រោះដ៏ច្រើន ។

ដូច្នេះហើយ បានជាខ្ញុំសូមស្នើទៅលើការឆ្លើយតបទៅនឹងសំណួររបស់លោក គឺថានៅចំណុចមួយនយោបាយរបស់គណៈអចិន្ត្រៃយ៍ គឺពិតមានតួនាទីមួយទាក់ទងទៅចំណុចនេះ ។ ក៏ប៉ុន្តែ នៅពេលដំណាលគ្នានោះដែរ គំនិតច្នៃប្រឌិត ការច្នៃប្រឌិត និងការព្យាយាមប្រឹងប្រែងរបស់កម្មាភិបាល ដែលទទួលបន្ទុកក្នុងការអនុវត្តគោលយោបាយនោះ ក៏ចូលរួមបច្ច័យដ៏ច្រើនទៅលើចំណុចនេះដែរ ។

[១៦:១៩:៤១]

**ស៖** តើពួកគេមានជម្រើសដែរឬទេ?

**ឆ៖** ដូចដែលខ្ញុំបានស្នើឡើងពីមុនអ៊ីចឹងលោកមេធាវី ។ បុគ្គលគ្រប់រូបតែងតែមានជម្រើស ។

**ស៖** ហើយក៏បានឯកភាពជាមួយនឹងខ្ញុំដែរថា នៅថ្ងៃនេះគឺថា គាត់នៅមានរស់រានជីវិត ។

**ឆ៖** បាទ គាត់នៅរស់រានមានជីវិតមែន ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ទាក់ទងទៅនឹងអ្វីដែលលោក ហ្វ្រង់ស្វ័រ រូ បានលើកឡើង ខ្ញុំមិនមានបំណងក្នុងការធ្វើឲ្យចាប់អារម្មណ៍ដោយភ័ន្តច្រឡំទៅលើចម្លើយសក្ខីកម្មរបស់អ្នកជំនាញនេះទេ ។ ហាក់បីដូចជាមានការបង្ហាញសំណួរជាច្រើនមកពីមេធាវីការពារក្តី លើកឡើងក្នុងគោលបំណងចង់និយាយថា គឺថា មានជម្រើសតែពីរតែប៉ុណ្ណោះសម្រាប់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ។ មានន័យថាត្រូវស្លាប់ ឬក៏ត្រូវបំពេញភារកិច្ច ក៏ប៉ុន្តែដើម្បីបំពេញរូបភាពបែបនេះ គឺអ្នកជំនាញគួរតែទៅសួរថាតើគាត់បានដឹងដែរឬទេ អំពីជម្រើសទីបី ឬក៏វិធីទីបី? ដូចជាមានន័យថា រត់គេច ឬក៏រត់ភៀសខ្លួន ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន នេះមិនមែនជាពេលដើម្បីឲ្យខ្ញុំធ្វើការស្នើឡើងថា សហព្រះរាជអាជ្ញានឹងធ្វើការលើកឡើងរបស់គាត់ ប៉ុន្តែ ពេលនោះជាពេលដែលខ្ញុំត្រូវលើកឡើងអំពីអ្វីដែលខ្ញុំចង់លើកនេះ ។ ហើយនេះមិនមែនជាពេលដែលគួរតែអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា ធ្វើការលើកឡើងពីអ្វីដែលគាត់ចង់លើកឡើងនេះទេ ។ នេះជាឱកាសសម្រាប់ឲ្យខ្ញុំធ្វើការសួរទៅលើអ្នកជំនាញ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្តសំណួរតទៅទៀត ។

[១៦:២២:២២]

**សួរដោយលោក ហ្សង់ស្វ័រ រូ៖**

**ស៖** លោកបណ្ឌិត អេតធេសាន់ លោកបាននិយាយអំពីអំណាចច្នៃប្រឌិតរបស់ជនជាប់ចោទ ។ សម្រាប់ខ្ញុំហាក់បីដូចជាចម្លែកណាស់ ជាពិសេសនៅក្នុងអង្គការមួយដែលលោកបានរៀបរាប់យ៉ាងលម្អិត គឺនិយាយអំពីអង្គការចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យនោះ ។ ខ្ញុំដូចជាមិនមានការចាប់អារម្មណ៍ថា ពីថ្នាក់លើ ដល់ថ្នាក់ក្រោម គឺកម្មាភិបាលណាម្នាក់អាចមានចិត្ត ឬក៏ហ៊ានធ្វើការកែច្នៃ ឬក៏បញ្ចេញមតិរបស់ខ្លួនបាននោះទេ ដោយមិនធ្វើការសំណើទៅថ្នាក់លើរបស់ខ្លួននោះ ។ ដូច្នេះ លោកបណ្ឌិត អេតធេសាន់ នេះជាសំណួររបស់ខ្ញុំចុងក្រោយ ។

លោក អេតធេសាន់ ខ្ញុំគិតថាពាក្យដ៏ប្រសើរបំផុត ដើម្បីរៀបរាប់ពីស-២១ នោះគឺថា យើងអាចនិយាយថា ស-២១ គឺស្ថិតនៅក្រោមការ-- ថ្នាក់ដឹកនាំ ហើយដើម្បីអនុវត្តឲ្យបានដាច់ខាត ដោយមកពីមានការគ្រប់គ្រងពីមេ ពីលើនោះ ។ ខ្ញុំចង់ទៅលើលោកដែលជាអ្នកស្រាវជ្រាវឯករាជ្យនោះ ដើម្បីឲ្យផ្តល់នូវមតិយោបល់ជាអ្នកបញ្ញវន្តម្នាក់នោះ ។

តើយើងអាចនិយាយថានេះ គឺជាលទ្ធផលនៃវិធីសាស្រ្តដែលត្រូវបានធ្វើឡើង និងអនុវត្តដោយជនជាប់ចោទ ដើម្បីដេញរកខ្មាំង? ហើយខ្ញុំចង់និយាយក្នុងនាមលោកជាអ្នកស្រាវជ្រាវ ថាតើអ្វីទៅដែលជាធាតុផ្សំដែលផ្ទុយទៅនឹងចំណុចនេះ? អាស្រ័យទៅលើអ្វីដែលលោកបានដឹងពីប្រតិបត្តិការផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ ។ តើអ្វីទៅដែលជាធាតុផ្សំដែលអ្នកស្រាវជ្រាវឯករាជ្យនឹងនិយាយថា ផ្ទុយពីចំណុចនោះ ឌុច ដោយមានការព្យាយាមប្រឹងប្រែងនោះត្រូវបានមេរបស់គាត់បញ្ជារ ឬក៏បង្គាប់ឲ្យធ្វើដូច្នោះ? ខ្ញុំសូមទុកឱកាសនេះឲ្យលោកឆ្លើយ ។

**ឆ៖** ខ្ញុំចង់និយាយយោងទៅចំណុចបកក្រោយវិញលោកមេធាវី ការពិភាក្សារបស់ខ្ញុំកាលពីមុនមកទាក់ទងអំពីពាក្យពេចន៍របស់ខ្មែរក្រហម គឺពាក្យថា “ឯករាជ្យម្ចាស់ការ” ។ ទស្សនទានទៅលើពាក្យនេះ រួមបញ្ចូលទាំងគំនិតដែលថា កម្មាភិបាលដែលត្រូវធ្វើម្ចាស់ការទៅការប្រឈមមុខណាៗដែលត្រូវបានប្រគល់មកឲ្យខ្លួន ដោយធ្វើការតាមមធ្យោបាយកែច្នៃប្រឌិត ដែលវាស៊ីចង្វាក់ទៅនឹងមាគ៌ាបក្សដែលកំពុងតែមាន ដើម្បីទទួលបាននូវលទ្ធផលដែលជាគោលនយោបាយដែលគេចង់បាននោះ ។ ហើយ

ប្រហែលជាខ្ញុំអាចនឹងធ្វើការកែតម្រូវបន្តិចទៅអ្វីដែលខ្ញុំបាននិយាយដោយផ្ទាល់មាត់មុននេះបន្តិច មានន័យថា យើងអាចនិយាយថា ឬក៏ខ្ញុំអាចនិយាយថា នេះគឺជាចំណុចដែលខ្ញុំចង់លើកឡើងនោះ ។

[១៦:២៦:៣២]

**ស៖** អ៊ីចឹងលោកចង់និយាយប្រាប់ខ្ញុំថា អ្នកស្រាវជ្រាវនឹងគឺថាមិនមានមន្ទិលសង្ស័យអ្វីបន្តិចសោះ ។ ខ្ញុំគិតថាអ្នកស្រាវជ្រាវ គឺថាមានមន្ទិលសង្ស័យជាទូទៅ មានន័យថាមានសំណួរដើម្បីសួរ ។

**ឆ៖** ពិតហើយ ខ្ញុំតែងតែមានមន្ទិលសង្ស័យ ។ មានមន្ទិលសង្ស័យទៅលើរឿងជាច្រើន ហើយខ្ញុំព្យាយាមដោះស្រាយទៅលើមន្ទិលសង្ស័យនោះ នេះគឺជាវិធីដែលយើងរៀនដើម្បីបានដឹង ។ មានន័យថា ដើម្បីពិនិត្យមើលទៅមន្ទិលសង្ស័យអស់ទាំងនុ៎ង ហើយយើងពិនិត្យហើយនឹងធ្វើការសន្និដ្ឋាន ។

**ស៖** នោះគឺជាសេចក្តីសន្និដ្ឋានដែលមិនមាននៅក្នុងរបាយការណ៍របស់លោក តើនេះជាចំណុចត្រឹមត្រូវដែរ ឬទេ?

**ឆ៖** ប្រសិនបើអ្នកណាម្នាក់ពិនិត្យមើលរបាយការណ៍នេះ អាចពិនិត្យមើលឃើញយ៉ាងភ្លាមៗថា ទស្សនទានអំពីរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យនោះ គឺថាបុគ្គលម្នាក់ៗមិនមានផ្តោតអារម្មណ៍ជាចំណាងទៅលើស-២១ នោះទេ ។

**ស៖** ដូច្នេះធាតុផ្សំដែលនាំឲ្យលោកធ្វើសេចក្តីសន្និដ្ឋាននៅថ្ងៃនេះ គឺកើតចេញមកពីអ្វីដែលលោកបានដឹងចាប់តាំងពីការបង្កើតរបាយការណ៍របស់លោក មានន័យថា នៅតាំងពីដំណាក់ស៊ើបអង្កេតនោះមែនទេ?

**ឆ៖** អ៊ូ! មិនមែនអ៊ីចឹងទេលោកមេធាវី ។ នេះគឺជាការសន្និដ្ឋានមួយដែលគ្មានសុពលភាពទេ ។ គឺយ៉ាងសាមញ្ញបំផុត យ៉ាងអាចនិយាយថា ស-២១ មិនមែនជាប្រធានបទនៃរបាយការណ៍នេះទេ ។

**ស៖** ខ្ញុំសប្បាយចិត្តណាស់នៅពេលនេះ ។ អ៊ីចឹងមុននឹងយើងបញ្ចប់នេះ លោក អេតអេសាន់ ខ្ញុំជឿថាលោកបានធ្វើតារាងមួយដែលខ្ញុំបានឲ្យលោកធ្វើនោះ ។ តើលោកអាចបង្ហាញបានទេអំពីតារាងនោះ? ហើយនឹងអាចដាក់បញ្ចាំងនៅលើអេក្រង់ នូវតារាងតូចមួយនេះ?

[១៦:២៩:២៥]

**ឆ៖** លោកចៅក្រមជាទីគោរព! មន្ត្រីតុលាការបានធ្វើច្បាប់ចម្លងនូវតារាងនេះ ។ ក៏ប៉ុន្តែ ខ្ញុំសូមជម្រាបដល់លោក លោកស្រីចៅក្រមនឹងអង្គសវនាការថា ខ្ញុំមិនមែនជាសិល្បករទេ ហើយខ្ញុំក៏មិនមែន

ជាអ្នកពូកែខាងសិល្បកម្មដែរ ។ ដល់ហើយពេលវេលាសម្រាប់ការធ្វើកិច្ចការនេះ វាមានពេលខ្លី ។ ដូច្នេះ ឲ្យខ្ញុំសុំទោសជាមុន ប្រសិនបើការគូសគំនូសរបស់ខ្ញុំហ្នឹង វាមិនបានស្អាតនោះ ។

**ស៖** សូមអរគុណដែលបានធ្វើតារាងនេះសម្រាប់ពួកយើង លោក អេតឆេសាន់ ។ ដំបូងខ្ញុំសូមធ្វើការកត់សម្គាល់ជាបឋមសិនថា ខ្ញុំយល់ថាពិបាកបន្តិច ម្សិលមិញលោកបានឆ្លើយយ៉ាងច្បាស់ទៅលើសំណួរទាក់ទងអំពីរចនាសម្ព័ន្ធ ។ បើយើងមើលតាមរចនាសម្ព័ន្ធ គឺថាឌុច នៅខាងក្រោមកងពល ប៉ុន្តែនៅក្នុងតារាងនេះ លោកដាក់គាត់នៅពីលើកងពលអស់ទាំងនោះ ក៏ប៉ុន្តែ តើនេះវាស្របគ្នាទៅនឹងអ្វីដែលលោកបាននិយាយមុននេះ ។ ហេតុដូច្នេះ ខ្ញុំសូមរក្សាសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំ នៅពេលដែលខ្ញុំបានមើលឃើញតារាងនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញដាក់បញ្ចាំងស្លាយនូវឯកសាររចនាសម្ព័ន្ធជាភាសាអង់គ្លេស ដើម្បី-- សូមអញ្ជើញលោកបណ្ឌិត ក្រេក អេតឆេសាន់ ដើម្បីឆ្លើយតបទៅនឹងសំណួររបស់លោកមេធាវី ។

មិនឃើញទេ អ្នកបច្ចេកទេស ។ បានហើយ ឃើញហើយ សូមអញ្ជើញលោកបណ្ឌិត ។

**លោក ក្រេក អេតឆេសាន់៖**

សូមអរគុណលោកប្រធាន ។ មុនពេលយើងសម្រាកសម្រាប់អាហារថ្ងៃត្រង់ មេធាវីការពារក្តីបានស្នើឲ្យខ្ញុំ ដាក់បញ្ចូលគ្នានូវតារាងចំនួនពីរ ដែលតាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំយល់ថា មិនអាចដាក់បញ្ចូលគ្នាឲ្យបានស្អាតនោះទេ ឬក៏ផ្តល់នូវលទ្ធផលជាព័ត៌មានពេញលេញនោះ ។ អ្វីដែលយើងកំពុងមើលនៅលើអេក្រង់នេះ គឺជាលទ្ធផលនៃសំណើរបស់មេធាវីការពារក្តីនោះ ។ ដ្យាក្រាមនេះ រួមមានតារាងស្តីអំពីរដ្ឋាភិបាល ដែលយើងបានពិភាក្សាគ្នាពីមុនមកនៅក្នុងសវនាការនេះ ។ ហើយខ្ញុំមានដាក់បញ្ចូលបន្ថែមទាក់ទងទៅនឹងអង្គការលេខ ដែលស្ថិតនៅក្រោមបង្គាប់របស់អគ្គសេនាធិការ ។ រួមបញ្ចូលទាំងកងពលយោធាចំនួនប្រាំបួន និងកងវរសេនាធំឯករាជ្យចំនួនបី និងមន្ទីរចំនួនពីរ ដែលជាមន្ទីររបស់សេនាធិការ ។

នេះគឺជាអ្វីដែលជាសំណើរបស់មេធាវីការពារក្តី ដែលស្នើមកយើងខ្ញុំ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន លោកចៅក្រម ។ មេធាវីការពារក្តីតាមពិតបានស្នើឲ្យធ្វើដ្យាក្រាមនេះ ជាចំណុចបន្ថែម ហើយសូមអរគុណទៅលើលោកជំនាញ ដែលបានធ្វើការងារនេះ ។ ប៉ុន្តែយើងត្រូវចាំថា អ្វីដែលយើងចង់បាននោះ គឺអ្វីដែលគាត់ ដែលលោក អេតឆេសាន់ បានលើកឡើងកាលពីម្សិលមិញ ។

មានភាគីមួយបានសួរសំណួរ ហើយលោកបានឆ្លើយថា នៅក្នុងប្រអប់ខាងក្រោមនេះ គឺលេខាកងពលរួមបញ្ចូលទាំង ស៊ូ ម៉េត គឺនៅពីលើ ឌុច។ ប៉ុន្តែ ឥឡូវនេះខ្ញុំមានបញ្ហា ពីព្រោះខ្ទុះប្រអប់អស់ទាំងនេះ នៅពីខាងក្រោមប្រអប់របស់ ឌុច ។ ដូច្នេះខ្ញុំ បើសិនជាមើលរបាយការណ៍នៅទំព័រ១០៩ នៅចំណុច១០៩នោះ គឺលេខាធិការជាអ្នកគ្រប់គ្រងទៅលើកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែយើងមើលឃើញថាសុន សេន គឺជាប្រធាន ហើយនិងបន្ទាប់គឺថា មានអនុប្រធាន ហើយនិង តាម៉ុកជាប្រធាន ហើយនិង ចាន់ចក្រី គឺជាអនុប្រធាន ។ ហើយបន្ទាប់មកទៀត គឺយើងមានសមាជិកមួយចំនួននៃអគ្គសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជា ។ នេះគឺជាមនុស្សដែលខ្ញុំបានឲ្យឃើញ ដែលបញ្ជាក់នៅលើតារាង គឺមានឆាយ គឹមហ៊ី ដែលត្រូវសម្លាប់នៅឆ្នាំ១៩៧៨ ។ ស៊ូ ម៉េត, សូ សារឿន ត្រូវបានសម្លាប់ ១៩៧៨ ។ មាស មុត នៅរស់ ។ ខាត់ រឿន នៅរស់ និង ស៊ុន ទី ដែលនៅរស់ ។ ហើយនេះគឺជាអ្វីដែលលោកមានរៀបរាប់នៅក្នុងកថាខណ្ឌ១០៩ នៃរបាយការណ៍របស់លោក ។ ដូច្នេះ ខ្ញុំមិនយល់ប៉ុន្មានទេ ។ ឥឡូវនេះ គឺថាលោកបានឆ្លើយសំណួររបស់ខ្ញុំ គឺថានៅពេលដែលលោកធ្វើសេចក្តីព្រាងរបាយការណ៍របស់លោក ដែលជារបាយការណ៍ទូទៅ ដែលមិនបញ្ជាក់ឲ្យជាក់លាក់ទៅលើ ឬក៏ផ្តោតទៅលើស-២១នោះទេ ។ ក៏ប៉ុន្តែ នៅក្នុងតារាងមួយ ដែលលោកមាន គឺថាលោកឃើញមានតួនាទីរបស់ឌុច ដែលមាននៅក្នុងតារាងនោះ ។ ហើយនៅក្នុងតារាងនោះដែរ លោកមិនមានបញ្ចូលអំពីចំនួនបុគ្គលមួយចំនួនដែលយើងជឿថា គឺជាការសមស្របនៅក្នុងការដាក់បញ្ចូលនៅក្នុងតារាងបែបនេះ ហើយដែលបង្ហាញអំពីតួនាទីត្រឹមត្រូវរបស់ពួកគាត់ ដែលគេមាននៅក្នុងតារាងរចនាសម្ព័ន្ធទាំងមូលនោះ ។ ហើយខ្ញុំក៏ភ្លេចនិយាយនៅចំណុចមួយទៀត ខ្ញុំមិនចូលចិត្ត យើងខ្ញុំក៏មិនចូលចិត្តនៅក្នុងការបន្ទោសគ្នានោះដែរ ។

[១៦:៣៨:០៣]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ចំណុចចុងក្រោយដែលលោក រូ បានលើកឡើង តើនេះគឺជាសំណួរទៅលើអ្នកជំនាញឬ? បើសិនជាសំណួរមែន គឺមានន័យថាគួរតែឲ្យលោកអ្នកជំនាញហ្នឹងឯង គឺត្រូវឆ្លើយតប ។ ដូច្នេះ នេះគឺជាចំណុចល្បិចមួយរបស់ខាងគាត់ ។ ខ្ញុំចង់ឲ្យលោកអ្នកជំនាញឆ្លើយតបទៅនឹងចំណុចនេះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

តើលោកបានសួរសំណួរទៅលើជនអ្នកជំនាញពីមុនមក លោកបានធ្វើការលើកឡើង ប៉ុន្តែមិនមែនសំណួរនោះទេ ។ លោកបាននិយាយថា អាចនឹងមានជម្រើសទីបី ដូចគ្នាអ៊ីចឹងដែរ ខ្ញុំគឺគ្រាន់តែចង់

បង្ហាញអំពីគំនិតរបស់ខ្ញុំតែប៉ុណ្ណោះ មិនមែនជាការដាក់បន្ទោសទៅលើគ្នានោះទេ ។

**លោក អាឡិចសាន់ឌឺ បេ៊ត៖**

ខ្ញុំយល់ថា ឥឡូវនេះ ខ្ញុំមិនចង់ឲ្យធ្វើទៅជាល្បែងក្នុងការលេងពីងប៉ុង វៃទៅ វៃមកនោះទេ ។ គឺខ្ញុំចង់ឲ្យលោកប្រធាន បង្គាប់ឲ្យគាត់នឹងឯង សួរសំណួរទៅលើអ្នកជំនាញ ទៅលើវិធីសាស្ត្រដែលត្រូវបានអនុវត្តមកលើកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ហើយខ្ញុំសូមឲ្យសួរទៅលើអ្នកជំនាញ ហើយបើសិនជាមេធាវីការពារក្តីពិបាកក្នុងការសួរសំណួរនោះ គឺខ្ញុំសូមឲ្យលោកប្រធានអនុញ្ញាតឲ្យសាក្សីនេះធ្វើការឆ្លើយតបទៅនឹងអ្វី ដែលខាងសហព្រះរាជអាជ្ញាបានយល់ថា ការអង្កេតដ៏វែងអន្លាយដែលត្រូវបានលើកឡើងនោះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ សួរថា ឥឡូវហ្នឹងគឺជាការអនុវត្តនៅតាមសំណើសុំរបស់លោកមេធាវីការពារក្តីលើបញ្ហាការគូសតារាងនេះ ហើយពាក់ព័ន្ធនឹងតារាងដែលបានគូសហើយនេះ សូមលោកបញ្ជាក់ឲ្យបានច្បាស់លាស់ពីសំណួរពាក់ព័ន្ធទៅនឹងតារាងដែលបានបង្ហាញដោយអ្នកជំនាញឲ្យច្បាស់លាស់ ហើយប្រសិនបើលោកមានសំណួរ ឬគ្មានសំណួរ សូមធ្វើឲ្យបានច្បាស់លាស់ដើម្បីយើងអង្គជំនុំជម្រះយល់បានអំពីបញ្ហានេះ ។ ហើយថាតើវិធីបន្តទៅទៀតហ្នឹង ត្រូវគ្រប់គ្រងសវនាការហ្នឹងតាមបែបណាទៅ ។

លោកមេធាវី ហ្វ្រង់ស័រ រូ មានសំណួរអ្វីទៀតទេ ដែលត្រូវសួរដល់អ្នកជំនាញរូបនេះពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ដែលលោកសូមឲ្យអ្នកជំនាញគូសនេះ បើមានសូមអញ្ជើញសួរបន្តទៀត បើគ្មានសូមប្រាប់ថាគ្មាន ដើម្បីអង្គជំនុំជម្រះមានការគ្រប់គ្រងដំណើរការនីតិវិធីសវនាការហ្នឹង ទៅមុខទៀត ។

[១៦:៤១:២០]

**លោក ហ្វ្រង់ស្វ័រ រូ៖**

មិនមានទេលោកប្រធាន សូមអរគុណ ខ្ញុំអត់មានសំណួរទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រី អង្គជំនុំជម្រះមានសំណួរអ្វីត្រូវសួរដល់អ្នកជំនាញរូបនេះ បន្តទៀតទេ? បន្ថែមទៀតទេ?

បើគ្មានទេ ពេលវេលាសម្រាប់រសៀលនេះចប់សព្វគ្រប់ហើយ ហើយអ្នកបច្ចេកទេសសូមបង្វែររូបភាពប្រក្រតីភាពឡើងវិញ ហើយអង្គជំនុំជម្រះសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្ឌិត

ក្រេក អេតឆេសាន់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្ម ។ ហើយការចំណាយពេលវេលារបស់លោក គឺចំណាយពេលច្រើន ហើយនិងប្រកបដោយភាពអត់ធ្មត់ ដែលគួរឱ្យសរសើរ។ ហើយអង្គជំនុំជម្រះសូមប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកយកទៅបន្តនៅថ្ងៃច័ន្ទ ទី៨ ខែមិថុនា ឆ្នាំ២០០៩ ហើយសូមជម្រាបដល់ភាគីផងដែរថា សវនាការបន្តនោះ យើងនឹងធ្វើសវនាការសួរដេញដោលទៅលើជនជាប់ចោទ ដោយភាគីអំពីអង្គហេតុទាំងពីរ គឺអង្គហេតុដែលលើការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលភាគីបានស្នើសុំលើកមុន ហើយដោយសារយើងជាប់ធ្វើសវនាការលើអ្នកជំនាញរហូតដល់ពីររូប ដែលត្រូវចំណាយពេលវេលាច្រើន ហើយនិងអង្គហេតុមួយទៀត គឺជម្លោះប្រដាប់អាវុធ ដែលយើងមិនទាន់បានធ្វើការដេញដោលចំពោះជនជាប់ចោទនៅឡើយ ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឱ្យនាំគាត់មកកាន់សវនាការតាមការកំណត់ ដូចអម្បាញ់មិញនេះ ៕

*[សវនាការផ្អាកនៅម៉ោង១៦:៤៤ នាទី]*